វិទ្យាស្ថានស្រាវជ្រាវ និង អភិវឌ្ឍន៍នេសាទទឹកសាប



ដើម្បីអភិវឌ្ឍន៍ជលផលទឹកសាបកម្ពុជាដោយនិរន្តរភាព

WorldFish CENTER

ឯកសារគោលនយោបាយ

# កំណែទម្រង់វិស័យជលផលនៃប្រទេសកម្ពុជា: ការប្រឈមថ្មីដែលទាក់ទងនឹងគោលនយោបាយ និង ការស្រាវជ្រាវ




បណ្ឌិត ចន គុរាន

បណ្ឌិត សូ ណាម

លោក ម៉ៅ សំអុន



គាំទ្រដោយ

ADB

ADB TA 4563-CAM

ការកសាងសមត្ថភាព នៃវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍នេសាទទឹកសាប (វគ្គ២)



អាគារលេខ ១៨៦, មហាវិថីព្រះនរោត្តម, រាជធានីភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា, ប្រអប់សំបុត្រលេខ ៥៨២, ទូរស័ព្ទ/ទូរសារ: (៨៥៥) ២៣ ២២០ ៤១៧

អ៊ីម៉ែល: info@ifredi.org គេហទំព័រ: www.ifredi.org

# កំណែទម្រង់វិស័យជលផលនៃប្រទេសកម្ពុជាៈ ការប្រឈមថ្មី ដែលទាក់ទងនឹងគោលនយោបាយ និង ការស្រាវជ្រាវ

ចន គុរាន

សូ ណាម

ម៉ៅ សំអុន

ឆ្នាំ ២០០៦

បោះពុម្ពផ្សាយដោយវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍នេសាទទឹកសាប (IFReDI) នៃនាយកដ្ឋានជលផល

អាសយដ្ឋាន : អាគារលេខ ១៨៦ មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

Kurine, J, So, N, Mao, S.O. 2006. Cambodia's Aquarian Reforms: Implications and Challenges for Research and Policy. Inland Fisheries Research and Development Institute, Phnom Penh, Cambodia. 52 pp.

ឯកសារគោលនយោបាយនេះត្រូវបានរៀបរៀងឡើង ជាផ្នែកមួយនៃជំនួយបច្ចេកទេសសម្រាប់ការកសាងសមត្ថភាព នៃវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍នេសាទទឹកសាបដែលបានអនុវត្តដោយមជ្ឈមណ្ឌលត្រីពិភពលោក និងគាំទ្រដោយ ធនាគារអភិវឌ្ឍន៍អាស៊ី (TA 4563-CAM).

នេះមិនមែនជាការបោះពុម្ពផ្សាយជាផ្លូវការរបស់ធនាគារអភិវឌ្ឍន៍អាស៊ីទេ ហើយទស្សនៈដែលបានឆ្លុះបញ្ចាំងនៅទីនេះ មិនទាក់ទងនឹងធនាគារអភិវឌ្ឍន៍អាស៊ីឡើយ ។

ISBN-10: 99950 - 65 - 00 - 2
9789995065003
ISBN-13: 99950 - 65 - 01 - 0
9789995065010

# កំណែទម្រង់វិស័យជលផលនៃប្រទេសកម្ពុជាៈ ការប្រឈមថ្មី ដែលទាក់ទងនឹងគោលនយោបាយ និង ការស្រាវជ្រាវ


ចន គុភាន[១]

សូ ណាម[២]

ម៉ៅ សំអុន[៣]



ម.ឯ.ឯ.ក AIDOC
Code: 141-015
Date:
Donated by:



[១] បណ្ឌិតសាស្ត្រាចារ្យ ពីមជ្ឈមណ្ឌលសម្រាប់សិក្សាការអភិវឌ្ឍ នៅ ទ្រីវ៉ានដ្រូម ប្រទេសឥណ្ឌា

[២] អនុប្រធានការិយាល័យកិច្ចការដែនទេសាទ និងផ្សព្វផ្សាយ នៃនាយកដ្ឋានជលផល រាជធានីភ្នំពេញ កម្ពុជា

[៣] អនុប្រធានការិយាល័យរដ្ឋបាល បុគ្គលិក និងជាអ្នកជំនួយការប្រធាននាយកដ្ឋានជលផល រាជធានីភ្នំពេញ កម្ពុជា

# មាតិកា

បញ្ជីតារាង, បញ្ជីរូប, បញ្ជីប្រអប់, បញ្ជីផែនទី ..... iii
ពាក្យបំព្រួញ ..... iii
សេចក្តីថ្លែងអំណរគុណ ..... iv
សេចក្តីសង្ខេប ..... v
សេចក្តីផ្តើម ..... ១
១. ការប្រែប្រួលនៃដែនទឹក និងធនធាន ..... ៣
២. កំណែទម្រង់វិស័យជលផល : ប្រវត្តិខ្លះៗ ..... ៦
៣. កំណែទម្រង់វិស័យជលផល : ការប្រឈមដែលកើតឡើងថ្មី ..... ១១
៤. អនុសាសន៍ ..... ៣៧
សេចក្តីសន្និដ្ឋាន ..... ៤០
ឯកសារយោង ..... ៤៣

CDRI R.D.C.
Code
Date
Donated By

## បញ្ជីតារាង

តារាងទី ១: ការប្រែប្រួលរូបភាពនៃសិទ្ធិចេញចូល និងប្រើប្រាស់
នៅក្នុងតំបន់នានានៃឡូត៍នេសាទក្នុងប្រទេសកម្ពុជា ........................ ១២

## បញ្ជីរូប

រូបទី ១: បរិមាណផលនេសាទទឹកសាបក្នុងប្រទេសកម្ពុជា ទិន្នន័យផ្លូវការ ........................ ១៦
រូបទី ២: លក្ខណៈវិនិច្ឆ័យសម្រាប់បកស្រាយអំពីចំនុចជាក់លាក់នៃអត្តសញ្ញាណ
របស់សហគមន៍នៅជាប់ដែន ទឹកក្នុងប្រទេសកម្ពុជា ........................ ២៨

## បញ្ជីប្រអប់

ប្រអប់ ១: ប្រវត្តិនៃឡូត៍នេសាទនៅក្នុងវិស័យជលផលនៃប្រទេសកម្ពុជា ........................ ៧
ប្រអប់ ២: ទិដ្ឋភាពសំខាន់ខ្លះៗនៃអនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍នេសាទ (SDCFM)
នៃព្រះរាជរដ្ឋាភិបាលកម្ពុជា ........................ ១៩

## បញ្ជីផែនទី

ផែនទី ១: ផែនទីប្រទេសកម្ពុជា បង្ហាញតំបន់ឡូត៍នេសាទដែលបានកាត់ចេញ
សម្រាប់សហគមន៍នេសាទ........................ ១៤

## ពាក្យបំព្រួញ

CARDI - Cambodian Agricultural Research and Development Institute
CC- Commune Councils
CDRI - Cambodia Development Research Institute
CF - Community Fisheries
CFA - Community Fisheries Area
CFC - Community Fisheries Committee
CFDO - Community Fisheries Development Office
CRRI - Cambodia Rubber Research Institute
D&D - Decentralisation and Deconcentration
DoF - Department of Fisheries
EJF - Environmental Justice Foundation
FACT - Fisheries Action Coalition Team
FAO/UN - Food and Agriculture Organisation of the United Nations
FWSRI - Forest Wildlife Science Research Institute
GDP - Gross Domestic Product
IFReDI - Inland Fisheries Research and Development Institute
MAFF - Ministry of Agriculture, Forestry and Fisheries
NAHPIC - National Animal Health and Production Investigation Center
NGO - Non-Governmental Organisations
PFO - Provincial Fisheries Office
RGC - Royal Government of Cambodia
SDCFM - Sub-Decree on Community Fisheries Management
UNESCO - United Nations Economic Scientific and Cultural Organisation
UNTAC - United Nations Transitional Authority in Cambodia

## សេចក្ដីថ្លែងអំណរគុណ

ឯកសារគោលនយោបាយនេះត្រូវបានរៀបរៀងឡើង ជាផ្នែកមួយនៃជំនួយបច្ចេកទេសសម្រាប់ការកសាងសមត្ថភាពនៃវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍នេសាទទឹកសាប (IFReDI) នៃនាយកដ្ឋានជលផល ព្រះរាជាណាចក្រកម្ពុជាដែលបានទទួលការគាំទ្រពីធនាគារអភិវឌ្ឍន៍អាស៊ី និងអនុវត្តដោយមជ្ឈមណ្ឌលត្រីពិភពលោក ។ យើងសូមថ្លែងអំណរគុណចំពោះការលើកទឹកចិត្តពីសំណាក់ ឯកឧត្តម **ណៅ ធួក** ប្រធាននាយកដ្ឋានជលផល លោក **ស្រ៊ុន លឹមសុខ** នាយកវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍នេសាទទឹកសាប លោក **ម្លួក វ៉ាត់ណឺ** នាយកប្រចាំតំបន់នៃការិយាល័យមហាតំបន់ទន្លេមេគង្គរបស់មជ្ឈមណ្ឌលត្រីពិភពលោក **វ៉ែណាត្ន អាឆាយ៉ាន** ប្រធានក្រុមនៃគំរោងជំនួយបច្ចេកទេស ADB TA 4563-CAM និង ឯកឧត្តម **នុច ស៊ាងតាណា** សមាជិកក្រុមសង្កេតការណ៍សេដ្ឋកិច្ច សង្គម និងវប្បធម៌នៃគណៈរដ្ឋមន្ត្រី (រដ្ឋលេខាធិការ) នៃរាជរដ្ឋាភិបាលកម្ពុជា។ យើងក៏សូមថ្លែងអំណរគុណផងដែរចំពោះលោក **ម្លួក វ៉ាត់ណឺ វ៉ែណាត្ន អាឆាយ៉ារី ស៊ឹន ស៊ីវ៉ាប់ ចេនសិន លី ឌុន្នី ឈួន ចំណាន អេង ចាំសាន ក្លួយគុន ចាក អេរិច ឈាវ៉ីន** និង **ណៅ ធួក** ដែលបានផ្ដល់យោបល់លើសេចក្ដីព្រាងឯកសារនេះ។ ទោះជាយ៉ាងណាក៏ដោយ យើងនៅតែជាអ្នកទទួលខុសត្រូវចំពោះរាល់កំហុសឆ្គង ឬការខ្វះខាតដែលអាចមាននៅក្នុងឯកសារនេះ។

# សេចក្តីសង្ខេប

## កំណែទម្រង់វិស័យជលផលនៃប្រទេសកម្ពុជា៖ ការប្រឈមថ្មីដែលទាក់ទង នឹងគោលនយោបាយ និង ការស្រាវជ្រាវ

ដោយ

ចន គុរាន   សូ ណាម និង ម៉ៅ សំអុន

គោលបំណងចំបងនៃឯកសារនេះ គឺជាការបង្កើតឱ្យមានកិច្ចប្រឹងប្រែងតូចមួយ ដើម្បីគូសបញ្ជាក់អំពីការប្រឈមដែលកំពុងកើតឡើងនៅក្នុងដំណាក់កាលបច្ចុប្បន្ននៃកំណែទម្រង់វិស័យជលផលក្នុងប្រទេសកម្ពុជាដែលជាសមាសភាគសំខាន់មួយ ជាពិសេសនៅក្នុងអន្តរកាលនៃការផ្លាស់ប្តូរពីឡូត៍នេសាទទៅសហគមន៍នេសាទ។ ការប្រឈមនានារួមមាន វិសាលភាពនៃកំណែទម្រង់ស្ថាប័ន និង គោលនយោបាយ ចំណាត់ការនៅមូលដ្ឋាន ការច្នៃប្រឌិត និងការស្រាវជ្រាវ។ យើងបង្ហាញអំពីកិច្ចប្រឹងប្រែងរបស់យើង ដោយចាប់ផ្តើមពីការវាយតម្លៃអំពីសារៈសំខាន់នៃធនធានជលផល និងផ្តល់ព័តមានសង្ខេបអំពីប្រវត្តិដើមដែលនាំឱ្យមានកំណែទម្រង់នេះ។ បន្ទាប់មក មានការពិនិត្យមើលអំពីការផ្លាស់ប្តូរលើសិទ្ធិនៃការប្រើប្រាស់ និងកម្មសិទ្ធិ ព្រមទាំងអំពីការផ្លាស់ប្តូរនៃប្រព័ន្ធដែលត្រូវបានបង្កើតឡើងដោយសារកំណែទម្រង់នេះ។ លើសពីនេះ ក៏មានការលើកឡើងផងដែរអំពីថាតើអាចធ្វើការវាយតម្លៃបែបណាអំពីការផ្លាស់ប្តូរនៅក្នុងអន្តរកាលនេះ និងអំពីថាតើអាចផ្តល់កិច្ចប្រឹងប្រែងបែបណាដើម្បីគាំទ្រសហគមន៍នេសាទក្នុងការលើកសម្រេចទាំងខាងគោលដៅសេដ្ឋកិច្ច និងសង្គម ។ យើងក៏លើកឡើងផងដែរអំពីបញ្ហាសាំញ៉ាំ អំពីអត្តសញ្ញាណសង្គម និងការប៉ងប្រាថ្នាដើម្បីបង្កើតឱ្យមានគំនិតថ្មីអំពីការអនុវត្តការងារតាមបែបសហគមន៍។ តួនាទីថ្មីរបស់ស្ត្រី សារៈសំខាន់នៃការបង្កើតបណ្តាញការងារ និងកិច្ចសហការកាន់តែជិតស្និទ្ធជាមួយរចនាសម្ព័ន្ធអភិបាលកិច្ចមូលដ្ឋាននៃប្រទេសកម្ពុជា និងភាពរស់រវើកនៃការចាត់ចែងសង្គមស៊ីវិល ក៏មានគូសបញ្ជាក់នៅទីនេះផងដែរ។ កំណែទម្រង់បានបង្កើតបរិបទថ្មីខាងផ្នែកច្បាប់សម្រាប់ប្រព័ន្ធអេកូឡូស៊ីតូចៗ និងអភិបាលកិច្ចធនធាន។ ប៉ុន្តែការធ្វើបែបនេះនឹងមិនបង្វែរការយកចិត្តទុកដាក់ចេញពីតម្រូវការឱ្យមានការយល់ដឹងអំពីបរិបទធំទូលាយ "ជាសកល" នោះឡើយ ទោះបីការយល់ដឹងនេះទាក់ទងនឹងលក្ខណៈឌីណាមិកនៃប្រព័ន្ធអេកូឡូស៊ី ឬអាទិភាពនានានៃអភិបាលកិច្ចក៏ដោយ។ យើងស្នើឱ្យមានការពិនិត្យឡើងវិញ អំពីអាទិភាពនៃការស្រាវជ្រាវ និងអភិវឌ្ឍន៍ វិធីនានាដើម្បីធ្វើការពិចារណាដោយវែកញែកអំពី "ស្ថានភាពជាក់ស្តែងនៅមូលដ្ឋាន" ដែលកើតឡើងថ្មី និងវិវត្តន៍ ព្រមទាំងបង្ហាញពីទំនាក់ទំនងទន្ទឹមគ្នានៃអាទិភាពទាំងពីរនេះ ជាមួយស្ថានភាពដែលកើតមាននៅក្នុងបរិបទធំទូលាយនៅ "កម្រិតពិភពលោក"។ ផ្នែកចុងក្រោយនៃការបកស្រាយរបស់យើងមានភ្ជាប់ជាមួយនូវអនុសាសន៍នានាសម្រាប់អ្នកដើរតួខុសៗគ្នាដែលពាក់ព័ន្ធនៅក្នុងដំណើរការធ្វើកំណែទម្រង់វិស័យជលផល។ នេះជាការអំពាវនាវឱ្យមានបេសកម្មថ្មី និងកិច្ចសហការកាន់តែច្រើនឡើងពីសំណាក់គ្រឹះស្ថានស្រាវជ្រាវ វិធីសាស្ត្រថ្មីៗសម្រាប់ ការប្រមូលទិន្នន័យ ការចូលរួមកាន់តែច្រើនឡើងជាមួយរចនាសម្ព័ន្ធអភិបាលកិច្ចមូលដ្ឋាន យុទ្ធសាស្ត្រដកថយសម្រាប់ទីភ្នាក់ងារផ្តល់ជំនួយ និងអំពីតម្រូវការឱ្យបង្កើតវិទ្យាស្ថានជាតិសម្រាប់អនុវត្ត និងបណ្តុះបណ្តាលអំពីសហគ្រប់គ្រង។

# សេចក្តីផ្តើម

នៅពេលថ្មីៗនេះ បណ្តាប្រទេសកំពុងអភិវឌ្ឍន៍បានជួបប្រទះនឹងកាលានុវត្តភាព និងបញ្ហាជាច្រើន ទាក់ទងនឹងកិច្ចប្រឹងប្រែងរបស់ខ្លួន ដើម្បីជម្រុញឱ្យមានកំណើនសេដ្ឋកិច្ច និងលើកកំពស់ការអភិវឌ្ឍធនធានមនុស្ស។ ការផ្តល់ឱ្យប្រជាពលរដ្ឋដែលមានចំនួនកាន់តែកើនច្រើនឡើង នូវសិទ្ធិអំណាច និងសមត្ថភាពដែលចាំបាច់ ដើម្បីបំពេញតាមបំណងប្រាថ្នាដែលកាន់តែកើនឡើង នៅក្នុងបរិបទនៃសេដ្ឋកិច្ចតាមបែបសកលភាវូបនីយកម្ម និងដែលពឹងផ្អែកជាចំបងលើទីផ្សារ ច្រើនតែជាកិច្ចការដែលស្ថិតនៅក្រោមឥទ្ធិពលនៃគោលនយោបាយទីផ្សារ និងអ្នកនយោបាយ។ តាមរយៈការប្រើប្រាស់ធនធានធម្មជាតិដែលកកើតឡើងវិញនៅក្នុងប្រទេស ភាពសំបូរស្តុកស្តម្ភពិតប្រាកដនៃប្រទេសមួយច្រើនតែជា "ជម្រើសជកថយ" ដែលទាំងរដ្ឋ និងប្រជាជន ឯកភាពគ្នាទទួលយក នៅពេលវិបត្តិនានាបានកើតឡើងនៅក្នុងវិស័យនានាផ្សេងទៀតនៃសេដ្ឋកិច្ច។ ជម្រើសដែលផ្តោតលើទីផ្សារ ដើម្បីបម្លែងធនធានធម្មជាតិ ទៅជាទ្រព្យសម្បត្តិ ច្រើនតែបញ្ចប់នៅក្នុងអ្វីមួយដែលនៅពេលថ្មីៗនេះ Herman Daly (Daly, 2005) បានហៅថាជា "សោកនាដកម្មនៃការច្នៃប្រឌិត ឬភាពកម្រដែលធ្វើឱ្យរងគ្រោះដោយខ្លួនឯង" ។ ជាទូទៅ វិធានបែបនេះ ធ្វើឱ្យឯកជនមួយចំនួនតូចកេងយកផលប្រយោជន៍បានច្រើន និងរាំងមនុស្សជាច្រើនផ្សេងទៀត មិនឱ្យប្រើប្រាស់សម្បត្តិសាធារណៈ។ ទោះបីមានការទទួលស្គាល់អំពីភាពខ្វះខាតនៃវិធានបែបនេះក៏ដោយ ប៉ុន្តែដោយសារច្រើនតែស្ថិតក្រោមសម្ពាធពីប្រជាពលរដ្ឋ និងសង្គមស៊ីវិល រដ្ឋនានាជាចំនួនកាន់តែច្រើនឡើង ពុំមានជម្រើសផ្សេង ក្រៅពីចាត់វិធានការដើម្បីបើកចំហរធនធានធម្មជាតិ សម្រាប់ការប្រើប្រាស់ដោយសហគមន៍ ដែលជាអ្នកពឹងផ្អែកលើធនធានទាំងនោះសម្រាប់ការចិញ្ចឹមជីវិត។ ការធ្វើបែបនេះ ដោយពុំមានការចាត់ចែងស្ថាប័នឱ្យបានសមស្រប ដើម្បីកែសម្រួល ការប្រើប្រាស់ និងការគ្រប់គ្រងធនធានទាំងនេះ ច្រើនតែនាំទៅរក "សោកនាដកម្មនៃការប្រើប្រាស់ដោយបើកចំហរ" ។ ការស្វែងរក "ផ្លូវកណ្តាល" ដែលបំពេញគោលដៅ ទាំងខាងការពង្រឹងប្រសិទ្ធភាព និងសមធម៌ ឱ្យបានពេញលេញ នៅក្នុងក្របខ័ណ្ឌសង្គម វប្បធម៌ និងនយោបាយ បានក្លាយជាប្រធានបទ នៅក្នុងរបៀបវារៈនៃប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើន។

ដោយផ្អែកលើការប្រៀបធៀបប្រាក់ចំណូលជាមធ្យមសម្រាប់បុគ្គលម្នាក់ៗ ប្រទេសកម្ពុជាត្រូវបានមើលឃើញជាអន្តរជាតិ ថាជាប្រទេសមួយក្នុងចំណោមប្រទេសក្រីក្រជាងគេនៅលើពិភពលោក។ ប្រការនេះបានបង្ហាញយ៉ាងច្បាស់លាស់នៅក្នុងស្ថិតិ។ ទោះជាយ៉ាងណាក៏ដោយ ការផ្អែកលើទស្សនទានអំពីវត្តមានធនធានធម្មជាតិជាមធ្យមសម្រាប់មនុស្សម្នាក់ៗ ដូចជា ដីធ្លី ធនធានជលផល ជាពិសេស ត្រី និងព្រៃឈើ កម្ពុជាគឺពិតជាប្រទេសមួយក្នុងចំណោមប្រទេសដែលមានសម្បត្តិស្តុកស្តម្ភជាងគេនៅអាស៊ី។ បម្លែងតួលេខមធ្យមតាមការវិភាគបែបនេះ អំពីធនធានធម្មជាតិសម្រាប់មនុស្សម្នាក់ៗ ទៅជាសិទ្ធិប្រើប្រាស់ដោយសមធម៌ និងសុខុមាលភាពសម្រាប់ប្រជាពលរដ្ឋភាគច្រើន គឺជាការលំបាកយ៉ាងខ្លាំងណាស់សម្រាប់រដ្ឋ និងប្រជាជនកម្ពុជា។ ការប្រឈមដើម្បីសម្រេចគោលដៅនេះ ទាក់ទងនឹងធនធានជលផល ដែលមានតម្លៃបំផុតនៅក្នុងប្រទេស ជាពិសេស ត្រីនៅក្នុងដែនទេសាទទឹកសាប គឺជាការយកចិត្តទុកដាក់នៃឯកសារនេះ។

យើងឱ្យឈ្មោះកិច្ចប្រឹងប្រែងនានាក្នុងការគ្រប់គ្រងធនធានវារិជាតិ ដែលបានលាតត្រដាងនៅក្នុងប្រទេសកម្ពុជា ថាជា កំណែទម្រង់វិស័យជលផល។ មានមូលហេតុផ្សេងគ្នាមួយចំនួន ដែលនាំឱ្យយើងឯកភាពប្រើប្រាស់ពាក្យថា កំណែទម្រង់ជលផល។ កំណែទម្រង់នេះមានបរិបទជាប្រវត្តិសាស្ត្ររបស់ខ្លួន។ កាលពីអតីតកាល អន្តរាគមន៍របស់រដ្ឋាភិបាលនៅក្នុងវិស័យនេះបានផ្តោតលើការប្រមូលប្រាក់ចំណូល ជាងលើការគ្រប់គ្រងផលិតផលនេសាទ ឬការលើកកំពស់ជីវភាពរស់នៅ។ នៅក្នុងដំណាក់កាលបច្ចុប្បន្ននៃកំណែទម្រង់នេះ ការយកចិត្តទុកដាក់បានផ្តោតលើការកែប្រែស្ថាប័ន ដែលរដ្ឋកំពុងអនុវត្តក្នុងពេលជាមួយគ្នា នូវកំណែទម្រង់ពីខាងលើ ហើយសហគមន៍ធ្វើកំណែទម្រង់ពីខាងក្រោម។ កំណែទម្រង់ទាំងនេះ មានបំណងដើម្បីផ្តល់សិទ្ធិអំណាច ដល់ប្រជាពលរដ្ឋធ្វើការបង្ហាញរួមគ្នាអំពី ទំនាក់ទំនងជាមួយទន្លេ បឹង ទំនាបលិចទឹកនៅក្នុងផ្ទៃប្រទេស និងធនធានជលផលដែលមាននៅក្នុងមជ្ឈដ្ឋានទាំងនោះ។ ទៅអនាគត កំណែទម្រង់គួរតែមានតួនាទីក្នុងការជួយសម្រួលឱ្យប្រជាពលរដ្ឋធ្វើការជ្រើសយកបច្ចេកវិទ្យា និងធ្វើសេចក្តីសម្រេចលើការងារចាត់ចែងដើម្បីឱ្យចំណាត់ការរួមគ្នារបស់ប្រជាពលរដ្ឋទាំងនោះ ផ្តល់កំណើនសេដ្ឋកិច្ចដោយចីរភាព។ ជាសង្ខេប យើងមានការព្រួយបារម្ភអំពីដំណើរការ ដែលមានលក្ខណៈឌីណាមិកនៃបម្លែងនេះ។ ការយកចិត្តទុកដាក់នៅទីនេះ មិនមែនផ្តោតទៅលើមច្ឆជាតិនោះទេ ប៉ុន្តែទៅលើវិសាលភាពទាំងមូលនៃដែននេសាទ និងទិដ្ឋភាពនៃការវិវត្តនៃទំនាក់ទំនង និងអន្តរាគមន៍របស់ប្រជាពលរដ្ឋជាមួយដែននេសាទ និងនៅក្នុងដែននេសាទ។ ចំណុចដែលនៅពុំទាន់ដាច់ស្រេចស្ថិតនៅត្រង់ថាលក្ខខណ្ឌដំបូងនៃកត្តាអេកូឡូស៊ី និងសេដ្ឋកិច្ច-សង្គមមានឥទ្ធិពលទៅលើកាលៈទេសៈនៃការវិវត្តទាំងនេះ។ ត្រូវពិចារណាអំពីលំនាំនៃការផ្លាស់ប្តូរខាងស្ថាប័នដែលកំពុងត្រូវបានដាក់ឱ្យអនុវត្តនាពេលបច្ចុប្បន្ន និងដែលគ្រោងទៅអនាគតដោយផ្អែកលើទស្សនទាននេះ។ កំណែទម្រង់វិស័យជលផល មានវិសាលភាពគ្របដណ្តប់ប្រការទាំងអស់នេះ។

> យើងប្រកាន់យកពាក្យថា កំណែទម្រង់វិស័យជលផល ដោយសារ យើងមានការព្រួយបារម្ភអំពីដំណើរការដែលមានលក្ខណៈឌីណាមិកនៃបម្លែងនេះ។ ការយកចិត្តទុកដាក់នៅទីនេះ មិនមែនផ្តោតទៅលើតែមច្ឆជាតិនោះទេ ប៉ុន្តែទៅលើវិសាលភាពទាំងមូលនៃដែននេសាទ និងទិដ្ឋភាពនៃការវិវត្តនៃទំនាក់ទំនង និងអន្តរាគមន៍របស់ប្រជាពលរដ្ឋជាមួយដែននេសាទ និងនៅក្នុងដែននេសាទ។

ការស្រាវជ្រាវជាច្រើនក៏បានអនុវត្តរួចមកហើយដែរអំពីកំណែទម្រង់ទាំងនេះ តាំងពីមុនពេលដែលមានអនុម័តជាផ្លូវការនូវអនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍នេសាទទៅទៀត។ កិច្ចប្រឹងប្រែងរបស់យើងនឹងផ្អែកលើព័ត៌មានដែលមានស្រាប់ទាំងនោះ និងការពិភាក្សានាពេលថ្មីៗនេះ (នៅចុងឆ្នាំ ២០០៥) ជាមួយមន្ត្រីជលផល និងអ្នកស្រាវជ្រាវ និងការធ្វើទស្សនកិច្ចតាមទីតាំងក្នុងមូលដ្ឋាននៃខេត្តមួយចំនួនដើម្បីប្រមូលយកព័ត៌មានដំបូងពីស្ត្រី និងបុរសនៅក្នុងភូមិនានាដែលទទួលឥទ្ធិពលខ្លាំងគ្នាជាងគេពីកំណែទម្រង់ទាំងនេះ។ ឯកសារនេះបកស្រាយជាបឋមអំពីអ្នកដើរតួនានា ដែលទាក់ទងនឹងកំណែទម្រង់វិស័យជលផលនៅក្នុងប្រទេសកម្ពុជា។ ឯកសារនេះព្យាយាមផ្តល់ឱ្យអ្នកទាំងនោះ នូវការណែនាំខ្លះៗអំពីបញ្ហានានាដែលអាចកើតឡើង ប្រសិនបើអ្នកទាំងនោះត្រូវធ្វើការសម្រេចដោយខ្លួនឯងអំពីកំណែទម្រង់នេះ។

គោលបំណងចំបងនៃឯកសារនេះ គឺផ្ដល់នូវកិច្ចប្រឹងប្រែងតូចមួយដើម្បីគូសបញ្ជាក់អំពីការប្រឈមនានា ដែលកំពុងកើតឡើងនៅក្នុងដំណាក់កាលបច្ចុប្បន្ននៃកំណែទម្រង់វិស័យជលផល។ ការប្រឈមទាំងនោះរួមមានវិសាលភាពនៃកំណែទម្រង់ស្ថាប័ន និងគោលនយោបាយ ចំណាត់ការនៅមូលដ្ឋាន ការច្នៃប្រឌិត និងការស្រាវជ្រាវ។ យើងបង្ហាញអំពីកិច្ចប្រឹងប្រែងរបស់យើងដោយចាប់ផ្ដើមពីការវាយតម្លៃអំពីសារៈសំខាន់នៃធនធានជលផល និងផ្ដល់ព័ត៌មានសង្ខេបអំពីប្រវត្តិដើមនៃកំណែទម្រង់នេះ។ បន្ទាប់មក មានការពិនិត្យមើលការផ្លាស់ប្ដូរអំពីសិទ្ធិនៃការប្រើប្រាស់ និងសិទ្ធិលើកម្មសិទ្ធិ ព្រមទាំងអំពីការផ្លាស់ប្ដូរនៃប្រព័ន្ធ ដែលត្រូវបានបង្កើតឡើងដោយសារកំណែទម្រង់នេះ។ លើសពីនេះ ក៏មានការលើកឡើងផងដែរអំពី ថាតើអាចធ្វើការវាយតម្លៃបែបណាអំពីការផ្លាស់ប្ដូរនៅក្នុងអន្តរកាលនេះ និងអំពីថាតើសហគមន៍នេសាទអាចផ្ដល់កិច្ចប្រឹងប្រែងបែបណា ដើម្បីលើកកំពស់ស្ថានភាពសេដ្ឋកិច្ច និងសង្គម ។ យើងក៏លើកឡើងផងដែរ អំពីបញ្ហាសាំញ៉ាំ អំពីអត្តសញ្ញាណសង្គម និងការប៉ងប្រាថ្នា ដើម្បីបង្កើតឱ្យមានគំនិតថ្មីក្នុងការអនុវត្តការងារតាមបែបសហគមន៍។ តួនាទីថ្មីរបស់ស្ត្រី សារៈសំខាន់នៃការបង្កើតបណ្ដាញការងារ និងកិច្ចសហការកាន់តែជិតស្និទ្ធជាមួយរចនាសម្ព័ន្ធអភិបាលកិច្ចមូលដ្ឋាននៃប្រទេសកម្ពុជា និងភាពរស់រវើកនៃការចាត់ចែងសង្គមស៊ីវិលក៏មានគូសបញ្ជាក់នៅទីនេះផងដែរ។ កំណែទម្រង់បានបង្កើតបរិបទថ្មីខាងផ្នែកច្បាប់សម្រាប់ប្រព័ន្ធអេកូឡូស៊ីតូចៗ និងអភិបាលកិច្ចធនធាននៅកម្រិតមូលដ្ឋាន ។ ប៉ុន្តែ ការធ្វើបែបនេះនឹងមិនបង្វែរការយកចិត្តទុកដាក់ចេញពីតម្រូវការឱ្យមានការយល់ដឹងអំពីបរិបទធំទូលាយ "ជាសកល" នោះឡើយ ទោះបីការយល់ដឹងនេះ ទាក់ទងនឹងលក្ខណៈឌីណាមិកនៃប្រព័ន្ធអេកូឡូស៊ី ឬអាទិភាពនានានៃអភិបាលកិច្ចក៏ដោយ។ យើងស្នើឱ្យមានការពិនិត្យឡើងវិញ អំពីអាទិភាពនៃការស្រាវជ្រាវ និងអភិវឌ្ឍន៍ ដើម្បីធ្វើការពិចារណាវិធីនានា ដែលវែកញែកអំពី "ស្ថានភាពជាក់ស្ដែង នៅមូលដ្ឋាន" ដែលកើតមានថ្មីៗ និងវិវត្ត និងបង្ហាញពីទំនាក់ទំនងទន្ទឹមគ្នានេះជាមួយស្ថានភាពដែលកើតមាននៅក្នុងបរិបទធំទូលាយនៅ "កម្រិតពិភពលោក"។ ផ្នែកចុងក្រោយការបកស្រាយរបស់យើង មានភ្ជាប់ជាមួយនូវអនុសាសន៍នានា សម្រាប់អ្នកដើរតួខុសៗគ្នា ដែលពាក់ព័ន្ធនៅក្នុងដំណើរការធ្វើកំណែទម្រង់ការគ្រប់គ្រងវារិជាត។ នេះជាការអំពាវនាវឱ្យមានបេសកកម្មថ្មី និងកិច្ចសហការកាន់តែច្រើនឡើង ពីសំណាក់គ្រឹះស្ថានស្រាវជ្រាវ វិធីសាស្ត្រថ្មីៗសម្រាប់ការប្រមូលទិន្នន័យ ការចូលរួមកាន់តែច្រើនឡើងជាមួយរចនាសម្ព័ន្ធអភិបាលកិច្ចមូលដ្ឋាន យុទ្ធសាស្ត្រសម្រាប់ទីភ្នាក់ងារផ្ដល់ជំនួយនៅពេលបញ្ចប់ការគាំទ្រ និងអំពីតម្រូវការឱ្យបង្កើតវិទ្យាស្ថានជាតិសម្រាប់ដាក់ឱ្យអនុវត្តនិងបណ្ដុះបណ្ដាលអំពីសហគ្រប់គ្រង។

## ១. ការប្រែប្រួលនៃដែនទឹក និងធនធាន

ដែនទឹកដ៏ធំទូលាយនៃប្រទេសកម្ពុជា គឺជាផ្នែកមួយនៃអាងទន្លេមេគង្គ។ មជ្ឈដ្ឋាននេះគឺជាប្រព័ន្ធអេកូឡូស៊ីមួយ ក្នុងចំណោមប្រព័ន្ធអេកូឡូស៊ីនានាដែលមានលក្ខណៈពិសេសបំផុតនៅលើផែនដីយើងនេះ។ តំបន់ទំនាបលិចទឹកទន្លេមេគង្គ លាតសន្ធឹងលើវិសាលភាពទំហំ ៧០.០០០ គ.ម[២] ហើយប្រទេសកម្ពុជាមានចំណែកធំជាងគេនៃទំនាបលិចទឹកនេះ។ នៅចំបេះដូងនៃទំនាបលិចទឹកនេះ គឺបឹងទន្លេសាប ដែលជាបឹងទឹកសាបធំជាងគេបំផុតនៅអាស៊ីអាគ្នេយ៍ និងជាដែនទឹកសាបដែលមានផលិតភាពខ្ពស់ ប្រកបដោយជីវៈចម្រុះសំបូរបែបជាងគេនៅលើពិភពលោក (Baran, 2005) ។ ទឹកបឹងទន្លេសាបហូរតាមដងទន្លេសាប មកជួបជាមួយ

ទន្លេមេគង្គនៅត្រង់ភ្នំពេញ។ នៅរដូវដែលទឹកជំនន់មានកំពស់អតិបរមា ចាប់ពីខែមិថុនា ដល់ខែ កញ្ញា របបខ្យល់មូសុងប្រចាំរដូវ បានធ្វើឱ្យទន្លេមេគង្គ និងដៃរបស់ទន្លេនេះ មានទឹកពេញហៀរច្រាំង។ បរិមាណទឹកដ៏ច្រើនដែលហូរគំហុកបែបនេះ បានធ្វើឱ្យទឹកទន្លេសាប ហូរច្រាសទៅបឹងទន្លេសាបវិញ ជាហេតុធ្វើឱ្យលិចលង់តំបន់*យ៉ាងធំ* ដែលមានព្រៃ និងវាលស្មៅនៅទូទាំងប្រទេស។ នៅពេល បាតុភូតនេះកើតឡើង បឹងទន្លេសាប ដែលបច្ចុប្បន្នត្រូវបានកំណត់ជាជីវមណ្ឌល នៅក្រោមកម្មវិធីរបស់អង្គការយូណេស្កូ បានកើនវិសាលភាពពី ២៥០០ គ.ម$^{2}$ រហូតដល់ ១៦.០០០ គ.ម$^{2}$ ឬត្រូវជាប្រមាណ ៧ភាគរយនៃផ្ទៃដីប្រទេសកម្ពុជាទាំងមូល។

> បឹងទន្លេសាប គឺជាបឹងទឹកសាបធំជាងគេបំផុតនៅអាស៊ីអាគ្នេយ៍ និងជាដែនទឹកសាបដែលមានផលិតភាពខ្ពស់ ប្រកបដោយជីវៈចម្រុះសំបូរបែបជាងគេនៅលើពិភពលោក ។

វាលទំនាបលិចទឹកនេះ មានវិសាលភាពធំទូលាយទំហំ ៤០.០០០គ.ម$^{2}$ ឬត្រូវជា ២២ភាគរយ នៃផ្ទៃដីប្រទេសកម្ពុជាទាំងមូល។ តំបន់នេះ រួមមាន តំបន់ព្រៃលិចទឹកទំហំ ២២.០០០គ.ម$^{2}$ និងតំបន់ដីសើម ១៨.០០០ គ.ម$^{2}$ (So Nam & Bouy Roitana, 2005) ។ តំបន់នេះមានសារៈសំខាន់ណាស់ សម្រាប់ការជ្រកកោណរបស់ត្រីនៅរដូវប្រាំង។ ប្រការគួរឱ្យកត់សំគាល់គឺ អន្លង់ជ្រៅៗ នៅតាមដងទន្លេមេគង្គ (ជ្រៅបំផុតប្រមាណ ៨០ ម) និងដៃនានានៃទន្លេនេះនៅតំបន់ខ្សែទឹកខាងលើ។ ដែនទឹកទាំងនេះ និងទំនាបលិចទឹក ដែលបង្កើតឡើងដោយសារការប្រែប្រួលនៃវិសាលភាពដែនទឹក ដែលមានលក្ខណៈដោយឡែកបែបនេះ ផ្តល់ឱ្យប្រជាពលរដ្ឋប្រមាណ ៤ លាននាក់ ដែលរស់នៅជុំវិញតំបន់ទាំងនេះ នូវធនធាន និងសេវាប្រព័ន្ធអេកូឡូស៊ីជាច្រើនបែប (ADB, 2005) ។ ធនធាន និងសេវាទាំងនោះ រួមមាន ត្រី វារីរុក្ខជាតិ ដីប្រកបដោយជីជាតិសម្រាប់ធ្វើកសិកម្ម អុស កន្លែងពងកូននៃសារព័ន្ធវារីសត្វ និងជាមធ្យោបាយសម្រាប់ការដឹកជញ្ជូន និងមានច្រើនជាងនេះទៅទៀត។ ផ្ទាំងចម្លាក់នៅតាមជញ្ជាំងប្រាសាទអង្គរវត្តផ្តល់ជាភស្តុតាងថា ការប្រែប្រួលនៃវិសាលភាពដែនទឹកនេះបានផ្តល់នូវភាពសំបូរដែលគ្មានព្រំដែនដល់ប្រជាជនខ្មែរតាំងពីបុរាណសម័យមកម្លេះ។

ផលនេសាទទឹកសាបនៃប្រទេសកម្ពុជា ស្ថិតក្នុងចំណោមផលនេសាទដែលមានបរិមាណច្រើន និងមានសារៈសំខាន់បំផុតនៅក្នុងពិភពលោក។ ត្រីដែលមានចំនួនជិត ៥០០ ប្រភេទ ត្រូវបាននេសាទដោយប្រើប្រាស់ឧបករណ៍នេសាទយ៉ាងហោចណាស់ចំនួន ១៧០ បែប។ ផលនេសាទត្រូវបានប៉ាន់ប្រមាណកម្រិតទាបបំផុតក្នុងរវាង ២៥០.០០០ និង ៤០០.០០០ តោន ក្នុងមួយឆ្នាំ ដែលមានតម្លៃ ៣០០ លានដុល្លារអាមេរិក[1] ហើយផលនេសាទ និងវារីសត្វដទៃទៀត ដូចជា កំពឹស ក្តាម ខ្យង កង្កែប សត្វល្អិត ពស់ និងអណ្តើក រួមគ្នាមានយ៉ាងហោចណាស់ ៦០.០០០តោន ក្នុងមួយឆ្នាំ (Hortle et al., 2004)។ ផលនេសាទទឹកសាបរួមចំណែកច្រើនជាង ៧៥ ភាគរយនៃផលនេសាទសរុប។ ប្រជាពលរដ្ឋចំនួនប្រហែលបួនលាននាក់ ឬត្រូវជា ២៩ ភាគរយនៃចំនួន

[1] ដែនទឹកមានវិសាលភាពធំទូលាយ និងប្រែប្រួល។ ធនធានមានជីវិតមានភាពសំបូរបែប ហើយភាគច្រើនមានតម្លៃសម្រាប់ការប្រើប្រាស់ផ្ទាល់ ដែលនៅពុំទាន់បានឆ្លុះបញ្ចាំងនៅក្នុងទិន្នន័យស្ថិតិនៅថ្នាក់ជាតិ ឬ ក្នុងស្ថិតិតាមវិស័យឡើយ។ ការរួមចំណែកនៃធនធានទាំងនេះចំពោះអាហារូបត្ថម្ភ និងសុខុមាលភាព ពិតជាមានទំហំធំធេងណាស់។ ប៉ុន្តែ មកទល់បច្ចុប្បន្ន នៅពុំទាន់មានការព្យាយាមវាយតម្លៃឱ្យបានសមស្របអំពីសារៈសំខាន់នៃធនធានទាំងនេះនៅឡើយទេ។

ប្រជាពលរដ្ឋនៅទូទាំងប្រទេស[2] មានការងារធ្វើដែលទាក់ទងនឹងសកម្មភាពនេសាទ ហើយត្រី និងស្រូវនៅតែជាអាហារចាំបាច់ចំបងរបស់ប្រជាពលរដ្ឋ។ ត្រី និងវារីសត្វដទៃទៀតមានសារៈសំខាន់ណាស់ សម្រាប់ផ្តល់នូវអាហារូបត្ថម្ភ និងសន្តិសុខស្បៀង ព្រោះថា សាច់ត្រីបានផ្តល់នូវប្រូតេអ៊ីនច្រើនជាងបីភាគបួននៃប្រូតេអ៊ីននៅក្នុងរបបអាហារមានប្រភពពីជាតិសាច់ដែលប្រជាជនកម្ពុជាទទួលទាន។ ធនធានទាំងនេះក៏រួមចំណែកផងដែរក្នុងការផ្តល់វីតាមីន និងសារធាតុរ៉ែសំខាន់ៗ ជាពិសេស កាល់ស្យូម និងជីវជាតិអា ក៏ដូចជាសារធាតុខ្លាញ់ផងដែរនៅក្នុងរបបអាហារ ។ គិតជាមធ្យម ប្រជាពលរដ្ឋកម្ពុជាត្រូវបានចាត់ទុកថាជាអ្នកដែលបានបរិភោគត្រីច្រើនជាងគេនៅលើពិភពលោក ។ ការប៉ាន់ប្រមាណតាមរយៈការអង្កេតតាមផ្ទះបង្ហាញថា អត្រានៃការបរិភោគត្រី មាន ៦៥ គ.ក្រ ក្នុងមនុស្សម្នាក់ និងនៅក្នុងមួយឆ្នាំ (Hortle et al., 2004) ។ វិស័យជលផលនៃប្រទេសកម្ពុជាបានរួមចំណែកក្នុងរវាង ពី ៨ ទៅ ១២ ភាគរយ នៃផលទុនជាតិក្នុងស្រុកសរុប សម្រាប់ឆ្នាំ ២០០០-២០០៤ ។

> *ប្រជាពលរដ្ឋចំនួនប្រហែលបួនលាននាក់ ឬត្រូវជា ២៩ ភាគរយនៃចំនួនប្រជាពលរដ្ឋនៅទូទាំងប្រទេស មានការងារធ្វើ ដែលទាក់ទងនឹងសកម្មភាពនេសាទ ។*

ភាពសំបូរស្តុកស្តម្ភនៃធនធានធម្មជាតិទាំងនេះ បានធ្វើឱ្យមានការចាត់ទុកថា វិស័យជលផលមិនត្រឹមតែជាប្រភពតែមួយគត់នៃម្ហូបអាហារ និងការចិញ្ចឹមជីវិតតែប៉ុណ្ណោះទេ ប៉ុន្តែក៏ជាមធ្យោបាយងាយស្រួលសម្រាប់ការរកប្រាក់ចំណូលសម្រាប់រដ្ឋផងដែរ[3]។ ទន្លេ បឹង ទំនាបលិចទឹក តំបន់ជីសើម និងព្រៃឈើទាំងនេះ មានឥទ្ធិពលយ៉ាងខ្លាំងទៅលើអត្តសញ្ញាណជាតិនៃប្រជាជនកម្ពុជា មុខម្ហូបដែលជាទីនិយម និងជម្រើសក្នុងការចិញ្ចឹមជីវិត។ រូបិយប័ណ្ណនៅក្នុងប្រទេស (ប្រាក់រៀល) ប្រហែលជាត្រូវបានយកឈ្មោះតាមលំនាំនៃឈ្មោះត្រីមួយប្រភេទដែលសំបូរបំផុត គឺ *ត្រីរៀល* ដែលជាសញ្ញាអំពីសារៈសំខាន់ជាប្រពៃណីនៃត្រីប្រភេទនេះចំពោះសេដ្ឋកិច្ចជាតិ។ សុភាសិតខ្មែរ "ទីណាមានទឹក ទីនោះមានត្រី ។ ការថែរក្សាទឹក និងត្រី គឺជាការថែរក្សាខ្លួនឯង" ផ្តល់ខ្លឹមសារដែលមានរួមបញ្ចូលមូលធនដ៏ច្រើននៃចំណេះដឹងប្រពៃណីអំពីអេកូឡូស៊ី (Kurien, 1998) ។ សុភាសិតនេះជាការបូកបញ្ចូលនូវអ្វីដែលអ្នកជំនាញការបច្ចុប្បន្នចាត់ទុកថាជាគោលការណ៍គ្រប់គ្រង ដែលជាមូលដ្ឋានគ្រឹះសំខាន់បំផុត សម្រាប់ប្រព័ន្ធអេកូឡូស៊ីនៃតំបន់ទំនាបលិចទឹកណាមួយ ពោលគឺការគ្រប់គ្រងលំហូរទឹក និងការថែរក្សាគុណភាពទឹក (FAO, 1996, 1997) ។

---

[2] បានទទួលពីការប្រាស្រ័យទាក់ទងដោយផ្ទាល់មាត់ជាមួយលោក ណៅ ធួក អគ្គនាយក នៃនាយកដ្ឋានជលផល ព្រះរាជាណាចក្រកម្ពុជា ខែ តុលា ឆ្នាំ ១៩៩៩ ។

[3] យោងតាមវិទ្យាស្ថានជាតិស្ថិតិនៃប្រទេសកម្ពុជា ផលិតផលពីវិស័យជលផល (ទាំងផលពីដែននេសាទទឹកសាប និងសមុទ្រ) មានតម្លៃ ១៩២៤.០០០ លានរៀល (តាមថ្លៃបច្ចុប្បន្ន) នៅក្នុងឆ្នាំ ២០០៤ ដែលត្រូវជា ៤៦៩ លានដុល្លារអាមេរិក។ ចំនួននេះបានកើនឡើងពី ១៥១៥.០០០ លានរៀល (៣៨៤ លានដុល្លារអាមេរិក) នៅឆ្នាំ ២០០០។ ផលនេសាទបានរួមចំណែក ៣១ភាគរយនៃផលទុនក្នុងស្រុកសរុបពីវិស័យបឋម នៅក្នុងឆ្នាំ ២០០៤។ តួលេខនេះបានកើនពី ២៩ ភាគរយនៅក្នុងឆ្នាំ ២០០០។

## ២. កំណែទម្រង់វិស័យជលផល : ប្រវត្តិដើមខ្លះៗ

ទោះបីស្ថានភាពធម្មជាតិភាគច្រើនក្នុងប្រទេសកម្ពុជា នៅពុំទាន់ផ្លាស់ប្តូរនៅឡើយក្តី គេមិនអាចនិយាយបានដូចគ្នានេះទេ អំពីកត្តាសេដ្ឋកិច្ច សង្គម-វប្បធម៌ និងនយោបាយ។ នេះជាការពិតនៅក្នុងរយៈពេលពាក់កណ្តាលសតវត្សរ៍ចុងក្រោយនេះ។ ការផ្លាស់ប្តូរជាសំខាន់មួយក្នុងចំណោមការផ្លាស់ប្តូរនានានៅក្នុងអំឡុងពេលនេះ គឺទៅលើវិធីដែលរដ្ឋបានធ្វើការផ្លាស់ប្តូររបៀបដែលប្រជាពលរដ្ឋទាក់ទងជាមួយធនធានធម្មជាតិនៃប្រទេសនេះ។ លទ្ធភាពក្នុងការប្រើប្រាស់ដែនទឹកត្រូវបានរៀបចំ កែទម្រង់ និងចេញជាបទប្បញ្ញត្តិជាបន្តបន្ទាប់។ ដំណើរការនេះបន្តរហូតមកដល់បច្ចុប្បន្ន ហើយទំនងជាមានឥទ្ធិពលទៅអនាគតផងដែរ។

នៅចំណុចស្នូលនៃកិច្ចប្រឹងប្រែងដើម្បីត្រួតពិនិត្យ និងគ្រប់គ្រងការនេសាទទឹកសាបក្នុងប្រទេសកម្ពុជា គឺឡូត៍នេសាទដែលមានប្រវត្តិជាយូរលង់មកហើយ (សូមអានប្រអប់ទី ១)។ ឡូត៍នេសាទគឺជាផ្នែកដែលមានការចាត់ចែងបានម៉ត់ចត់ជាងគេនៅក្នុងវិស័យនេសាទទាំងមូល និងបានផ្តល់ជាប្រភពចំបងនៃប្រាក់ចំណូលរបស់រដ្ឋ។ ឡូត៍នេសាទត្រូវបានដាក់ឱ្យដំណើរការ ដោយការធ្វើសម្បទានរបស់រដ្ឋសម្រាប់រយៈពេលពីរឆ្នាំម្តង តាមរយៈការដេញថ្លៃជាសាធារណៈ ដែលមិនសុទ្ធតែជាការចាត់ចែងដែលមានតម្លាភាពនោះឡើយ។ នាយកដ្ឋានជលផលប្រគល់សិទ្ធិដល់បុគ្គលណាដែលបានឱ្យថ្លៃខ្ពស់ជាងគេនៅក្នុងការដេញថ្លៃ។ ការប្រកួតប្រជែងនៅពេលដេញថ្លៃបានធ្វើឱ្យថ្លៃឈ្នួលឡូត៍កើនឡើងដែលមិនអាចឱ្យអ្នកពីក្រៅចូលប្រកួតបាន ប៉ុន្តែមានតែមួយភាគនៃថ្លៃដែលដេញបានតែប៉ុណ្ណោះដែលតែត្រូវបានបង់ (Degen et al, 2000)។ អ្នកដេញថ្លៃបាន មានសិទ្ធផ្តាច់មុខលើដែននេសាទដែលបានកំណត់ជាក់លាក់នៅក្នុងតំបន់ទំនាបលិចទឹក។ ឡូត៍នេសាទនីមួយៗមាន "សៀវភៅបន្ទុក" ដែលចែងអំពីសិទ្ធិ និងកាតព្វកិច្ចរបស់ភាគីដែលកាន់កាប់ឡូត៍នេសាទ។ នៅក្នុងសៀវភៅនេះមានចែងអំពីចំណុចលំអិតជាក់លាក់អំពីវិសាលភាពនៃឡូត៍នេសាទនោះ ពេលវេលានៃរដូវបើក និងបិទនេសាទ ប្រភេទឧបករណ៍នេសាទដែលអាចអនុញ្ញាតឱ្យប្រើប្រាស់ ទីកន្លែងនៅក្នុងឡូត៍នេសាទដែលត្រូវរក្សាជាកន្លែងបម្រុងទុក និងទីកន្លែងដែលអនុញ្ញាតឱ្យសហគមន៍មូលដ្ឋានធ្វើនេសាទសម្រាប់តែផ្គត់ផ្គង់ជីវភាពគ្រួសារ។ ឡូត៍នេសាទលាតសន្ធឹងលើវិសាលភាពប្រមាណ ១០.០០០ត.ម$^{២}$ នៃកន្លែងដែលមានផលិតភាពខ្ពស់ និងជាដែននេសាទដែលសំបូរត្រី។ ត្រីដែលបាននេសាទក្នុងបរិមាណដ៏ច្រើនពីឡូត៍នានា ត្រូវបានផ្គត់ផ្គង់ទៅប្រជាពលរដ្ឋទូទៅនៅក្នុងប្រទេសពោលគឺមិនមែន សម្រាប់តែប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់ទំនាបលិចទឹកនេះតែប៉ុណ្ណោះទេ។

នៅក្នុងអំឡុងទសវត្សរ៍ឆ្នាំ ១៩៩០ វិស័យនេសាទទឹកសាបក្នុងប្រទេសកម្ពុជាត្រូវបានគ្រប់គ្រងតាមវិធីដែលបានរួមចំណែកតិចតួចនៅក្នុងការកាត់បន្ថយភាពក្រីក្រ និងមានការយកចិត្តទុកដាក់តិចតួចប៉ុណ្ណោះអំពីបរិស្ថាន។ ភាគច្រើននៃផលចំណេញត្រូវបានជាប្រយោជន៍នៃក្រុមជនដែលមានឥទ្ធិពលមួយចំនួនតូចតែប៉ុណ្ណោះ (Tarr 2002, Degen 2000)។ វិសាលភាពរបវិន្តនៃឡូត៍នេសាទ វត្តមានរបស់សហគមន៍នៅក្នុងតំបន់នោះ និងផលិតភាពដ៏ខ្ពស់នៃប្រព័ន្ធទាំងនេះបានធ្វើឱ្យឡូត៍នេសាទមិនគ្រាន់តែក្លាយជាកន្លែងពងកូនសម្រាប់ត្រីប៉ុណ្ណោះទេ ប៉ុន្តែក៏ជាប្រភពនៃទំនាស់សង្គមផងដែរ។ នៅក្រោយទសវត្សរ៍ឆ្នាំ ១៩៩០

ជាធម្មតា ម្ចាស់ឡូត៍នេសាទបានជួលឡូត៍នេសាទជាបន្ត ដើម្បីអាចប្រមូលមកវិញនូវទឹកប្រាក់ដែលបានបង់ទៅឱ្យរដ្ឋាភិបាល។ នៅក្នុងករណីមួយចំនួន ឡូត៍នេសាទមានទំហំធំពេកដែលពុំអាចគ្រប់គ្រងទាំងមូលបាន។ ដោយសារការវិនិយោគមានទំហំធំដើម្បីចំណាយលើប្រព័ន្ធសម្រាប់ចាប់ត្រី ឡូត៍នេសាទក៏ត្រូវបានការពារយ៉ាងម៉ត់ចត់ទល់នឹងការចូលលួចនេសាទដោយប្រើប្រាស់ឆ្មាំឯកជនប្រដាប់ដោយអាវុធ ។ប្រមាណ៨០ភាគរយនៃតំបន់មាត់បឹងទន្លេសាបត្រូវបានដាក់ឱ្យស្ថិតក្រោមការគ្រប់គ្រងរបស់ឡូត៍នេសាទចំនួន ១៨ (Evans, 2002) ។

**ប្រអប់ ១: ប្រវត្តិនៃឡូត៍នេសាទនៅក្នុងវិស័យជលផលនៃប្រទេសកម្ពុជា**

ប្រព័ន្ធឡូត៍នេសាទត្រូវបានដាក់ឱ្យប្រើប្រាស់ជាដំបូង ក្នុងប្រទេសកម្ពុជានៅចុងសតវត្សរ៍ទី ១៩ (ឆ្នាំ ១៨៦៣) ដែលជាប្រព័ន្ធមួយរបស់របបបរិបាលកិច្ចនៅក្រោមរាជព្រះបាទនរោត្តម។ ប្រាក់ចំណូលដែលទទួលបានពីវិស័យនេះ ត្រូវបានបង់ទៅឱ្យរដ្ឋបាលអាណាព្យាបាលបារាំងដែលប្រើប្រាស់សម្រាប់ទប់ស្កាត់ការឈ្លានពានពីប្រទេសសៀម។ ទោះជាយ៉ាងណាក៏ដោយ ប្រព័ន្ធនេះត្រូវបានបោះបង់ចោលនៅក្នុងឆ្នាំ ១៨៨៤ ដោយសារចលនារបស់កសិករដែលធ្វើការតស៊ូ ប្រឆាំងនឹងការរំលោភលើសិទ្ធិប្រើប្រាស់ធនធានរួមរបស់ពួកគេ។ ដោយចាប់អារម្មណ៍អំពីប្រការនេះ នៅពេលក្រោយមក ប្រព័ន្ធនេះត្រូវបានកែតម្រូវ និង បង្កើតឱ្យមានការទទួលស្គាល់ជាផ្លូវការដោយរដ្ឋបាលអាណាព្យាបាលបារាំង នៅក្នុងឆ្នាំ ១៩០៨។ អាជ្ញាធរបានតែងតាំងបុគ្គលិកដែលបានទទួលការបណ្តុះបណ្តាល ដាក់ឱ្យប្រើប្រាស់វិធានការគ្រប់គ្រង និងអភិរក្សតឹងរ៉ឹង និងបានអនុញ្ញាតឱ្យមានការគិតគូរអំពីផលប្រយោជន៍សង្គម ដើម្បីដោះស្រាយកង្វល់ខ្លះៗរបស់កសិករ (Touch 2005) ។ គួរកត់សំគាល់ផងដែរថា ការផ្លាស់ប្តូរនេះបានរួមបញ្ចូលធាតុចំនួនប្រាំដូចតទៅ: ការកំណត់រដូវបើកនេសាទ ការបង្កើតឡូត៍នេសាទបម្រុងទុក ការហាមឃាត់មិនឱ្យប្រើ-ប្រាស់ប្រភេទខ្លះៗនៃឧបករណ៍ និង សម្ភារៈនេសាទ ការពារសិទ្ធិខ្លះៗរបស់អ្នកភូមិនៅក្នុងមូលដ្ឋាន ក្នុងការចូលធ្វើនេសាទ (៧ភាគរយនៃវិសាលភាពដែននេសាទសរុបដែលបានដាក់សម្រាប់ការធ្វើសម្បទានទៅឱ្យឯកជន) និង ការបង្កើតវិទ្យាស្ថានស្រាវជ្រាវជលផល (Somony, 2002 ដកស្រង់ចេញពី Touch 2001) ។ ប្រាក់ចំណូលដែលទទួលបានពីប្រព័ន្ធដែលមានលក្ខណៈផ្លូវការជាងមុននេះ ត្រូវបានប្រើប្រាស់រហូតដល់ដើមទសវត្សរ៍ឆ្នាំ ១៩៥០ ដើម្បីអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ដូចជាផ្លូវថ្នល់ និងផ្លូវដែកសម្រាប់ប្រទេសកម្ពុជា (Touch ST, 2005) ។ ក្រោយបានទទួលឯករាជ្យនៅក្នុងឆ្នាំ ១៩៥៤ ក្របខ័ណ្ឌច្បាប់មួយសម្រាប់វិស័យនេសាទត្រូវបានបង្កើតឡើង តាមរយៈការដាក់ឱ្យប្រើប្រាស់ច្បាប់ជលផលនៅក្នុងឆ្នាំ ១៩៥៦។

នៅក្នុងដំណាក់កាលដើមដំបូង ក្រោយការទទួលបានឯករាជ្យ ទំនាស់អំពីប្រព័ន្ធឡូត៍នេសាទក៏បានកើនឡើងជាថ្មី។ ក្រុមអ្នកដែលមានអំណាច បានព្យាយាមដោះស្រាយបញ្ហាទាំងនេះ។ ជាដំបូង ពួកគេបានទទួលជោគជ័យ។ ប៉ុន្តែ ព្រះបាទនរោត្តមសីហនុ បានបញ្ជាឱ្យបញ្ឈប់ដំណើរការឡូត៍នេសាទមួយចំនួន។ នៅក្នុងទសវត្សរ៍ឆ្នាំ ១៩៦០ មានសេចក្តីរាយការណ៍ជាញឹកញាប់ អំពីករណីធ្វើឃាតម្ចាស់ឡូត៍ និងអ្នកចាត់ចែងឡូត៍នេសាទ នៅក្នុងជម្លោះជាមួយមន្ត្រីមូលដ្ឋាន និងអ្នកភូមិ (Tarr, 2002) ។ កម្លាំងនេះហើយដែលនៅពេលក្រោយមក ប្រហែលជាបានរួបរួមគ្នាជាមួយខ្មែរក្រហម ដើម្បីធ្វើឱ្យមានព្រឹត្តិការណ៍ទាំងនោះឡើង។ នៅឆ្នាំ ១៩៧៣ រដ្ឋបាលលោក លន់ ណុល បានហាមឃាត់ការធ្វើអាជីវកម្មឡូត៍នេសាទទាំងអស់ ហើយនៅក្នុងឆ្នាំ ១៩៧៥ ភាគច្រើននៃសកម្មភាពនេសាទក៏ត្រូវបោះបង់ចោលផងដែរ ក្រោយពេលដែលពួកខ្មែរក្រហមដណ្តើមបានអំណាច។ ពួកខ្មែរក្រហមបានជម្លៀសប្រជាជនចេញពីភូមិនេសាទ និងថែមទាំងបានព្យាយាមបម្លែងតំបន់ដីសើមឱ្យទៅជាវាលស្រែផងដែរ។ មិនដូចប្រជាពលរដ្ឋទេ ជាពិសេសអ្នកដែលមានដើមកំណើតជាជនជាតិវៀតណាម ត្រីនៅក្នុងបឹងទន្លេសាបមិនបានប្រឈមនឹងការគំរាមកំហែងពីពួកខ្មែរក្រហមឡើយ។ ផលស្តុកនៅក្នុងពេលនោះបានកើនឡើងរហូតដល់កម្រិតអតិបរមានៅក្នុងរបបនោះ (Tarr, 2002) ។

សកម្មភាពនេសាទបានរស់ឡើងវិញដោយរដ្ឋាភិបាលសង្គមនិយមនៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា និងដែលគាំទ្រដោយអតីតសហភាពសូវៀត នៅក្រោយការផ្តួលរំលំរបបខ្មែរក្រហមនៅក្នុងឆ្នាំ ១៩៧៩ ។ ដោយបន្តអនុវត្តតាមមាគ៌ានៃទ្រឹស្តីនេះ រដ្ឋាភិបាលបានព្យាយាមធ្វើឱ្យកម្មសិទ្ធិលើឡូត៍នេសាទមានលក្ខណៈសង្គមនិយមបំផុត ដោយបែងចែកឡូត៍នេសាទទៅឱ្យក្រុមសាមគ្គីដែលផ្សំដោយគ្រួសារអ្នកនេសាទ និងដែលហៅថា "ក្រុមសាមគ្គី" ។ រដ្ឋបានតម្រូវឱ្យបង់កម្រៃ (ពន្ធ) ក្រោមរូបភាពជាត្រីស្រស់ ឬត្រីប្រឡាក់ (Vibolrith, 2000) ។ នេះជាដំណាក់កាលមួយថ្មី ក្រោយរយៈពេលច្រើនជាងមួយសតវត្សរ៍ ដែលប្រជាជនត្រូវមានសិទ្ធិធ្វើនេសាទដោយសេរី នៅតាមគ្រប់ទីកន្លែង តាមដែលពួកគេចង់។ លើសពីនេះ នៅពេលនោះ ដែននេសាទទឹកសាបសំបូរត្រីណាស់ បន្ទាប់ពីមានសម្ពាធតិចតួចតែប៉ុណ្ណោះលើផលស្តុកនៅក្នុងរបបខ្មែរក្រហម (Degen et al 2000) ។ នៅក្នុងដំណាក់កាលនេះ ប្រជាជនជាច្រើនមកពីប្រទេសវៀតណាម ពិសេសអ្នកដែលមានជំនាញខាងការធ្វើនេសាទ បានចូលមកក្នុងប្រទេសកម្ពុជា។ អ្នកទាំងនោះជាច្រើនបានតាំងទីលំនៅក្នុងបឹងទន្លេសាប ដោយបង្កើតជាភូមិបណ្តែតទឹក ដោយសារពួកគេពុំមានកម្មសិទ្ធិដី។ នៅពាក់កណ្តាលទសវត្សរ៍ឆ្នាំ ១៩៨០ នៅពេលដែលរដ្ឋាភិបាលនៃអតីតសហភាពសូវៀតបានប្រឈមភាពវឹកវរ រដ្ឋាភិបាលត្រូវស្វែងរកមូលនិធិពីប្រភពផ្សេងដើម្បីដឹកនាំប្រទេស និងរក្សាទុកក្របខ័ណ្ឌគណបក្សរបស់ខ្លួន។ ប្រព័ន្ធឡូត៍នេសាទត្រូវបានមើលឃើញថាជាប្រភពដ៏សំខាន់ ដើម្បីសម្រេចគោលដៅទាំងពីរនេះ។

នៅឆ្នាំ ១៩៨៧ រដ្ឋាភិបាលកម្ពុជាបានដាក់ឱ្យប្រើប្រាស់ច្បាប់ស្តីពីការគ្រប់គ្រង និងរដ្ឋបាលជលផល លេខ ៣៣ ឆ្នាំ ១៩៨៧។ ច្បាប់នេះផ្អែកជាសំខាន់តាមគំរូនៃច្បាប់ជលផលឆ្នាំ ១៩៥៦។ ច្បាប់ថ្មីមានសុពលភាពទាំងលើការនេសាទទឹកសាប និងសមុទ្រ និងបានអនុវត្តទស្សនទានអំពីដែននេសាទ ទៅតាមគោលការណ៍ច្បាប់របស់បារាំង *ដែនសាធារណៈ* ពោលគឺសម្បត្តិរបស់រដ្ឋដែលមិនអាចយកធ្វើជាកម្មសិទ្ធិឯកជនបាន។ ច្បាប់នេះ បានបែងចែកដែននេសាទទឹកសាបបន្តជាបីក្រុមៈ ការនេសាទទ្រង់ទ្រាយធំ (ជាមូលដ្ឋានគឺ ឡូត៍នេសាទ ដែលត្រូវបានដាក់ឱ្យដេញថ្លៃ និងត្រូវបានហៅថាជាការនេសាទឧស្សាហកម្មផងដែរ) ការនេសាទខ្នាតមធ្យម (ប្រើប្រាស់ឧបករណ៍នេសាទ ដូចជា ម៉ាញ់ អួន ។ល។ ដែលត្រូវសុំលិខិតអនុញ្ញាតដើម្បីអាចធ្វើនេសាទ និងដែលហៅថាការនេសាទសិប្បកម្ម) និងការនេសាទទ្រង់ទ្រាយតូច (ឧបករណ៍តូចៗ ដូចជាសន្ទូចផ្លែមួយ សំណាញ់ និងមងខ្លីៗ និងត្រូវបានឱ្យឈ្មោះថា ការនេសាទជាលក្ខណៈគ្រួសារ) ។

អនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍នេសាទ ដែលត្រូវបានអនុម័តនៅក្នុងឆ្នាំ ២០០៥ បាននាំឱ្យមានសំណួរឡើងវិញ អំពីនិរន្តរភាពនៃប្រព័ន្ធឡូត៍នេសាទ។ ទោះជាយ៉ាងណាក៏ដោយ ប្រសិនបើប្រវត្តិសាស្ត្រជាអ្នកនាំមុខ បញ្ហានេះមិនមែនជាកិច្ចការដែលត្រូវចប់នោះទេ។

ក្នុងចន្លោះឆ្នាំ ១៩៩៥ និង ឆ្នាំ ១៩៩៩ ទំនាស់អំពីសិទ្ធិលើការនេសាទបានរីករាលដាលហួសពីការស្មាន ហើយទំនាស់ទាំងនោះ បានកើតឡើងក្រោមរូបភាពជាច្រើន។ ការសំដែងមតិបែបនេះបានកើតឡើង ដោយសាររដ្ឋធម្មនុញ្ញដែលនៅជាធរមាននៅក្រោយការបោះឆ្នោតដែលចាត់ចែងឡើងដោយអ៊ុនតាក់នៅក្នុងឆ្នាំ ១៩៩៣ បានចែងយ៉ាងច្បាស់លាស់អំពីសិទ្ធិជាច្រើនខាងស៊ីវិល និង នយោបាយ ដែលពុំធ្លាប់មានពីមុនមកនៅក្នុងប្រទេសកម្ពុជា។ ចំនួនអង្គការសង្គមស៊ីវិលធ្វើការខាងវិស័យសិទ្ធិមនុស្ស ទំនាក់ទំនងខាងយេនឌ័រ ការអភិវឌ្ឍ និងបរិស្ថាន បានកើនឡើងយ៉ាងឆាប់រហ័ស។ សហគមន៍ផ្តល់ជំនួយអន្តរជាតិក៏បានផ្តល់ការគាំទ្រចំពោះសកម្មភាពរបស់អង្គការទាំងនោះផងដែរ ដោយព្យាយាមធ្វើឱ្យមានការចូលរួមកាន់តែច្រើនឡើង ពីសំណាក់ប្រជាពលរដ្ឋនៅក្នុងដំណើរការអភិវឌ្ឍន៍។ ដោយបានទទួលការលើកទឹកចិត្តពីអង្គការសង្គមស៊ីវិលនានា សហគមន៍អ្នកនេសាទជាច្រើន [4] ហ៊ាន

[4] ប្រការសំខាន់គឺ គួរកត់សំគាល់ថា ប្រជាពលរដ្ឋទាំងអស់ដែលមានសកម្មភាពទាក់ទងនឹងឡូត៍នេសាទ កម្រនិយាយប្រឆាំងនឹងអំពើហឹង្សាណាស់។ ជនជាតិចាម និង ជនជាតិវៀតណាម ដែលពាក់ព័ន្ធច្រើនជាងប្រជាជនខ្មែរ នៅក្នុងការនេសាទ កម្រធ្លាក់ក្នុងជម្លោះជាមួយអាជ្ញាធរ ឬជាមួយម្ចាស់ឡូត៍នេសាទណាស់

សំដែងមតិរបស់ខ្លួនអំពីសិទ្ធិមនុស្ស ជាពិសេសក្នុងការប្រឆាំងនឹងអំពើអយុត្តិធម៌ ដែលប្រព្រឹត្តដោយអាជ្ញាធរ និងម្ចាស់ឡូត៍នេសាទ (Ratner, 2004) ។ ភស្តុតាងទាំងនេះក៏មានរាយការណ៍ជាទៀងទាត់នៅក្នុងសារព័ត៌មាននានាផងដែរ។ ការស៊ើបអង្កេតដែលធ្វើឡើងដោយអង្គការសង្គមស៊ីវិល បានគូសបញ្ជាក់អំពីការរីករាលដាលនៃបញ្ហាទាំងនេះ :

"ជម្លោះត្រូវបានបង្ហាញឱ្យឃើញអំពីភាពប្រកួតប្រជែងនៃការទាមទារសិទ្ធិប្រើប្រាស់ធនធានជលផល ដែលកើតចេញពីផលប្រយោជន៍ខាងពាណិជ្ជកម្ម កំណើនចំនួនប្រជាពលរដ្ឋដែលជាអ្នកនេសាទសម្រាប់តែផ្គត់ផ្គង់ការប្រើប្រាស់ក្នុងគ្រួសារ ការនេសាទល្មើសច្បាប់ និងតម្រូវការដីធ្លីសម្រាប់ធ្វើកសិកម្ម ទឹក និងអុស។ ទំនាស់បានកើតឡើង រវាងកម្មករឡូត៍នេសាទ អាជ្ញាធរមូលដ្ឋាន ទាហាន ប៉ូលីស និងសហគមន៍មូលដ្ឋាន និងបានលេចចេញជាបាតុកម្ម ការធ្វើញត្តិតវ៉ា "ការចូលលួចធ្វើនេសាទ" ការឃាត់ខ្លួន និង ការឃុំខ្លួនដើម្បីបង្ខំឱ្យធ្វើការ ការរឹបអូសឧបករណ៍នេសាទ និងសត្វចិញ្ចឹម (ដែលបានបង្កើតឱ្យមានផលវិបាកធ្ងន់ធ្ងរចំពោះអ្នកនេសាទក្រីក្រជាងគេ) ការបង្ករបួស ការរំលោភធ្ងន់ធ្ងរចំពោះសិទ្ធិមនុស្ស និង មានសេចក្តីរាយការណ៍អំពីការធ្វើឃាតអ្នកនេសាទ និងមន្ត្រីជលផលផងដែរ" (FACT/EJF, 2002: 24)។

នៅក្នុងស្ថានភាពនៃជម្លោះបែបនេះ គួរកត់សំគាល់ថា មានអ្នកសង្កេតការណ៍ប្រកបដោយការប្រុងប្រយ័ត្ន និងប្រកបដោយចំណេះដឹង អំពីទិដ្ឋភាពនៃការនេសាទក្នុងប្រទេសកម្ពុជា បានអះអាងថា រចនាសម្ព័ន្ធចាត់ចែង និងបច្ចេកវិទ្យានៃការគ្រប់គ្រងឡូត៍នេសាទ ពុំគួរជាគោលដៅនៃការលុបចោលនោះទេ។ ពួកគេចង់ឱ្យមានដំណោះស្រាយដែល :

"ត្រូវលើកឡើងអំពីករណីកែលំអការគ្រប់គ្រងការនេសាទនៅក្នុង និងតាមរយៈប្រព័ន្ធឡូត៍នេសាទ។ ការគ្រប់គ្រងផ្អែកលើសហគមន៍ ដូចដែលត្រូវបានមើលបង្ហាញនៅក្នុងចក្ខុវិស័យ អាចមិនដំណើរការទៅបាននៅក្នុងប្រទេសកម្ពុជាឡើយ។ ការរំពឹងទុកថា រចនាសម្ព័ន្ធគ្រប់គ្រងដែលផ្អែកលើសហគមន៍ ដែលបានទទួលជោគជ័យនៅកន្លែងដទៃ អាចនឹងយកមកប្រើប្រាស់នៅក្នុងប្រទេសកម្ពុជាដោយងាយស្រួល គឺជាការរំពឹងទុកដែលគ្មានលក្ខណៈប្រាកដនិយម។ គួរប្រើប្រាស់ប្រព័ន្ធឡូត៍នេសាទ ជាចំណុចចាប់ផ្តើម ដើម្បីដោះស្រាយបញ្ហាកម្មសិទ្ធិលើធនធាន។ អាទិភាពនៃដែននេសាទរួមនៅក្នុងឡូត៍នេសាទ ... អាចផ្តល់សក្តានុពលសម្រាប់ជាវេទិកាដ៏ល្អ ដើម្បីធ្វើការប្រាស្រ័យទាក់ទង និងការចរចា អំពីសិទ្ធិប្រើប្រាស់ និងការគ្រប់គ្រងធនធានដោយនិរន្តរភាព" (Degen & Thouk, 1999) ។

មតិពីរខុសគ្នា ដែលមតិមួយជំទាស់នឹងប្រព័ន្ធឡូត៍នេសាទ និងមតិមួយផ្សេងទៀតគាំទ្រការចាត់ចែងប្រព័ន្ធឡូត៍នេសាទ បានផ្តល់នូវកាលានុវត្តភាពដើម្បីចាត់ការតាមរូបភាពទីបី។ នៅរវាង ឆ្នាំ ១៩៩៤ និង ឆ្នាំ ១៩៩៨ មានកិច្ចផ្តួចផ្តើមមួយចំនួនដែលបានធ្វើឡើង ដោយអង្គការសង្គមស៊ីវិល និង ទីភ្នាក់ងារអន្តរជាតិ ដូចជា អង្គការ FAO/UN ដើម្បីផ្តួចផ្តើមឱ្យមានកិច្ចប្រឹង-ប្រែងឆ្ពោះទៅបង្កើតសហគ្រប់គ្រងការនេសាទនៅក្នុងតំបន់មួយចំនួននៃប្រទេសកម្ពុជា (Ly Vuthy, 2005) ។ កិច្ចប្រឹងប្រែង

---

(Degen and Thouk, 2000) ។ ជម្លោះមិនមែនសុទ្ធតែទាក់ទងនឹងសិទ្ធិធ្វើនេសាទតែប៉ុណ្ណោះទេ។ ដំណើរប្រព្រឹត្តរបស់ឡូត៍នេសាទ បានជះឥទ្ធិពលទៅលើសេរីភាព នៃសកម្មភាពរបស់កសិករខ្មែរក្រីក្រ ដែលប្រើប្រាស់ដីធ្លី និងទឹក សម្រាប់ធ្វើស្រែ ទាំងនៅរដូវវស្សា និងនៅរដូវប្រាំង (Tarr, 2002) ។

ទាំងនេះ ត្រូវបានផ្តួចផ្តើមឡើងដោយអង្គការទាំងនេះ ជាការឆ្លើយតបមួយចំណែកទៅនឹងចលនាទ្រង់ទ្រាយធំជាអន្តរជាតិ ឆ្ពោះទៅរកការគ្រប់គ្រងធនធានដោយផ្អែកលើសហគមន៍ និងបានគូសបញ្ជាក់អំពីវិធីដ៏មានប្រយោជន៍នៃការប្រើប្រាស់ និងគ្រប់គ្រងធនធានធម្មជាតិ។ វិធាននេះត្រូវបាននិយមចូលចិត្តដោយសារវាបានលើកទឹកចិត្តឱ្យមានការទទួលខុសត្រូវការតែច្រើនឡើងនៅថ្នាក់មូលដ្ឋាន ដែលនេះជាគន្លឹះសម្រាប់ធានានិរន្តរភាពធនធាន។ ទោះជាយ៉ាងណាក៏ដោយ នៅពុំទាន់មានកិច្ចប្រឹងប្រែងរួមគ្នានៅក្នុងដំណាក់កាលនេះនៅឡើយទេ ក្នុងការធ្វើឱ្យកិច្ចផ្តួចផ្តើមបែបនេះកើតមានឡើងនៅទូទាំងផ្ទៃប្រទេស។

ដោយសារការជំទាស់នឹងស្ថានភាពនៃទំនាស់ក្នុងសង្គម និងគំនិតផ្ទុយគ្នា អំពីដំណោះស្រាយក្នុងការគ្រប់គ្រងជលផលនេះហើយ ទើបនាយករដ្ឋមន្ត្រីបច្ចុប្បន្ន សម្តេច ហ៊ុន សែន បានចេញសេចក្តីប្រកាសនៅឆ្នាំ ១៩៩៩ ដើម្បីប្រឆាំងនឹងអ្វី ដែលត្រូវបានហៅថា "អនាធិបតេយ្យក្នុងវិស័យជលផល" (RGC, 1999) ។ រយៈពេលមួយឆ្នាំក្រោយមក នៅថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០០០ ក្នុងពេលជួបសួរសុខទុក្ខជនរងគ្រោះដោយសារទឹកជំនន់នៅក្នុងខេត្តសៀមរាប សម្តេចបានធ្វើសេចក្តីប្រកាសយ៉ាងឱឡារិកអំពីការកាត់ចេញឡូត៍នេសាទទំហំប្រមាណ ៨០០០ ហិកតា ទៅឱ្យសហគមន៍នេសាទសម្រាប់ការគ្រប់គ្រងតាមបែបសហគមន៍។ សម្តេច ក៏បានសន្យាផងដែរក្នុងការដកចេញនូវមន្ត្រីពុករលួយដែលមិនគាំទ្របុព្វហេតុរបស់ប្រជាជន។ នៅក្នុងដំណាក់កាលនេះ មានឡូត៍នេសាទចំនួន ២៣៩ ដែលមានវិសាលភាពសរុបធំជាងមួយលានហិកតា និងផ្តល់ប្រាក់ចំណូលដល់រដ្ឋាភិបាលប្រមាណ ២ លានដុល្លារអាមេរិក។ ភាគច្រើននៃឡូត៍នេសាទដែលត្រូវបានលុបចោលគឺជាឡូត៍នេសាទតូចៗដែលប្រាក់ចំណូលពីឡូត៍ទាំងនោះនីមួយៗត្រូវបានប៉ាន់ប្រមាណថាមានទាបជាង ៣០ លានរៀល (ប្រហែល ៧.៧០០ ដុល្លា) និងដែលមិនមែនជាឡូត៍នេសាទដែលមានផលិតភាពខ្ពស់នោះឡើយ (Cacaud et al, 2003) ។ ទោះជាយ៉ាងណាក៏ដោយ មានករណីខ្លះដែលឡូត៍នេសាទ ប្រកបដោយផលិតភាពខ្ពស់មួយចំនួន ក៏ត្រូវបានកាត់ចេញសម្រាប់សហគមន៍ប្រើប្រាស់ផងដែរ។

មានអនុក្រឹត្យជាច្រើន ត្រូវបានចេញផងដែរសម្រាប់ខេត្តនីមួយៗ ដើម្បីដាក់ជាផ្លូវការនូវការកាត់ចេញឡូត៍នេសាទ និងដើម្បីបង្កើតសហគមន៍នេសាទ។ ចំពោះប្រជាពលរដ្ឋនៅតាមទីជនបទ ជាពិសេសអ្នកដែលរស់នៅជុំវិញបឹងទន្លេសាប ការប្រកាសអំពីកំណែទម្រង់ទាំងនេះដោយអ្នកដឹកនាំនយោបាយជាន់ខ្ពស់មានសារៈសំខាន់ខ្លាំងណាស់។ នៅខែកុម្ភៈ ឆ្នាំ ២០០១ កម្ពុជាបានក្លាយជាប្រទេសទីមួយនៅអាស៊ី ដែលបានបង្កើតការិយាល័យដោយឡែកមួយ នៅក្នុងនាយកដ្ឋានជលផល សម្រាប់ការងារអភិវឌ្ឍន៍សហគមន៍នេសាទ ដែលមានគោលដៅគាំទ្រសហគមន៍ និងលើកទឹកចិត្តសហគមន៍ឱ្យចូលរួមកាន់តែច្រើនឡើងក្នុងគ្រប់គ្រងការនេសាទនៅក្នុងតំបន់ទំនាបលិចទឹកក្នុងប្រទេសកម្ពុជាផងដែរ។ រដ្ឋាភិបាលក៏ផ្តល់សិទ្ធិដល់អង្គការ FAO/UN ដែលនៅពេលនោះ កំពុងគាំទ្រការបង្កើតសហគមន៍នេសាទនៅខេត្តសៀមរាប ដើម្បីឱ្យជួយបង្កើតគណៈកម្មការគ្រប់គ្រងជលផលភូមិនៅជុំវិញបឹងទន្លេសាបផងដែរ ។ កិច្ចផ្តួចផ្តើមសហគមន៍ថ្មីៗនៅកម្រិតភូមិ បានធ្វើការយ៉ាងជិតស្និទ្ធជាមួយមេភូមិ អភិបាលស្រុក និងមន្ត្រីជលផលខេត្ត ដោយផ្តល់សិទ្ធិអំណាចដល់ដំណើរការអភិវឌ្ឍន៍សហគមន៍នេសាទ (Evans, 2002) ។

ដើម្បីធ្វើឱ្យវិធានការកែទម្រង់មានការគាំទ្រខាងផ្លូវច្បាប់ អនុក្រឹត្យមួយស្តីពីសហគមន៍នេសាទ ត្រូវបានរៀបចំឡើងដោយមានពិភាក្សាជាសាធារណៈនៅក្នុងខេត្តនីមួយៗ។ បន្ទាប់មក សេចក្តីព្រាងចុងក្រោយត្រូវបានរៀបរៀងឡើង និងត្រូវបានបញ្ជូនទៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីដាក់ជូនសុំការអនុម័តឯកភាពពីគណៈរដ្ឋមន្ត្រី។ ទន្ទឹមនឹងអនុក្រឹត្យ

ស្តីពីសហគមន៍នេសាទ ច្បាប់ជលផលដែលមានសារៈសំខាន់ជាង និងដែលត្រូវបានរៀបរៀងឡើងក្នុងគោលបំណងដាក់ឱ្យប្រើ-ប្រាស់ជំនួសច្បាប់ជលផលបច្ចុប្បន្នដែលត្រូវបានអនុម័តតាំងពីឆ្នាំ ១៩៨៧មកម្លេះ ក៏ត្រូវបានដាក់ជូនទៅសភាជាតិ នៅដើមឆ្នាំ ២០០៤ ផងដែរ។ ច្បាប់ជលផលថ្មី នឹងផ្តល់ជាក្របខ័ណ្ឌគតិយុត្តិ ដែលគាំទ្ររចនាសម្ព័ន្ធគ្រប់គ្រងថ្មីសម្រាប់សហគមន៍នេសាទ។ ព្រះរាជក្រឹត្យមួយស្តីពីការបង្កើតសហគមន៍នេសាទ ត្រូវបានប្រកាសឱ្យប្រើ ហើយអនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍នេសាទ ក៏ត្រូវបានចេញផងដែរ នៅខែ មិថុនា ឆ្នាំ ២០០៥។ ច្បាប់នេះគឺជាចំណែកស្នូលនៃកំណែទម្រង់ជលផលបច្ចុប្បន្ននៅក្នុងប្រទេសកម្ពុជា ( ប្រអប់ទី ២) ។

## ៣. កំណែទម្រង់វិស័យជលផល : ការប្រឈមដែលកើតឡើងថ្មី

នៅក្នុងដំណើរកំណែទម្រង់ធនធានធម្មជាតិ គោលបំណងសំខាន់មួយគឺ ការផ្លាស់ប្តូរគំរូនៃទំនាក់ទំនងរវាងប្រជាពលរដ្ឋជាមួយធនធានដែលជាមូលដ្ឋានសម្រាប់ការរស់នៅរបស់ប្រជាពលរដ្ឋទាំងនោះ។ របៀបនៃការប្រើប្រាស់ធនធាន និងបញ្ហានៃរបាយ និងសមធម៌ដែលបង្កើតឡើងដោយសារទំនាក់ទំនងនេះ គឺជាចំណុចស្នូលនៃគោលនយោបាយកំណែទម្រង់នេះ។ ការផ្លាស់ប្តូរដែលបានកើតឡើងតាមរយៈទំនាក់ទំនងរបស់ប្រជាពលរដ្ឋជាមួយធនធាន បានជះឥទ្ធិពលទៅលើវិធីដែលប្រជាពលរដ្ឋមានទំនាក់ទំនងជាមួយគ្នា។ សេចក្តីប្រកាសថ្មីអំពីសិទ្ធិមនុស្សក្នុងក្រុមណាមួយក្នុងការចេញចូល និងប្រើប្រាស់ធនធានតែងតែទាក់ទងជាមួយប្រការដែលថាតើក្រុមដទៃទៀតទទួលស្គាល់សេចក្តីប្រកាសនោះដែរឬទេ។ ដំណាក់កាលកែប្រែឈានទៅរកសិទ្ធិតាមទម្រង់ថ្មីតែងតែនាំមកជាមួយនូវទំនាស់ថ្មីៗ សមត្ថភាពថ្មី កាលានុវត្តភាព និងការគំរាមកំហែងជាច្រើនបែបផងដែរ។ នៅក្នុងអន្តរកាលរបស់ប្រទេសកម្ពុជាដើម្បីឈានទៅបង្កើតសហគមន៍នេសាទ ប្រការដូចដែលរៀបរាប់ខាងលើសុទ្ធតែអាចកើតឡើងទាំងអស់។ មានគម្លាតរវាងភាពស្របច្បាប់នៃកំណែទម្រង់ និងតម្រូវការដែលខានពុំបាន ខាងសេដ្ឋកិច្ចសង្គម និងវប្បធម៌របស់សង្គមមនុស្សនៅជនបទក្នុងផ្ទៃប្រទេស។ ដើម្បីបំពេញភាពខ្វះចន្លោះទាំងនេះ ទាមទារឱ្យមានចំណាត់ការជាច្រើននៅក្នុងវិស័យមួយចំនួន។ នោះគឺជាសកម្មភាពដែលត្រូវអនុវត្តដោយស្ថាប័នជាច្រើនរបស់រដ្ឋ និងដោយសហគមន៍នៅតាមលំដាប់ថ្នាក់ខុសៗគ្នា។ យន្តការទីផ្សារនឹងមានឥទ្ធិពលយ៉ាងខ្លាំងទៅលើលទ្ធផលជាក់ស្តែងនៃការផ្លាស់ប្តូររបបគ្រប់គ្រងធនធានធម្មជាតិ ។ ទីផ្សារនឹងមានឥទ្ធិពលទៅលើការអភិរក្សធនធាន របាយប្រាក់ចំណូលនៅក្នុងសង្គម និងផលប៉ះពាល់ទៅលើទស្សនៈអំពីជីវភាពរស់នៅទាំងមូលព្រមទាំងទៅលើសុខុមាលភាពរបស់ប្រជាពលរដ្ឋជាច្រើនលាននាក់នៅតាមទីជនបទ។

ការប្រឈមមានច្រើនណាស់។ ការប្រឈមខ្លាំងអាចនឹងលេចឡើងច្បាស់នៅក្នុងពេលអនាគតដ៏ខ្លី ចំណែកការប្រឈមខ្លះទៀតអាចនៅសម្ងំក្នុងសង្គមដែលមានភាពរស់រវើក ហើយដែលនឹងកើតមានឡើងជាមួយកំណែទម្រង់ស្ថាប័ន ហើយនឹងលេចចេញជារូបរាងនៅពេលក្រោយតែប៉ុណ្ណោះ។ យើងបានព្យាយាមចង្អុលបង្ហាញការប្រឈមខ្លះៗដែលមានសារៈសំខាន់នៅក្នុងចំណោមការប្រឈមខាងលើដែលយើងយល់ថានឹងកើតមានឡើងនៅក្នុងដំណាក់កាលនៃកំណែទម្រង់វិស័យជលផលនៅក្នុងប្រទេសកម្ពុជា។

## ៣.១ ការកំណត់សិទ្ធិជាថ្មីលើការចេញចូល និងការប្រើប្រាស់

នៅពេលថ្មីៗនេះ កំណែទម្រង់វិស័យជលផលបានធ្វើឱ្យមានការផ្លាស់ប្តូរពីប្រព័ន្ធឡូត៍នេសាទទៅជាក្របខ័ណ្ឌសហគមន៍នេសាទនៅលើវិសាលភាពប្រមាណពាក់កណ្តាលនៃទំហំតំបន់ទំនាបលិចទឹកសរុបក្នុងប្រទេសកម្ពុជា។ ទោះជាយ៉ាងណាក៏ដោយ កំណែទម្រង់នេះ ពុំបានធ្វើឱ្យមានការផ្លាស់ប្តូរសិទ្ធិជាមូលដ្ឋានលើធនធានទៅក្នុងប្រព័ន្ធនេះទេ។ ដូចមានចែងនៅក្នុងមាត្រា ៤ នៃសេចក្តីព្រាងច្បាប់ជលផល "ដែននេសាទគឺជាកម្មសិទ្ធិរបស់រដ្ឋ" ។ កំណែទម្រង់ដែលមានឥទ្ធិពលទៅលើឡូត៍នេសាទគួរតែត្រូវបានមើលឃើញថាជាវិធានការនានា ដែលបានបម្លែងចំណែកដ៏ធំមួយដែលជាកម្មសិទ្ធិរបស់រដ្ឋនៅក្រោមរបបសិទ្ធិប្រើប្រាស់ និងសិទ្ធិអាស្រ័យផលជាលក្ខណៈឯកជន ឱ្យទៅជាចំណែកដែលនឹងត្រូវបម្លែងឱ្យនៅក្រោមរបបសិទ្ធិប្រើប្រាស់ និងសិទ្ធិអាស្រ័យផលដែលមានការដាក់កំហិត (សូមអាន តារាងទី ១)។

បច្ចុប្បន្ន (ខែធ្នូ ឆ្នាំ ២០០៥) ច្បាប់ជលផលកំពុងរង់ចាំការពិភាក្សានៅសភាជាតិ ។ ដើម្បីឱ្យសហគមន៍នេសាទមានសិទ្ធិអំណាចតាមផ្លូវច្បាប់ បច្ចុប្បន្ន នាយកដ្ឋានជលផលកំពុងធ្វើការរៀបចំ បទបញ្ជា និងគោលការណ៍ណែនាំលំអិត គំរូលក្ខន្តិកៈ និងផែនការគ្រប់គ្រង ។ អនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍នេសាទត្រូវបានអនុម័តរួចហើយសម្រាប់សមាជិកសហគមន៍នេសាទប្រើប្រាស់។ ដោយហេតុថា អត្រាអ្នកចេះអក្សរនៅក្នុងសហគមន៍មានកម្រិតទាប ចាំបាច់ត្រូវមានកិច្ចប្រឹងប្រែងដើម្បីដើម្បីរៀបរៀងឯកសារពន្យល់អំពីអនុក្រឹត្យនេះ ដោយគូសបញ្ជាក់ចំណុចសំខាន់ៗនៅក្នុងអនុក្រឹត្យនេះ។ ការប្រើប្រាស់យុទ្ធសាស្ត្រប្រាស្រ័យទាក់ទងដែលអាចមើលឃើញផង និងស្តាប់បានផង ដើម្បីផ្សព្វផ្សាយចំណេះដឹងអំពីអនុក្រឹត្យនេះ គឺជាប្រការសំខាន់ជាអាយុជីវិត។ ប្រការសំខាន់គឺត្រូវមានការគូសបញ្ជាក់អំពីសិទ្ធិ ករណីយកិច្ច និងតួនាទីរបស់សមាជិកសហគមន៍នេសាទ ថាជាកិច្ចការដែលមានអាទិភាពខ្ពស់ និងជាផ្នែកបច្ចេកទេសនៃការបង្កើតសហគមន៍នេសាទដែលទាក់ទងនឹងកត្តាទាំងអស់នេះ។ ចាំបាច់ត្រូវផ្តោតការយកចិត្តទុកដាក់ ដើម្បីធ្វើឱ្យប្រាកដថា នីតិវិធីផ្សព្វផ្សាយព័ត៌មានទាំងអស់នេះ ត្រូវបានអនុវត្តប្រកបដោយការប្តេជ្ញា និងតម្លាភាព។ ការិយាល័យអភិវឌ្ឍន៍សហគមន៍នេសាទ និងមន្ត្រីជលផលនៅថ្នាក់ខេត្ត គួរតែផ្តល់ជាជំនួយនៅក្នុងដំណើរការនេះ។ តួនាទីរបស់អង្គការសង្គមស៊ីវិលនៅក្នុងការបំពេញកិច្ចការឃ្លាំមើលមិនគួរត្រូវកាត់បន្ថយនោះឡើយ។

**តារាងទី ១: ការប្រែប្រួលរូបភាពនៃសិទ្ធិចេញចូល និងប្រើប្រាស់**
**នៅក្នុងតំបន់នានានៃឡូត៍នេសាទក្នុងប្រទេសកម្ពុជា**

| ដំណាក់កាល | រូបភាពនៃសិទ្ធិប្រើប្រាស់ និងសិទ្ធិលើកម្មសិទ្ធិ |
|---|---|
| **មុនខែតុលា ឆ្នាំ ២០០០**<br>*(មុនពេលមានការប្រកាសអំពីកំណែទម្រង់បច្ចុប្បន្ននេះ ដែលធ្វើឡើងដោយនាយករដ្ឋមន្ត្រី)* | ទ្រព្យសម្បត្តិដែលជាកម្មសិទ្ធិរបស់រដ្ឋត្រូវស្ថិតនៅក្រោម សិទ្ធិប្រើប្រាស់ និងសិទ្ធិ អាស្រ័យផលជាឯកជន |

| | |
|---|---|
| **ខែតុលា ឆ្នាំ ២០០០ ដល់ ខែ ឧសភា ឆ្នាំ ២០០៥**<br>*(ក្រោយការប្រកាសរបស់នាយករដ្ឋមន្ត្រី និងមុនការអនុម័តអនុក្រឹត្យស្តីពីសហគមន៍នេសាទ)* | នៅដំណាក់កាលដំបូង ទ្រព្យសម្បត្តិដែលជាកម្មសិទ្ធិរបស់រដ្ឋត្រូវបានប្រែក្លាយទៅជាសម្បត្តិសម្រាប់**ការប្រើប្រាស់ជាលក្ខណៈបើកចំហ** (មនុស្សទាំងអស់គ្នាអាចប្រើប្រាស់ដោយសេរី ដោយគ្រាន់តែមានសិទ្ធិតាមធម្មជាតិ) |
| **ខែឧសភា ឆ្នាំ ២០០៥ តមក**<br>*(ក្រោយការអនុម័តអនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍នេសាទ [SDCFM] )* | កម្មសិទ្ធិរបស់រដ្ឋ នៅក្រោម**សិទ្ធិប្រើប្រាស់ និងសិទ្ធិអាស្រ័យផលដោយសហគមន៍ ដែលមានការដាក់កំហិត**<br>តំបន់នេសាទរបស់សហគមន៍គឺជាកម្មសិទ្ធិសម្រាប់ការប្រើប្រាស់ផ្តាច់មុខក្នុងការនេសាទ (TURF) (មាត្រា ៦ នៃអនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍។ ទោះជាយ៉ាងណាក៏ដោយ សិទ្ធិប្រើប្រាស់ក៏អាចផ្តល់ឱ្យដល់អ្នកដែលមិនមែនជាសមាជិកសហគមន៍ផងដែរ សម្រាប់គោលដៅសេដ្ឋកិច្ច-សង្គម (មាត្រា ១៤ នៃអនុក្រឹត្យ ស្តីពីការគ្រប់គ្រងសហគមន៍នេសាទ) |

សុទិដ្ឋិនិយមដែលកើនឡើងក្នុងចំណោមសហគមន៍នៅជិតដែនទឹក អំពីសិទ្ធិថ្មីលើការប្រើប្រាស់ និងការអាស្រ័យផល និងសេរីភាព[5] ក្នុងការពាក់ព័ន្ធជាមួយធនធានជលផលដែលទទួលបានតាមរូបភាពនេះមានវិសាលភាពធំធេងគួរឱ្យកត់សំគាល់។ ចំនួនដ៏ច្រើននៃសហគមន៍នេសាទដែលត្រូវបានបង្កើតឡើងជាក់ស្តែង និងរបាយនៃសហគមន៍ទាំងនេះនៅទូទាំងដែនទឹកលើផ្ទៃប្រទេស គឺជាប្រការគួរឱ្យកត់សំគាល់ (សូមមើលផែនទី ១)។ សហគមន៍នេសាទបានក្លាយជា របស់ដែលបានបង្កើតរួចមកហើយនៅក្នុងប្រទេសកម្ពុជា ។

| |
|---|
| សុទិដ្ឋិនិយមដែលកើនឡើងក្នុងចំណោមសហគមន៍នៅជិតដែនទឹក អំពីសិទ្ធិថ្មីលើការប្រើប្រាស់ និងការអាស្រ័យផល និងសេរីភាពក្នុងការពាក់ព័ន្ធជាមួយធនធានជលផល ដែលទទួលបានតាមរូបភាពនេះ មានវិសាលភាពធំធេងគួរឱ្យកត់សំគាល់។ |

ការផ្លាស់ប្តូរជាក់ស្តែងនូវសិទ្ធិចេញចូល និងប្រើប្រាស់ក្នុងចន្លោះឆ្នាំ ២០០០ និងឆ្នាំ ២០០៥ បានទទួលការគាំទ្រយ៉ាងច្រើនតាមរយៈការកែសម្រួលស្ថាប័ននៅផ្ទៃក្នុងរបស់នាយកដ្ឋានជលផល ដោយមានការប្តេជ្ញាខាងនយោបាយពីមន្ត្រីនៅថ្នាក់ខ្ពស់បំផុត។ ការគាំទ្រដោយសង្គមស៊ីវិល និងការប្តេជ្ញារបស់អង្គការអន្តរជាតិដូចជា អង្គការ FAO/UN ចាប់តាំងពីដំណាក់កាលដើមដំបូងនៃដំណើរការផ្លាស់ប្តូរមានសារៈសំខាន់ណាស់ក្នុងការបន្តរក្សាជំហាននៃការទាមទារថ្មីៗរហូតបានទទួលលទ្ធផល នៅទីបំផុត។ ទោះជាយ៉ាងណាក្តី ការទាមទារថ្មីជាបន្ថែម ពុំមានមូលដ្ឋានច្បាប់ឡើយ មុនពេលដែលសភាអនុម័តច្បាប់ជលផលថ្មី។

---

[5] ពេលធ្វើទស្សនកិច្ចសិក្សា យើងបានស្វែងយល់ថា ផលប្រយោជន៍ដ៏សំខាន់មួយនៃការប្រែក្លាយឡូត៍នេសាទទៅជាកន្លែងសហគមន៍នេសាទគឺជាសិទ្ធិសេរីភាពទាក់ទងនឹងការប្រើប្រាស់ធនធានធម្មជាតិដោយគ្មានការភ័យខ្លាច និងការគំរាមកំហែងពីសំណាក់ម្ចាស់ឡូត៍នេសាទ ។




ផែនទី ១: ផែនទីប្រទេសកម្ពុជា បង្ហាញតំបន់ឡូត៍នេសាទដែលបានកាត់ចេញសម្រាប់សហគមន៍នេសាទ

ការរំពឹងទុកថា នៅពេលដែលបានទទួលការគាំទ្រតាមផ្លូវច្បាប់ហើយ នឹងមានការគោរពចំពោះសិទ្ធិរបស់សហគមន៍ ពីគ្រប់ស្រទាប់មនុស្សនៅក្នុងសង្គម គឺជាបំណងប្រាថ្នារបស់យើង។ សិទ្ធិត្រួតត្រាលើធនធាន ធ្វើឱ្យមានការប្រែប្រួលលើរបាយប្រាក់ចំណូល និងទ្រព្យសម្បត្តិក្នុងចំណោមសហគមន៍។ សម្ព័ន្ធភាពថ្មីៗនឹងបង្កើតឡើង ឯសម្ព័ន្ធភាពចាស់នឹងត្រូវកែប្រែ។ ទាំងនេះគឺជាមូលដ្ឋានដែលធ្វើឱ្យមានភាពតានតឹងថ្មីនៅក្នុងសង្គម។ ការកែតម្រូវទៅតាមភាពទទួលខុសត្រូវទាំងនេះ ការផ្តល់នូវការយល់ដឹងជាការរំពឹងទុកជាមុន និងការកសាងសមត្ថភាពសម្រាប់ដោះស្រាយជម្លោះនៅកម្រិតមូលដ្ឋាន គឺជាកិច្ចការចំបងមួយនៅចំពោះមុខរចនាសម្ព័ន្ធអភិបាលកិច្ចរបស់រដ្ឋ។ អង្គការសង្គមស៊ីវិលដែលធ្លាប់បានដើរតួយ៉ាងសំខាន់នៅក្នុងការបង្កើតសហគមន៍នេសាទ ក៏ត្រូវតែបង្វែរការគាំទ្រសំខាន់ៗរបស់ខ្លួន សម្រាប់ព្រឹត្តិការណ៍បែបនេះដែរ។

## ៣.២ ការស្វែងយល់អំពីការផ្លាស់ប្តូរប្រព័ន្ធ

ការដាក់កំហិតលើសិទ្ធិរបស់សហគមន៍ក្នុងការប្រើប្រាស់ និងអាស្រ័យផល គឺពិតជាការផ្លាស់ប្តូរចំបងខាងស្ថាប័ន ដែលកើតឡើងដោយសារកំណែទម្រង់ ដូច្នេះត្រូវធ្វើការពិនិត្យឱ្យបានម៉ត់ចត់អំពីការប្រែប្រួលផ្សេងទៀតដែលមានលក្ខណៈជាប្រព័ន្ធ និងដែលស្ថិតនៅក្រោមឥទ្ធិពលនៃកំណែទម្រង់ ។ ការប្រែប្រួលទាំងនោះរួមមាន : (១) ទំហំផលិតកម្ម (២) ប្រភេទនៃជម្រើស

បច្ចេកវិទ្យា (៣) ការប្រែប្រួលដែលទំនងជាកើតឡើងចំពោះទិដ្ឋភាពអ៊ីដ្រូលិកនៃប្រព័ន្ធនេះ ដែលនឹងធ្វើឱ្យមានការប្រែប្រួលនូវអន្តរកម្មរវាងដី និងទឹកនៅក្នុងតំបន់ទំនាបលិចទឹក និង (៤) ការប្រែប្រួលនៃប្រព័ន្ធទាំងមូល ដោយសារការប្រើប្រាស់ច្រើនយ៉ាងដែលគ្មានការសម្របសម្រួលរវាងគ្នា។ ទន្ទឹមនឹងការប្រែប្រួលខាងស្ថាប័ន កត្តាទាំងនេះនឹងមានតួនាទីយ៉ាងសំខាន់ក្នុងការដាក់កំហិតអំពីបរិមាណផលដែលត្រូវប្រមូល និងក្នុងការកំណត់អំពីប្រភេទ សកម្មភាពនៃការកែច្នៃផលនេសាទ និងការចាត់ចែងផលនេសាទនៅក្នុងទីផ្សារនៃប្រទេសកម្ពុជាផងដែរ។ ការប្រែប្រួលនេះក៏នឹងបង្កើតលក្ខខណ្ឌសម្រាប់ការប្រើប្រាស់ផ្សេងទៀតផងដែរ ដែលជាការតម្រង់ទិសសហគមន៍នេសាទក្នុងការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ដែលទើបទទួលបានថ្មី។ វាក៏មានទំនាក់ទំនងទូលំទូលាយ និងមានឥទ្ធិពលលើបញ្ហានានានៃសិទ្ធិប្រើប្រាស់និងសមធម៌ផងដែរ។

យោងតាមទិន្នន័យអំពីស្ថិតិផលនេសាទ ផលិតផលសរុបពីការនេសាទទ្រង់ទ្រាយធំ រួមទាំងផលពីឡូត៍នេសាទទាំងអស់មានបរិមាណត្រឹមតែប្រមាណ ១០ ភាគរយនៃផលនេសាទទឹកសាបសរុបក្នុងប្រទេសកម្ពុជាតែប៉ុណ្ណោះ។ ការនេសាទជាលក្ខណៈគ្រួសារ (ភាគច្រើនប្រើប្រាស់មង សំណាញ់ និងលបតូចៗ) ត្រូវបានប៉ាន់ប្រមាណត្រឹម ៤០ ភាគរយនៃផលនេសាទសរុប[6] ។ កំណែទម្រង់វិស័យជលផលនៅពេលថ្មីៗនេះ បាននាំឱ្យមានការកាត់ចេញដែននេសាទទំហំពាក់កណ្តាលពីឡូត៍នេសាទ និងដាក់ទៅជាកន្លែងសហគមន៍នេសាទ។ មានតែការធ្វើនេសាទជាលក្ខណៈគ្រួសារតែប៉ុណ្ណោះដែលអាចអនុញ្ញាតនៅក្នុងកន្លែងនេសាទសហគមន៍ទាំងនេះ។ ក្នុងករណីនេះ *ប្រសិនបើកត្តានានាដទៃទៀតស្ថិតនៅឥតប្រែប្រួល* យើងពុំគួររំពឹងថានឹងឃើញមានការប្រែប្រួលនៃផលនេសាទជាដុំកំភួនឡើយ បណ្តាលពីកំណែទម្រង់តែខាងផ្នែកស្ថាប័នមួយមុខនោះ។ ទោះជាយ៉ាងណាក៏ដោយ ទិន្នន័យបានពីនាយកដ្ឋានជលផល សម្រាប់រយៈពេលពីឆ្នាំ ២០០០ ដល់ ២០០៤ បានបង្ហាញឱ្យឃើញពីកំណើនយ៉ាងខ្លាំងនូវផលនេសាទក្នុងរវាងឆ្នាំ ២០០០ និង ២០០១ បន្ទាប់ពីនោះមានការធ្លាក់ចុះមកត្រឹមអត្រា ឆ្នាំ ២០០០ សម្រាប់ផលនេសាទនៅឆ្នាំ ២០០៤ (សូមមើលរូបទី ១) ។ គួរឱ្យឆ្ងល់ដែរ ទិន្នន័យផ្លូវការរបស់នាយកដ្ឋានជលផលបានបង្ហាញអំពីកំណើនផលនេសាទនៅក្នុងឆ្នាំ ២០០៥។ នេះមានន័យថា ក្រោយពីមានការប្រកាសកែប្រែស្ថាប័នទៅបង្កើតសហគមន៍នេសាទ កត្តានានាផ្សេងទៀតនៅក្នុងប្រព័ន្ធនេះ *មិនមែនស្ថិតនៅឥតប្រែប្រួលនោះឡើយ។*

*(i) ទំហំ*

ការផ្លាស់ប្តូរខាងស្ថាប័នបាននាំឱ្យមានការប្រែប្រួលទំហំនៃផលិតកម្ម។ សកម្មភាពទ្រង់ទ្រាយតូចកាន់តែច្រើន បានបង្កើនកម្លាំងនេសាទ ដែលត្រូវបានប្រើប្រាស់នៅអំឡុងពេលក្រោយមានកំណែទម្រង់ ហើយប្រការមានឥទ្ធិពលទៅលើអត្រាត្រឹមរាប់ដោយសារការនេសាទជាទូទៅ។ ប្រសិនបើមានការប្រើប្រាស់តែឧបករណ៍នេសាទខ្នាតតូចដូចដែលអនុញ្ញាតនៅក្នុងច្បាប់ គ្មានហេតុផលណាមួយដែលនាំឱ្យមានការរំពឹងថាមានគ្រោះថ្នាក់ចំពោះប្រព័ន្ធអេកូឡូស៊ីនោះឡើយ។ ប៉ុន្តែផលនេសាទដែលអ្នកនេសាទម្នាក់ៗទទួលបានមានបរិមាណកាន់តែថយចុះ។ ប្រការនេះត្រូវបានអ្នកនេសាទនៅមូលដ្ឋានចាត់ទុកថាជាការបាត់បង់ធនធាន។

[6] មានការប៉ាន់ប្រមាណខុសគ្នាជាច្រើនអំពីផលនេសាទទឹកសាប។ ភាពខុសគ្នាបែបនេះមួយផ្នែក អាចកើតមានឡើង ដោយសារភាពប្លែកគ្នាច្រើនបែបនៃដែននេសាទ និងប្រភេទឧបករណ៍នេសាទដែលបានប្រើប្រាស់។ ការប៉ាន់ប្រមាណផ្តល់តួលេខប្រែប្រួលពី ២៨០.០០០ ដល់ ៤៣១.០០០ តោន (FAO, 2005) ។

យោបល់បែបនេះ គួរយកទៅវាយតម្លៃឱ្យបានត្រឹមត្រូវ ជាពិសេសដោយប្រៀបធៀប ជាមួយទិដ្ឋភាពរួមនៃការប្រើប្រាស់ប្រភេទឧបករណ៍នេសាទ។




**រូបទី ១ : បរិមាណផលនេសាទទឹកសាបក្នុងប្រទេសកម្ពុជា ទិន្នន័យផ្លូវការ**

*(ii) បច្ចេកវិទ្យា*

មានរបាយការណ៍ជាច្រើនស្ដីពីកំណើននៃការប្រើប្រាស់បច្ចេកវិទ្យានេសាទប្រកបដោយគ្រោះថ្នាក់នៅក្នុងតំបន់ដែលទើបកាត់ចេញថ្មីសម្រាប់សហគមន៍នេសាទ។ ប្រការនេះបានបង្ហាញជាភស្តុតាងយ៉ាងច្បាស់នៅក្នុងរវាងឆ្នាំ ២០០១-២០០៥ នៅពេលដែលពុំមានយន្តការតាមផ្លូវច្បាប់ច្បាស់លាស់ ដើម្បីតម្រង់ទិសកិច្ចផ្ដួចផ្ដើមរបស់សហគមន៍នេសាទ។ ការធ្វើទស្សនកិច្ចនៅក្នុងពេលថ្មីៗនេះនៅក្នុងខេត្តកំពង់ឆ្នាំង និងបាត់ដំបង ក៏អះអាងបញ្ជាក់ផងដែរថា ការនេសាទនៅក្នុងកន្លែងដែលបានកាត់ទៅឱ្យសហគមន៍នេសាទកំពុងតែបន្តស្ថិតក្រោម"សកម្មភាពនេសាទល្មើសច្បាប់" ដែលត្រូវតែកំណត់ថា រួមមានទាំង មិនត្រឹមតែការធ្វើនេសាទដោយបច្ចេកវិទ្យាប្រកបដោយគ្រោះថ្នាក់ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងការធ្វើនេសាទដោយប្រើប្រាស់ឧបករណ៍ស្របច្បាប់ *ប៉ុន្តែនៅក្នុងតំបន់ដែលហាមឃាត់ផងដែរ*។

ការអនុញ្ញាតឱ្យមានការនេសាទជាលក្ខណៈគ្រួសារកាន់តែច្រើនមានន័យថា មានការប្រើប្រាស់កាន់តែច្រើនឡើងនូវ មង លប និងទូក។ តម្រូវការសម្ភារៈដើម្បីផលិតឧបករណ៍ និងប្រដាប់សម្រាប់បម្រើក្នុងការនេសាទក៏បានកើនឡើងផងដែរ។ ឈើដែលត្រូវការសម្រាប់ផលិតទូកក៏ពុំមានគ្រប់គ្រាន់។ ជាទម្លាប់ប្រពៃណី ដើមត្នោត ត្រូវបានប្រើប្រាស់នៅតាមកន្លែងជាច្រើន ប៉ុន្តែវត្ថុធាតុដើមទាំងនេះនឹងត្រូវខ្វះខាតនៅក្នុងពេលឆាប់ៗខាងមុខនេះ[7]។ តម្រូវការសម្ភារៈផ្សេងសម្រាប់ផលិតទូកអាចនឹងកើតឡើងនៅក្នុងពេលឆាប់ៗខាងមុខនេះ។ ករណីដូចគ្នានេះនឹងកើតមានចំពោះសម្ភារៈសម្រាប់ផលិតមងផងដែរ។ អ្នកបច្ចេកទេស និងសេវាផ្សព្វផ្សាយ ត្រូវយកចិត្តទុកដាក់អំពីផ្នែកទាំងនេះ។ ទន្ទឹមនឹងតម្រូវការឱ្យមានការត្រួតពិនិត្យអំពីបច្ចេកវិទ្យាប្រកបដោយគ្រោះថ្នាក់ ប្រការសំខាន់គឺគួរធ្វើការពិនិត្យមើលផងដែរអំពី ការកើតឡើងវិញ និងការកែលំអបច្ចេកវិទ្យាទាំងចាស់ និងថ្មី ដែលនឹង

[7] ការកាប់ដើមត្នោត ជាអំពើល្មើសច្បាប់។ ទោះជាយ៉ាងណាក៏ដោយ យើងបានធ្វើការសង្កេតនៅតាមទីកន្លែងជាក់ស្ដែង ដោយឃើញថា សកម្មភាពនេះកំពុងអនុវត្តជាលក្ខណៈបើកចំហ ដែលជាការចង្អុលបង្ហាញអំពីតម្រូវការឱ្យបង្កើតជម្រើសផ្សេងនៃសម្ភារៈសម្រាប់ផលិតទូក។

រួមចំណែកធ្វើឱ្យមានកំណើននៃផលនេសាទជាលក្ខណៈគ្រួសារនៅក្នុងផលនេសាទទឹកសាបសរុប។ ត្រូវធ្វើការវាយតម្លៃផងដែរ អំពីតម្រូវការប្រភេទសម្ភារៈថ្មីៗ និង/ឬ ឥទ្ធិពលនៃការបង្កើនចំនួនអ្នកមានការងារធ្វើឆ្លើយតបនឹងសកម្មភាពទាំងនេះ។

*(iii) អ៊ីដ្រូលិក*

ត្រូវធ្វើការសង្កេតមើលឱ្យបានម៉ត់ចត់ផងដែរ អំពីផលប៉ះពាល់នៃការផ្លាស់ប្តូរខាងស្ថាប័នទៅលើការប្រែប្រួលជលសាស្ត្រនៃទន្លេ និងប្រព័ន្ធតំបន់ទំនាបលិចទឹកនៅក្នុងដែននេសាទទឹកសាបនៃប្រទេសកម្ពុជា។ ទោះបីផលប៉ះពាល់តិចតួចនៃការផ្លាស់ប្តូរទាំងនេះអាចទាមទារពេលវេលាយូរ ដើម្បីធ្វើការវាយតម្លៃក៏ដោយ ផលប៉ះពាល់នៅកម្រិតមូលដ្ឋាននឹងបង្ហាញឱ្យឃើញច្បាស់លាស់ជាង។ ឧទាហរណ៍: ចាប់តាំងពីមានការលុបចោលរចនាសម្ព័ន្ធឡូត៍នេសាទក្នុងទំហំពាក់កណ្តាលនៃវិសាលភាពតំបន់ដែលមានពីមុន ល្បឿនទឹកហូរចេញនៅក្នុងរដូវបើកនេសាទ (ក្រោយខែតុលា) អាចកើនឡើងរហ័សជាងមុន[8]។ ប្រការនេះអាចធ្វើឱ្យអន្លង់នានានៅក្នុងតំបន់ទំនាបលិចទឹកត្រូវគោក ជាហេតុនាំឱ្យងាយស្រួលក្នុងការធ្វើនេសាទ និងក៏នាំឱ្យដីនៅក្នុងតំបន់ទំនាបលិចទឹកឆាប់គោកដែលងាយស្រួលដល់ការធ្វើកសិកម្មផងដែរ។ម្យ៉ាងវិញទៀត ចរន្តទឹកហូររហ័សជាងមុនអាចមានផលប៉ះពាល់អវិជ្ជមានទៅលើការស្រោចស្រពស្រែផងដែរ។ នៅក្នុងសហគមន៍នេសាទនៅបាក់អម្រែក ក្នុងខេត្តបាត់ដំបង សមាជិកសហគមន៍បានចង្អុលបង្ហាញអំពីផលិតភាពខ្ពស់នៃផលនេសាទនៅក្នុងទន្លេដែលស្ថិតនៅជាប់នឹងកន្លែងនេសាទសហគមន៍នេសាទ។ អ្នកទាំងនោះបានកត់សំគាល់អំពីកំណើនផលិតភាពនេះ ថាកើតឡើងដោយសារសមាជិកសហគមន៍បានសម្រេចកំទេចចោលរាស់របាំងជាច្រើននៅក្នុងផ្លូវទឹកនានា ក្នុងទំនាបលិចទឹកនេះដែលអតីតម្ចាស់ឡូត៍នេសាទបានដាក់នៅទីនោះ។ ជាលទ្ធផល មានត្រីកាន់តែច្រើនបានចូលទៅក្នុងស្ទឹងនេះ។ អាស្រ័យហេតុនេះ ស្ត្រី និងកុមារកាន់តែច្រើន អាចនេសាទត្រីសម្រាប់បរិភោគ និងកែច្នៃនៅទីកន្លែងជិតផ្ទះរបស់ខ្លួននៅតាមដងស្ទឹងនេះ។ ស្ទឹងនេះមិនមែនជាផ្នែកមួយនៃដែននេសាទរបស់សហគមន៍នេះឡើយ ហើយក៏មិនមែនជាតំបន់សម្រាប់ការនេសាទដោយសេរីនោះដែរ។ នេះគឺជាកត្តាវិជ្ជមានពីខាងក្រៅ បណ្តាលពីការផ្លាស់ប្តូរទៅរករបបសហគមន៍នេសាទ និងដែលកើតឡើងពីការផ្លាស់ប្តូរភាពប្រែប្រួលជលសាស្ត្រនៅកម្រិតមីក្រូ (នៅមូលដ្ឋាន)។ ការផ្លាស់ប្តូរបែបនេះទំនងជាមានច្រើនដែលមានផលប៉ះពាល់ទាំងវិជ្ជមាន និងអវិជ្ជមាន។

*(iv) ប្រព័ន្ធអេកូឡូស៊ី*

ការផ្លាស់ប្តូរទំហំ បច្ចេកវិទ្យា និងអ៊ីដ្រូលិក ក៏នាំឱ្យមានឥទ្ធិពលមិនអាចជៀសវាងបាន ទៅលើប្រព័ន្ធអេកូឡូស៊ីផងដែរ។ ត្រូវធ្វើការសិក្សាផងដែរ អំពីការផ្លាស់ប្តូរខាងជីវសាស្ត្រ និងទម្រង់នៃការធ្វើចរាចររបស់ត្រី។ ការសិក្សាអំពីថាតើទីជម្រកសំខាន់ៗសម្រាប់ត្រី ឡូត៍នេសាទបំរុងទុក តំបន់ទំនាបលិចទឹក ព្រៃលិចទឹក និងអន្លង់នានា បានរងផលប៉ះពាល់បែបណា គឺជាការជួយសម្រួលឱ្យមានការយល់ដឹងបន្ថែមទៀតអំពីការប្រែប្រួលនៃជីវៈចម្រុះផងដែរ។ ដោយសារសហគមន៍នេសាទត្រូវបានបង្កើតឡើងនៅរាយប៉ាយតាមកន្លែងជាច្រើន ការប្រែប្រួលនៅក្នុងប្រព័ន្ធអេកូឡូស៊ីអាចកាន់តែកើនឡើង និងពុំអាចកត់សំគាល់បាននៅក្នុង

[8] ការធ្វើសេចក្តីយោងនៅទីនេះ សំដៅលើការបើកចំហ និងដកចេញនូវរបាំងនានា (របាំងប្រួល របាំងឧបករណ៍នេសាទ របាំងទប់ទឹក ផ្លូវទឹក ។ល។) រវាងព្រែក និងបឹងនានា ព្រមទាំងជាមួយតំបន់ទំនាបលិចទឹក ដែលអាចជាកន្លែងធ្វើកសិកម្ម។ ការផ្លាស់ប្តូរឌីណាមិកជលសាស្ត្រទាំងនេះ បានបង្ហាញឱ្យឃើញកាន់តែច្បាស់នៅក្នុងតំបន់នានា ដែលស្ថិតនៅជិតតំបន់ដីសណ្ត។

ដំណាក់កាលដើមដំបូងឡើយ ។ ទោះជាយ៉ាងណាក៏ដោយ ភាគច្រើននៃ "ការផ្លាស់ប្តូរបន្តិចម្តងៗ" អាចប្រមូលផ្តុំរហូតដល់កម្រិតខ្ពស់មួយដែលការស្តារប្រព័ន្ធអេកូឡូស៊ីឡើងវិញនឹងប្រទះការលំបាកកាន់តែខ្លាំងឡើង និងទាមទាររយៈពេលវែង។ ក្នុងករណីនេះ វាអាចបង្កឱ្យមានបន្ទុកយ៉ាងធ្ងន់ធ្ងរចំពោះអេកូឡូស៊ី និងសេដ្ឋកិច្ច។ ការកត់សំគាល់ដោយប្រុងប្រយ័ត្នអំពីស្ថានភាពរំខានបែបនេះនៅកម្រិតមូលដ្ឋាន នឹងជួយធ្វើឱ្យប្រាកដថា ការប្រែប្រួលខាងស្ថាប័នអាចនាំឱ្យមានការប្រែប្រួលសមាសភាពនៃប្រភេទ ដែលអាចនឹងនាំឱ្យមានផលប៉ះពាល់អវិជ្ជមានរយៈពេលវែង[9] ។ វចនាសម្ព័ន្ធនៃការចូលរួមរបស់អ្នកនេសាទនៅក្នុងការវាយតម្លៃទាំងអស់នេះ មិនត្រឹមតែនឹងនាំឱ្យមកនូវព័ត៌មានល្អៗប៉ុណ្ណោះទេ ប៉ុន្តែក៏អាចរួមចំណែកយ៉ាងច្រើន ចំពោះចំណេះដឹង និងការយល់ដឹងរបស់អ្នកទាំងអស់នោះអំពីប្រព័ន្ធអេកូឡូស៊ីដែលបច្ចុប្បន្នកំពុងស្ថិតក្រោមការត្រួតត្រារបស់ខ្លួនផងដែរ។

### ៣.៣ ការទទួលស្គាល់អំពីអន្តរកម្មរវាងដីធ្លី និងទឹក

មានទិដ្ឋភាពដ៏មានសារៈសំខាន់មួយ ដែលពុំទាន់បានឆ្លុះបញ្ចាំងគ្រប់គ្រាន់នៅឡើយនៅក្នុងអនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍នេសាទ។ ជាក់ស្តែង ជាញឹកញាប់កន្លែងនេសាទរបស់សហគមន៍គឺជាកន្លែងដែលជួបប្រសព្វគ្នារវាងដីធ្លី និងដែនទឹក ហើយជាធម្មតា សមាជិកសហគមន៍ដែលរស់នៅក្នុងភូមិមានសមាសភាពជាអ្នកមានចំណាប់អារម្មណ៍ក្នុងកម្រិតខុសៗគ្នាទាក់ទងនឹងសក្តានុពលនៃធនធានធម្មជាតិ *ទាំង*ដីធ្លី និងដែនទឹក។ ប្រការនេះអាចបង្កើតឱ្យមានទំនាស់ផ្ទៃក្នុងរវាងសមាជិកនានាដោយសារចរិត និងការប្រើប្រាស់ដីធ្លីនៅក្នុងតំបន់ទំនាបលិចទឹកអាចមានទំនាស់ស្រួចស្រាល់ជាមួយចរិត និងការប្រើប្រាស់ទឹកនៅក្នុងសហគមន៍នោះ។ ទំនាស់ទាំងនេះអាចកើតឡើងនៅពេលណាមួយ និងក៏អាចបន្តរយៈពេលពេញមួយរដូវដែលមានការប្រើប្រាស់នោះផងដែរ ។

វត្តមាននៃការយល់ឃើញអំពីផលចំណេញ ឬ ការខូចបង់បណ្តាលពីការផ្លាស់ប្តូរពីរបបតាមប្រព័ន្ធឡូត៍នេសាទទៅជារបបនេសាទតាមបែបសហគមន៍ អាស្រ័យជាសំខាន់ទៅលើចរិតប្រើប្រាស់ច្រើនយ៉ាងនូវធនធាននានាពីសំណាក់ប្រជាពលរដ្ឋ។ ឧទាហរណ៍ៈ សមាជិកមួយរូបនៅក្នុងសហគមន៍ ដែលមានចំណែកដី និងបានចូលរួមនៅក្នុងសកម្មភាពនេសាទតាមរដូវអាចគិតថា លទ្ធភាពប្រើប្រាស់ទឹកបច្ចុប្បន្ននៅក្នុងតំបន់ទំនាបលិចទឹកដែលគ្មានការដាក់កំហិតទៅតាមរបបសហគមន៍នេសាទ បានផ្តល់អត្ថប្រយោជន៍សន្ធឹកសន្ធាប់សម្រាប់ជាចំណូលផ្ទាល់ខ្លួន។ ម្យ៉ាងវិញទៀត សមាជិកមួយរូបផ្សេងទៀតដែលពុំមានដីធ្លីសោះ និងដែលពឹងផ្អែកទាំងស្រុងលើការនេសាទអាចចាត់ទុកការផ្លាស់ប្តូរទៅជាការនេសាទតាមរបបសហគមន៍ ថាមានឥទ្ធិពលអវិជ្ជមានដោយសារកំណើននៃភាពប្រកួតប្រជែងជាមួយអ្នកដទៃទៀតក្នុងការធ្វើនេសាទដែលកាលពីមុនត្រូវបានរារាំងដោយសារប្រព័ន្ធឡូត៍

---

[9] មានភស្តុតាងថា នៅមុនពេលមានការផ្លាស់ប្តូរទៅបង្កើតសហគមន៍នេសាទ មានការប្រែប្រួលសមាសភាពប្រភេទត្រីជាច្រើន។ បច្ចុប្បន្ន ពពួកត្រី Cyprinids មានសមាសភាពរហូតដល់លើសពី 40 ភាគរយនៃផលនេសាទសរុបនៅក្នុងប្រព័ន្ធបឹងទន្លេសាបទាំងមូល ចំនួនត្រីដែលមានទំហំធំ ពពួកត្រីប្រា និងត្រីកាបក៏បានថយចុះផងដែរ ។ ភស្តុតាងអនាមិកមួយចំនួនបង្ហាញថា ប្រភេទត្រីធ្វើចរាចរ និងប្រភេទត្រីធំៗ ដែលធ្លាប់តែសម្បូរ ក៏បានថយចុះផងដែរ ដោយសារសម្ពាធនៃការធ្វើនេសាទ (Allan et al, 2005) ។

នេសាទ។ មានសំណុំលក្ខណៈរួមគ្នាជាច្រើន នៅក្នុងកន្លែងនេសាទសហគមន៍ ដែលត្រូវបានបង្កើតឡើងថ្មីដែលនាំឱ្យលំបាកធ្វើសេចក្តីអធិប្បាយជាទូទៅអំពីផលប៉ះពាល់នៃកំណែទម្រង់លើវិស័យជលផលនាពេលបច្ចុប្បន្នទៅលើប្រជាពលរដ្ឋ។

ភាពស្មុគស្មាញបន្ថែមមួយនៅក្នុងការវាយតម្លៃអំពីផលចំណេញ និងការខាតបង់នៃកំណែទម្រង់វិស័យជលផលគឺដោយសារតំបន់ទំនាបលិចទឹកធ្លាប់ត្រូវបានមនុស្សទាំងឡាយចាត់ទុកថាជាតំបន់នេសាទដោយសេរីដែលត្រូវបានប្រើប្រាស់ជាជម្រើសចុងក្រោយ។ ជាលទ្ធផល លក្ខខណ្ឌ និងកាលានុវត្តភាពនានាសម្រាប់កសិកម្មតែងតែមានឥទ្ធិពលទៅលើវិសាលភាពនៃការប្រើប្រាស់ក៏ដូចជាទៅលើបរិមាណ និងប្រភេទនៃកិច្ចប្រឹងប្រែងដែលនឹងត្រូវយកទៅអនុវត្តចំពោះការធ្វើនេសាទនៅក្នុងតំបន់ទំនាបលិចទឹកនេះដែរ។ ជាក់ស្តែង អនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍នេសាទ *មិនបាន* គិតគូរអំពីសមាជិកដែលនឹងត្រូវពាក់ព័ន្ធនៅក្នុងការដាំដំណាំនៅក្នុងកន្លែងនេសាទសហគមន៍ឡើយ។ ទោះជាយ៉ាងណាក៏ដោយ សមាជិកទាំងនោះមិនទំនងជាធ្វើការបែងចែកឱ្យដាច់គ្នាបែបនេះដោយខ្លួនឯងឡើយ។ នៅក្នុងកន្លែងនេសាទសហគមន៍មួយចំនួនតូចអាចមានសមាជិកពឹងផ្អែកស្ទើរតែទាំងស្រុងតែលើការធ្វើនេសាទ។ ស្ថានភាពទាំងនេះប្រហែលជាច្រើនមាននៅតែក្នុងចំណោមកន្លែងនេសាទសហគមន៍នៅក្នុងតំបន់បឹងទន្លេសាបតែប៉ុណ្ណោះ។ បញ្ហាបែបនេះនៅក្នុងតំបន់នានាផ្សេងទៀតនៃផ្ទៃប្រទេស (ប្រសិនបើអាចមានលទ្ធភាពកើតឡើងបានកំពុងកើតឡើង ឬដោយសារប្រជាជនមានបំណងធ្វើបែបនេះ) នឹងត្រូវស្ថិតក្រោមការហាមឃាត់នៃមាត្រានានានៅក្នុងអនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍នេសាទ។ តើភាពមិនប្រក្រតីរវាងស្ថានភាពជាក់ស្តែងនៃប្រព័ន្ធអេកូឡូស៊ី និងកាតព្វកិច្ចតាមផ្លូវច្បាប់ដែលមានចែងនៅក្នុងអនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍នេសាទអាចសម្រុះសម្រួលគ្នាបានតាមវិធីណា? ការប្រឈមដ៏សំខាន់មួយគឺត្រូវបង្កើនការយល់ដឹងគ្រប់ជ្រុងជ្រោយអំពីវិធីដែលប្រជាជនចាប់អារម្មណ៍លើប្រព័ន្ធអេកូឡូស៊ីរបស់ខ្លួន។ ទង្វើនេះក៏ជួយយើងក្នុងការស្វែងយល់ផងដែរ អំពីថាតើប្រព័ន្ធអេកូឡូស៊ី នឹងវិវត្តបែបណានៅក្រោមរបបគ្រប់គ្រងតាមបែបសហគមន៍[10]។

**ប្រអប់ ២: ទិដ្ឋភាពសំខាន់ខ្លះៗនៃអនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍នេសាទ (SDCFM) នៃព្រះរាជរដ្ឋាភិបាលកម្ពុជា**

**តើអ្វីខ្លះជាគោលបំណងនៃសហគមន៍នេសាទ?**

គោលបំណងចំនួនប្រាំមានចែងនៅក្នុងអនុក្រឹត្យនេះ ៖ (ក) គ្រប់គ្រងការនេសាទទឹកសាប និងប្រព័ន្ធអេកូឡូស៊ីពាក់ព័ន្ធ នៅតាមតំបន់ដែលកាត់ចេញពីឡូត៍នេសាទ (ខ) គ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តរភាព និងសមធម៌ (គ) បង្កើនការយល់ដឹង និងការទទួលស្គាល់អំពីអត្ថប្រយោជន៍នៃធនធានជលផលតាមរយៈការចូលរួមការពារ និងគ្រប់គ្រង (ឃ) ផ្តល់ក្របខ័ណ្ឌច្បាប់សម្រាប់បង្កើតសហគមន៍នេសាទ និង (ង) លើកកំពស់ស្តង់ដារនៃការរស់នៅ និងកាត់បន្ថយភាពក្រីក្រ ។

**តើសហគមន៍នេសាទផ្សំឡើងដោយអ្វីខ្លះ ?**

សហគមន៍នេសាទគឺជាក្រុមប្រជាពលរដ្ឋខ្មែរ ដែលរស់នៅក្នុងដែននេសាទ និងនៅជិតដែននេសាទ និងស្ម័គ្រចិត្តបង្កើតឱ្យមានកិច្ចផ្តួច-ផ្តើមដើម្បីសម្រេចគោលបំណងដូចដែលបានចែងខាងលើ។

[10] Keskinen M, 2003 បានធ្វើការបកស្រាយលំអិតអំពីទិដ្ឋភាពមួយចំនួនដែលមានលើកឡើងនៅក្នុងផ្នែកនេះ។

### តើអ្នកណាខ្លះអាចក្លាយជាសមាជិកនៃសហគមន៍នេសាទ?

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលជាអ្នករស់នៅក្នុងភូមិនៃកន្លែងនេសាទសហគមន៍នោះ ដោយមានអាយុចាប់ពី ១៨ ឆ្នាំ ឡើងទៅ និងអាចជាសមាជិកនៅក្នុងសហគមន៍នេសាទតែមួយប៉ុណ្ណោះ ។

### តើសហគមន៍នេសាទមានភារកិច្ចអ្វីខ្លះ?

ចូលរួមក្នុងការគ្រប់គ្រង និងអភិរក្សធនធាន គោរពបទបញ្ជាពីនាយកដ្ឋានជលផល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចូលរួមនៅក្នុងការបង្កើតតំបន់អភិរក្សនៅក្នុងកន្លែងនេសាទសហគមន៍ ធានាសិទ្ធិស្មើភាពនៅក្នុងការប្រើប្រាស់ធនធានដោយនិរន្តរភាព អនុវត្តលក្ខន្តិកៈ និងកសាងផែនការគ្រប់គ្រង ចុះកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ជាមួយនាយកដ្ឋានជលផល ដើម្បីគ្រប់គ្រងធនធាន និងរក្សាទុកគ្រប់ឯកសារដែលទាក់ទងនឹងសហគមន៍នេសាទ ។

### តើសហគមន៍នេសាទមានសិទ្ធិអ្វីខ្លះ?

សិទ្ធិរបស់សហគមន៍នេសាទ គឺការចាត់ចែងសកម្មភាពនេសាទ ធ្វើសហប្រតិបត្តិការជាមួយអាជ្ញាធរមានសមត្ថកិច្ចដើម្បីបង្ក្រាបបទល្មើស លើកសំណើសុំដកហូតវត្ថុតាងនៃការនេសាទខុសច្បាប់ និងឃាត់ខ្លួនអ្នកប្រព្រឹត្តបទល្មើស ដើម្បីបញ្ជូនទៅមន្ត្រីសមត្ថកិច្ចជលផល ។ អនុលោមតាមបរិធានច្បាប់ សហគមន៍នេសាទមួយអាចប្រាស្រ័យទាក់ទងជាមួយសហគមន៍នេសាទផ្សេងទៀត ឬជាមួយរូបវន្តបុគ្គល និងនីតិបុគ្គលនានាផ្សេងទៀត ដើម្បីជាប្រយោជន៍របស់សហគមន៍នេសាទ អាចធ្វើនេសាទ ធ្វើវារីវប្បកម្ម លក់ ប្រើប្រាស់ និងគ្រប់គ្រងធនធានជលផលទាំងអស់ អនុលោមតាមកិច្ចព្រមព្រៀង និងផែនការសហគមន៍នេសាទ។

### តើសិទ្ធិទាំងនេះមានព្រំដែនត្រឹមណា?

សហគមន៍នេសាទពុំមានសិទ្ធិដោះដូរកន្លែងនេសាទសហគមន៍តាមរូបភាពណាមួយឡើយ គ្មានសិទ្ធិកសាងហេដ្ឋារចនាសម្ព័ន្ធ ទោះបែបណាមួយក្តី នៅក្នុងកន្លែងនេសាទសហគមន៍ដោយគ្មានការអនុញ្ញាតពីនាយកដ្ឋានជលផល ឬក្រសួងកសិកម្មឡើយ មិនកាត់ជាចំណែក ឬបង្កើតកម្មសិទ្ធិឯកជននៅក្នុងកន្លែងនេសាទសហគមន៍មិនអាចចុះកិច្ចព្រមព្រៀងណាមួយនៅក្នុងកន្លែងនេសាទសហគមន៍នេសាទជាមួយរូបវន្តបុគ្គល ឬនីតិបុគ្គល សូម្បីតែក្នុងគោលបំណងស្រាវជ្រាវវិទ្យាសាស្ត្រក៏ដោយ ។

### តើគណៈកម្មការសហគមន៍នេសាទនឹងត្រូវបង្កើតឡើងដូចម្តេច ?

សហគមន៍នេសាទនីមួយៗត្រូវដឹកនាំដោយគណៈកម្មការសហគមន៍នេសាទមួយ ដែលត្រូវបានជ្រើសតាំងដោយការបោះឆ្នោត ដោយសម្ងាត់ សេរី និងត្រឹមត្រូវ នៅក្នុងកិច្ចប្រជុំរបស់សហគមន៍ តាមរយៈការជ្រើសរើសយកសម្លេងភាគច្រើនដាច់ខាតក្នុងចំណោមអ្នកដែលបានបោះឆ្នោត ។ បុគ្គលដែលទទួលបានសម្លេងគាំទ្រច្រើនជាងគេ នឹងត្រូវបានតែងតាំងជាប្រធាន ។ បុគ្គលដែលបានទទួលសម្លេងគាំទ្រខ្ពស់ជាងគេទីពីរត្រូវបានជ្រើសតាំងជាអនុប្រធាន។ អាជ្ញាធរសមត្ថកិច្ចជលផល និង ក្រុមប្រឹក្សាឃុំ នឹងត្រូវបានអញ្ជើញចូលរួមដើម្បីសង្កេតការបោះឆ្នោតនេះ។ ទោះជាយ៉ាងណាក៏ដោយ លទ្ធផលនៃការបោះឆ្នោតនេះនឹងត្រូវទទួលស្គាល់ជាផ្លូវការ ទោះបីអ្នកទាំងនោះអវត្តមានក៏ដោយ។ ចំនួនសមាជិកនៃគណៈកម្មការសហគមន៍អាចមានពី ៥ ទៅ ៧ ឬដល់ ១១ រូប អាស្រ័យលើការសម្រេចរបស់អង្គប្រជុំនៃសហគមន៍នេសាទ។ ស្ត្រីត្រូវបានលើកទឹកចិត្តឱ្យចូលរួមជាបេក្ខជន។ ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលជាសមាជិកនៃសហគមន៍នេសាទ មានសិទ្ធិឈរឈ្មោះជាបេក្ខជន។ គណៈកម្មការសហគមន៍ ដែលបានបង្កើតតាមរយៈការបោះឆ្នោតនេះ មានអាណត្តិរយៈពេល ៥ ឆ្នាំ និងមានសិទ្ធិដឹកនាំ និងគ្រប់គ្រង សហគមន៍នេសាទ អនុលោមតាមមាត្រាពាក់ព័ន្ធនៃអនុក្រឹត្យនេះ។

### តើគណៈកម្មការសហគមន៍នេសាទមានភារៈកិច្ចអ្វីខ្លះ?

សហគមន៍នេសាទមានភារកិច្ចដូចតទៅ ៖ តាក់តែងសេចក្តីព្រាងលក្ខន្តិកៈ និងផែនការគ្រប់គ្រង និងអនុវត្តតាមលក្ខន្តិកៈ និងផែនការនោះ ស្វែងរកការគាំទ្របច្ចេកទេស និងហិរញ្ញវត្ថុ ធ្វើជាតំណាងសហគមន៍នេសាទនៅក្នុងការសម្រុះសម្រួល និងដោះស្រាយទំនាស់ បើកគណនី និងគ្រប់គ្រងហិរញ្ញវត្ថុប្រកបដោយតម្លាភាព ធ្វើសេចក្តីសម្រេចអំពីសហគមន៍នេសាទ អនុលោមតាមលក្ខន្តិកៈ ចូលរួមក្នុងការពិគ្រោះយោបល់នានា ធ្វើសេចក្តីរាយការណ៍អំពីបទល្មើស អភិរក្សធនធាន និងកន្លែងនេសាទសហគមន៍អនុវត្តមុខនាទីផ្សេងទៀតតាមការណែនាំរបស់សមត្ថកិច្ចជលផល ធ្វើការលុបចោលកិច្ចព្រមព្រៀងសហគមន៍នេសាទប្រសិនបើសម្រេចមិនបន្តកិច្ចព្រមព្រៀងនោះ។ មានតែគណៈកម្មការសហគមន៍នេសាទទេ ទើបមានសិទ្ធិដាក់ពាក្យទៅនាយកដ្ឋានជលផល ដើម្បីស្នើសុំការអនុម័តឯកភាពលើកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍នេសាទ។ គណៈកម្មការសហគមន៍នេសាទ អាចស្នើសុំការគាំទ្របច្ចេកទេសពីមន្ត្រីជលផល ឬបុគ្គលនានា ដើម្បីរៀបចំសេចក្តីព្រាងកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍។

## តើកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ត្រូវរៀបចំឡើងរបៀបណា?

នីតិវិធីសម្រាប់រៀបចំកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ នឹងត្រូវកំណត់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ នៅក្នុងកិច្ចព្រមព្រៀង និងត្រូវមានភ្ជាប់ជាមួយនូវផែនទីដែលមានមាត្រដ្ឋាន ១/៥០.០០០ បញ្ជីឈ្មោះសមាជិកទាំងអស់ និងសមាជិកគណៈកម្មការសហគមន៍ លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង សេចក្តីថ្លែងការណ៍អំពីគោលបំណងរបស់សហគមន៍នេសាទ។ សេចក្តីព្រាងកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ នឹងត្រូវប្រកាសផ្សាយ និងបិទផ្សាយរយៈពេល ៣០ ថ្ងៃ នៅក្នុងទីសាធារណៈដែលងាយមើលឃើញ (ការិយាល័យឃុំ/សង្កាត់ ស្រុក/ខណ្ឌ) និងតាមការិយាល័យនានារបស់រដ្ឋាភិបាល និងដាក់ជូនទៅនាយកដ្ឋានជលផល ដើម្បីពិនិត្យ និងសម្រេច។ ប្រសិនបើមានការជំទាស់ចំពោះសេចក្តីប្រកាសផ្សាយនោះ នៅក្នុងអំឡុងពេលនោះ ក្រុមប្រឹក្សាឃុំ/សង្កាត់ ឬអាជ្ញាធរស្រុក/ខណ្ឌ ឬ ខេត្ត/ក្រុង ត្រូវជួយដោះស្រាយទំនាស់ និងកែសម្រួលកិច្ចព្រមព្រៀងនោះ។ កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍នេសាទមានសុពលភាពសម្រាប់រយៈពេលមិនលើសពី៣ ឆ្នាំ គិតចាប់ពីថ្ងៃចុះហត្ថលេខាឯកភាពដោយនាយកដ្ឋានជលផល។ គណៈកម្មការសហគមន៍នេសាទត្រូវដាក់ជូនសំណើជាលាយល័ក្ខអក្សរដើម្បីសុំ បន្តរយៈពេលសុពលភាពនៃកិច្ចព្រមព្រៀង នៅក្នុងរយៈពេល ៦ ខែ មុនអស់សុពលភាពនៃកិច្ចព្រមព្រៀងនោះ ហើយកិច្ចព្រមព្រៀងថ្មីនេះនឹងមានសុពលភាពមិនលើសពីរយៈពេលបីឆ្នាំបន្ថែមទៀតឡើយ។ រាល់សំណើសុំបន្តសុពលភាពកិច្ចព្រមព្រៀង នឹងត្រូវចុះហត្ថលេខាអនុម័តដោយនាយកដ្ឋានជលផល ក្នុងរយៈពេល ៣០ ថ្ងៃ នៃការអស់សុពលភាពនៃកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍។ ប្រសិនបើនាយកដ្ឋានជលផលបញ្ឈប់កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ នាយកដ្ឋាននេះត្រូវបញ្ជូនរបាយការណ៍ដែលបានរៀបចំឡើងដោយផ្អែកលើការវាយតម្លៃពីអាជ្ញាធរសមស្រប និងដោយមានការចូលរួមពីគណៈកម្មការសហគមន៍នេសាទដើម្បីពន្យល់ពីមូលហេតុនៃការសម្រេចនោះ។ ប្រសិនបើនាយកដ្ឋានជលផលមិនបានធ្វើសេចក្តីជូនដំណឹងឆ្លើយតបនឹងសំណើសុំបន្តរយៈពេលសុពលភាពនៃកិច្ចព្រមព្រៀងនៅក្នុងរយៈពេល ៣០ថ្ងៃ កិច្ចព្រមព្រៀងនោះនឹងត្រូវចាត់ទុកថាទទួលបានការអនុម័តឯកភាពឱ្យបន្តជាផ្លូវការ។

## តើអាចទុកកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ជាមោឃៈដែរឬទេ?

កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍អាចទុកជាមោឃៈ មុនពេលអស់សុពលភាព នៅក្រោមលក្ខខណ្ឌណាមួយដូចខាងក្រោមនេះ: ព្រមព្រៀងជាលាយល័ក្ខអក្សររវាងភាគីទាំងអស់អំពីការលុបចោលនេះ ការព្រមព្រៀងក្នុងចំណោមគណៈកម្មការសហគមន៍នេសាទ និងពីរភាគបីនៃចំនួនសមាជិកសហគមន៍ដោយសារការខកខានមិនបានអនុវត្ត និងដោយសារការរំលោភលើកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ដែលនៅជាធរមានដែលបង្កគ្រោះថ្នាក់ចំពោះធនធានដោយសារការវិនិច្ឆ័យរបស់រាជរដ្ឋាភិបាលក្នុងការដាក់តំបន់នោះដើម្បីជាប្រយោជន៍ខ្ពស់ជាងមុនសម្រាប់សាធារណៈ និងសង្គម ។ ក្នុងករណីនៃហេតុផលចុងក្រោយនេះ នាយកដ្ឋានជលផលត្រូវធ្វើសេចក្តីជូនដំណឹងជាលាយល័ក្ខអក្សរទៅគណៈកម្មការសហគមន៍ក្នុងរយៈពេល ៦ ខែ មុនការបញ្ឈប់កិច្ចព្រមព្រៀងនោះ ដោយបង្ហាញពីហេតុផលនៃការធ្វើបែបនោះ។ នៅក្នុងអំឡុង

ពេលនោះ នាយកដ្ឋានជលផលត្រូវពិភាក្សាជាមួយគណៈកម្មការសហគមន៍នេសាទអំពីកិច្ចការ និងការខូចបង់ចំពោះសហគមន៍ដែលកើតឡើងពីចំណាត់ការបែបនោះ ។

**តើផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ត្រូវរៀបចំឡើងដូចម្តេច?**

ក្រោយការអនុម័តឯកភាពលើកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ គណៈកម្មការសហគមន៍នេសាទអាចរៀបចំផែនការគ្រប់គ្រង និងស្នើសុំជំនួយបច្ចេកទេសពីអាជ្ញាធរសមត្ថកិច្ចជលផល ។ នីតិវិធីសម្រាប់រៀបចំផែនការនេះនឹងមានចែងនៅក្នុងសេចក្តីប្រកាសរបស់ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ។ ត្រូវដាក់ជូនផែនការនេះទៅនាយកដ្ឋានតាមបែបបទត្រឹមត្រូវ។ រយៈពេលសុពលភាពនៃផែនការនេះត្រូវមានដូចគ្នានឹងរយៈពេលសុពលភាពនៃកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ដែរ ។ ផែនការនេះនឹងត្រូវពិនិត្យឡើងវិញដោយការិយាល័យជលផលខេត្ត/ស្រុក ជារៀងរាល់ឆ្នាំ និងធ្វើសេចក្តីរាយការណ៍ទៅនាយកដ្ឋានជលផល។ ការត្រួតពិនិត្យ តាមដាន និងវាយតម្លៃអំពីការអនុវត្តផែនការនេះនឹងត្រូវធ្វើឡើងដោយមានការចូលរួមពីតំណាងរបស់គណៈកម្មការសហគមន៍នោះ។ នាយកដ្ឋានជលផលអាចតម្រូវឱ្យធ្វើការកែសម្រួលផែនការនោះ ដើម្បីឱ្យស្របតាមបរិធានច្បាប់នានាដែលពាក់ព័ន្ធនឹងវិស័យជលផល ដើម្បីធានានិរន្តរភាពនៃដែននេសាទនោះ ។

**តើសហគមន៍នេសាទអាចទទួលហិរញ្ញវត្ថុពីប្រភពណាខ្លះ?**

សហគមន៍នេសាទអាចទទួលហិរញ្ញវត្ថុពីៈ វិភាគទានរបស់សមាជិក អំណោយ ជំនួយពីរាជរដ្ឋាភិបាលកម្ពុជាពីអង្គការអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាល និងពីប្រាក់ចំណូលស្របច្បាប់ដទៃទៀត ។

## ៣.៤ ការវាយតម្លៃអំពីការផ្លាស់ប្តូរនៅក្នុងអន្តរកាល

មានការជជែកវែកញែកជាច្រើនអំពីនិន្នាការនៃផលនេសាទ នៅក្រោយមានការផ្លាស់ប្តូរទៅសហគមន៍នេសាទ។ មានការអះអាងថា កំណើននៃការនេសាទ (កំណើនចំនួនមង និងទូកនេសាទ) និងការប្រើប្រាស់វិធីនេសាទល្មើសច្បាប់ (ឧទាហរណ៍ៈ មងក្រឡាតូច ការប្រើអគ្គិសនីឆក់ត្រី) បាននាំឱ្យផលនេសាទថយចុះ។ វិធីសាស្ត្រនានាសម្រាប់ការប្រមូលទិន្នន័យអំពីផលនេសាទពុំអាចយកជាការបានជាទូទៅឡើយ ។ ការវាយតម្លៃអំពីការផ្លាស់ប្តូរទាំងនេះ តាមរយៈការធ្វើអង្កេតអ្នកនេសាទដោយផ្ទាល់ក៏មិនទំនងជាផ្តល់ចម្លើយដែលអាចយកជាការបាននោះឡើយ ។ ការអង្កេតទៅលើសកម្មភាពមុនការប្រមូលផល (ការបង្កើតឧបករណ៍នេសាទ និងបរិក្ខារបន្ទាប់បន្សំ) និងសកម្មភាពក្រោយការប្រមូលផល (ការកែច្នៃ និងជួញដូរផលនេសាទ) នឹងផ្តល់ជូននូវការវិនិច្ឆ័យប្រសើរជាងមុនអំពីបញ្ហាទាំងនេះ ។

ឧទាហរណ៍ៈ ប្រសិនបើយើងអាចវាយតម្លៃអំពីបរិមាណ និងប្រភេទអួនដែលបានផលិត យើងនឹងអាចឈានទៅទទួលចម្លើយពេញលេញជាងមុន អំពីនិន្នាការនៃការធ្វើនេសាទ និងប្រភេទនៃការធ្វើនេសាទល្មើសច្បាប់ ប្រសិនបើមាន ។ ការធ្វើបែបនេះ ក៏នឹងជួយបង្ហាញអំពីកំណើនការនេសាទ ដែលបណ្តាលពីកំណើនការងារសម្រាប់ស្ត្រី និងបុរស នៅក្នុងសកម្មភាពផលិតអួនផងដែរ។ ទន្ទឹមនឹងកំណើនការងារដែលអាចត្រូវបានមើលឃើញថាជាទិដ្ឋភាពវិជ្ជមាន និងដែលចង់បានផលប៉ះពាល់បណ្តាលពីកំណើនចំនួនអួនទៅលើធនធានក៏ត្រូវតែវិជ្ជមានផងដែរ។ ការកាប់ដើមត្នោតចាស់ៗសម្រាប់ធ្វើទូក ក៏អាចជាការចង្អុលបង្ហាញអំពីកំណើនសកម្មភាពនេសាទផងដែរ ។ ស្រដៀងគ្នានេះដែរ ការវាយតម្លៃអំពីបញ្ហានៃកំណើនការនេសាទដោយប្រើប្រាស់អគ្គិសនីឆក់ត្រី ក៏អាចធ្វើបានយ៉ាងងាយស្រួលផងដែរ នៅក្នុងទីកន្លែងដែលលក់ និងបញ្ចូលអាគុយសម្រាប់គោលបំណងនេះផងដែរ ។

គួធ្វើការអង្កេតអំពីការប្រែប្រួលដែលអាចកើតមានឡើងទាក់ទងនឹងទំហំ និងប្រភេទនៃផលនេសាទតាមរយៈការសង្កេតលើបណ្ដាអ្នកដែលពាក់ព័ន្ធនៅក្នុងសកម្មភាពក្រោយការធ្វើនេសាទ ដូចជា ការកែច្នៃ និងការជួញដូរផលនេសាទ។ អ្នកទាំងនោះគួរតែជាមនុស្សដំបូងបំផុតដែលចាប់អារម្មណ៍អំពីការប្រែប្រួលនូវប្រភេទ និងបរិមាណនៃផលនេសាទដោយសារវាមានទំនាក់ទំនងជាមួយគុណភាព និងថ្លៃចំណាយលើប្រតិបត្តិការទាំងនោះ។ ប្រសិនបើឈ្មួញតូចតាច ទីផ្សារនៅជនបទ និងគ្រួសារដែលស្ថិតនៅជិតសហគមន៍នេសាទ ធ្វើសេចក្ដីរាយការណ៍អំពីវត្តមានត្រីច្រើន (ប្រភេទ ទំហំ និងបរិមាណ) នេះគឺជាសញ្ញាអំពីការប្រមូលផលតាមបែបវិមជ្ឈការ និងទ្រង់ទ្រាយតូចផងដែរ។ ការវាយតម្លៃអំពីសកម្មភាពជំនួញរបស់ឈ្មួញដែលធ្លាប់ដឹកជញ្ជូនផលនេសាទក្នុងបរិមាណច្រើនពីឡូត៍នេសាទ ក៏ជាការចង្អុលបង្ហាញផងដែរអំពីការបាត់បង់ដែលកើតឡើង បណ្ដាលពីការផ្លាស់ប្ដូរទំហំនៃការនេសាទផងដែរ ពោលគឺ ពីផែផ្ទេរផលនេសាទដែលមានលក្ខណៈប្រមូលផ្ដុំ និងទ្រង់ទ្រាយធំ ទៅផែផ្ទេរផលនេសាទតូចៗរបស់សហគមន៍នេសាទដែលស្ថិតនៅរាយប៉ាយតាមកន្លែងជាច្រើន។ ការប្រែប្រួលក៏អាចមានផងដែរ ទៅលើសមាសភាគប្រភេទនៅក្នុងផលនេសាទ ឧទាហរណ៍ៈ ការថយចុះប្រភេទត្រី ដូចជា *ត្រីរៀល* ដែលតែងតែនេសាទបាននៅក្នុងឧបករណ៍នេសាទខ្នាតធំ។ ការថយចុះនៃសកម្មភាពឈ្មួញធំៗដែលជាអ្នកជួញផលនេសាទ ក៏អាចមានន័យថាការផ្គត់ផ្គង់ផលនេសាទទៅអ្នកប្រើប្រាស់ដែលស្ថិតនៅតំបន់ដាច់ស្រយាល ត្រូវថយចុះផងដែរ។ ទោះបីប្រការនេះមានផលប៉ះពាល់អវិជ្ជមាន ទៅលើអត្រានៃការបរិភោគត្រី ឬមិនមានឥទ្ធិពលក្ដី ចាំបាច់ត្រូវធ្វើការអង្កេតអំពីប្រការនេះ [11] ។

មិនមែនគ្រប់ការប្រែប្រួលដែលបានវាយតម្លៃឃើញ និងដែលបានរាយការណ៍ សុទ្ធតែទាក់ទងនឹងការផ្លាស់ប្ដូរស្ថាប័នដែលកើតឡើងពីកំណែទម្រង់វិស័យជលផលនាពេលបច្ចុប្បន្ននេះទេ។ ការផ្លាស់ប្ដូរខ្លះ អាចជាលទ្ធផលនៃការប្រែប្រួលប្រព័ន្ធអេកូឡូស៊ីទៅលើវិសាលភាពធំនៃតំបន់ផ្ទៃរងទឹកភ្លៀងនៃទន្លេមេគង្គ និងលក្ខខណ្ឌនានាដូចជា ការផ្លាស់ប្ដូររបបទឹកភ្លៀង និងលក្ខខណ្ឌរាំងស្ងួតដែលមានឥទ្ធិពលទៅលើផលិតកម្មកសិកម្ម និងវាសនារបស់កសិករ។ មានផ្នែកជាច្រើនដែលគួរធ្វើការស្រាវជ្រាវទាក់ទងនឹងសេដ្ឋកិច្ចសង្គម។

## ៣.៥ ការបង្កើតសកម្មភាពនេសាទដែលអាចមើលឃើញ

អនុក្រឹត្យស្ដីពីការគ្រប់គ្រងសហគមន៍អនុញ្ញាតឱ្យសមាជិកសហគមន៍ធ្វើនេសាទតែក្រោមរូបភាពជាលក្ខណៈគ្រួសារ អនុលោមតាមច្បាប់ (មាត្រា ១៣)។ ទោះជាយ៉ាងណាក្ដី ពន្ធលើការនេសាទសិប្បកម្មត្រូវបានដាក់ជានិរាករណ៍តាមរយៈបទបញ្ជាមួយផ្សេងទៀតរបស់រដ្ឋាភិបាល។ ដូច្នេះ ប្រការនេះមានន័យថាបុគ្គលនានាដែលបានប្រើប្រាស់ឧបករណ៍នេសាទខ្នាតមធ្យមត្រូវតែបោះបង់ចោលការនេសាទបែបនេះ ប្រសិនបើអ្នកទាំងនោះចង់ក្លាយជាសមាជិកសហគមន៍នេសាទ។ នេះជាការរំពឹងទុកដែលគ្មានភាពប្រាកដនិយមដោយសារភាពខុសគ្នាខ្លាំងនៃផលទទួលបានរវាងការនេសាទខ្នាតតូច និងខ្នាតមធ្យម។ ការប៉ាន់ប្រមាណ (ធ្វើឡើងនៅឆ្នាំ ១៩៩៥-៩៦) អំពីផលនេសាទប្រចាំឆ្នាំតាមគ្រួសារ ដែលប្រើប្រាស់ឧបករណ៍នេសាទសិប្បកម្ម មាន

---

[11] ការផ្លាស់ប្ដូរពីប្រព័ន្ធឡូត៍នេសាទទៅសហគមន៍នេសាទ នឹងនាំឱ្យមានការប្រែប្រួលការប្រើប្រាស់ និងទំហំនៃទម្លាប់ដោះដូរជាលក្ខណៈប្រពៃណី រវាងអង្ករសម្រាប់ត្រី ក្នុងចំណោមកសិករនៅតំបន់ខ្ពស់ និងអ្នកនេសាទនៅក្នុងបឹងទន្លេសាប។ ការផ្លាស់ប្ដូរនេះអាចជាការចង្អុលបង្ហាញ អំពីការផ្លាស់ប្ដូរទូលំទូលាយនូវលទ្ធភាពរបស់ប្រជាពលរដ្ឋក្នុងទទួលបានប្រូតេអ៊ីនដែលជាប្រភពប្រូតេអ៊ីន និងផលវិបាកដែលកើតឡើងបណ្ដាលពីស្ថានភាពផ្លាស់ប្ដូរខាងអាហាររូបត្ថម្ភនេះ។

ប្រមាណ ៣៣០០ គ.ក្រ /ឆ្នាំ ធៀបនឹង ៦៤០គ.ក្រ/ឆ្នាំ សម្រាប់គ្រួសារដែលប្រើប្រាស់ឧបករណ៍នេសាទសិប្បកម្ម (Ahmed et al, 1998) ។ ទោះបីតួលេខអំពីផលនេសាទប្រចាំឆ្នាំអាចប្រែប្រួលនៅក្នុងអំឡុងពេលនៃទសវត្សរ៍នេះក្តី ភាពប្រែប្រួល (អត្រា ៥:១) រវាងសមត្ថភាពនេសាទនៃឧបករណ៍នេសាទពីរបែបនេះ មិនទំនងជាប្រែប្រួលឡើយ។ ការស្នើឱ្យគ្រួសារដែលប្រើប្រាស់ឧបករណ៍នេសាទសិប្បកម្មបោះបង់ចោលទម្លាប់របស់ខ្លួន ជាលក្ខខណ្ឌប្តូរនឹងការចូលរួមជាមួយសហគមន៍នេសាទ ពិតជាពុំមានភាពប្រាកដនិយមឡើយ។ ឥទ្ធិពលនៃការផ្លាស់ប្តូរនេះស្ថិតនៅត្រង់ថា គ្រួសារនានានៅក្នុងកន្លែងនេសាទសហគមន៍ណាមួយ ដែលធ្លាប់បានប្រើប្រាស់ឧបករណ៍នេសាទសិប្បកម្ម នឹងពុំអាចក្លាយជាសមាជិករបស់សហគមន៍នេសាទឡើយ។ ប្រសិនបើពួកគេចង់នៅបន្តធ្វើការនេសាទ ពួកគេអាចត្រូវបង្ខំចិត្តឱ្យប្រព្រឹត្តបែបនោះដោយល្មើសច្បាប់!

ដោយហេតុថា ស្ថានភាពសេដ្ឋកិច្ចសង្គម រវាងគ្រួសារនានាដែលធ្វើការនេសាទទ្រង់ទ្រាយតូច និងគ្រួសារដែលធ្វើនេសាទសិប្បកម្ម ទំនងជាមានភាពខុសគ្នាខ្លាំង ការដាក់កំហិតចំពោះអ្នកនេសាទសិប្បកម្មមិនឱ្យចូលនេសាទនៅក្នុងដែននេសាទសហគមន៍ អាចមានឥទ្ធិពលអវិជ្ជមានចំពោះជីវភាពរស់នៅរបស់គ្រួសារទាំងនោះ។ ការធ្វើបែបនេះ ក៏នឹងអាចបង្កើតឱ្យមានទំនាស់ថ្មីផងដែរនៅក្នុងភូមិ និងរវាងអ្នកនេសាទ ។

ការដោះស្រាយទ្វេគ្រោះទាំងនេះគឺជាការប្រឈមមួយ។ នេះមានន័យថា ទោះជាការអនុញ្ញាតឱ្យអ្នកនេសាទសិប្បកម្មចូលធ្វើការនេសាទនៅក្នុងតំបន់នេសាទសហគមន៍ ឬពង្រីកនិយមន័យការនេសាទជាលក្ខណៈគ្រួសារដើម្បីរួមបញ្ចូលភាគច្រើននៃឧបករណ៍នេសាទសិប្បកម្មដែលមានការអនុញ្ញាតទៅក្នុងក្រុមជាមួយគ្នា ក៏សុទ្ធជាការប្រឈមដែរ។ នេះគឺជាជំហានចំបងក្នុងការបង្កើតសកម្មភាពនេសាទដែលអាចមើលឃើញ និងជាវិធានការជំរុញខាងគោលនយោបាយដើម្បីពង្រឹងផលនេសាទទឹកសាបឱ្យមានសមភាព និងនិរន្តរភាព នៅក្រោមការចាត់ចែងស្ថាប័នសហគមន៍នេសាទ។

## ៣.៦ ពង្រីកកាលានុវត្តភាពសេដ្ឋកិច្ច និងតួនាទីនៃទីផ្សារ

ប្រសិនបើគោលបំណងពិតប្រាកដនៃសហគមន៍នេសាទ គឺការកែលំអការរស់នៅ (មាត្រា ២) របស់សមាជិកសហគមន៍ក្នុងករណីនេះ សមាជិកទាំងនោះត្រូវតែធ្វើការពង្រីកជាបណ្តើរៗនូវសកម្មភាពរបស់ខ្លួន ដើម្បីរួមបញ្ចូលមិនត្រឹមតែការប្រមូលផលត្រីសម្រាប់បរិភោគក្នុងគ្រួសារតែប៉ុណ្ណោះទេ។ ការរួមបញ្ចូលទិដ្ឋភាពមួយស្តីពីការអភិវឌ្ឍសហគ្រាសមានសារៈសំខាន់ជាអាយុជីវិតដើម្បីសម្រេចគោលបំណងខាងលើ។ នេះមានន័យថា ដើម្បីឱ្យកំណែទម្រង់ផលផលបានទទួលជោគជ័យ និងអាចធ្វើការសន្និដ្ឋានបានសមរម្យទោះមុនឬក្រោយត្រូវតែធ្វើឱ្យមានរូបរាងឡើងនូវគ្រប់សកម្មភាពដែលមានចែងនៅក្នុងមាត្រា១១ នៃអនុក្រឹត្យ ស្តីពីការគ្រប់គ្រងសហគមន៍នេសាទ "នេសាទត្រី ធ្វើវារីវប្បកម្ម ប្រមូលផល លក់ ប្រើប្រាស់ និងគ្រប់គ្រងធនធានជលផលទាំងអស់ អនុលោមតាមកិច្ចព្រមព្រៀង និង ផែនការគ្រប់គ្រងតំបន់នេសាទសហគមន៍" ។ ការស្វែងយល់អំពីសកម្មភាពខ្លះៗ ក្នុងចំណោមសកម្មភាពទាំងនេះទាមទារឱ្យមានរចនាសម្ព័ន្ធចាត់ចែងថ្មីដូចជា ការចាត់ចែងដើម្បីកែច្នៃ និងលក់ផលត្រីដែលសមាជិកសហគមន៍ធ្វើនេសាទបាន ប៉ុន្តែបច្ចុប្បន្នពុំមានចែងនៅក្នុងអនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍នេសាទឡើយ។ ទោះជាយ៉ាងណាក៏ដោយ ការដាក់បញ្ចូលសកម្មភាពទាំងនេះទៅក្នុងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ទំនងជាអាចធ្វើទៅ បាន

(មាត្រា២៨)។ ការិយាល័យអភិវឌ្ឍន៍សហគមន៍នេសាទនៅក្នុងនាយកដ្ឋានជលផលគួរចាត់វិធានការដើម្បីរំពឹងទុក និងគ្រោងជាមុនអំពីលទ្ធភាព នៃសកម្មភាពបែបនេះនៅក្នុងសហគមន៍នេសាទដែលអនុវត្តបានជោគជ័យ[12] ។

ប្រសិនបើគោលបំណងពិតប្រាកដនៃសហគមន៍នេសាទ គឺការកែលំអការរស់នៅ (មាត្រា ២) របស់សមាជិកសហគមន៍ ក្នុងករណីនេះសមាជិកទាំងនោះត្រូវតែធ្វើការពង្រីកជាបណ្តើរៗនូវសកម្មភាពរបស់ខ្លួនដើម្បីរួមបញ្ចូលមិនត្រឹមតែការប្រមូលផលត្រីសម្រាប់បរិភោគក្នុងគ្រួសារតែប៉ុណ្ណោះទេ។

ការសិក្សានានាគួរតែត្រូវបានអនុវត្ត ហើយគួរឱ្យមានការអនុវត្តគម្រោងបង្ហាញដើម្បីពិនិត្យមើលអត្ថិភាពនៃសកម្មភាពតាមបែបវិមជ្ឈការអំពីការកែច្នៃ និងលក់ផលនេសាទនៅមុន និងនៅក្រោយការប្រមូលផល។ គួរធ្វើការវាយតម្លៃអំពីទំហំនៃវារីវប្បកម្មខ្នាតតូច នៅតាមរដូវ ឬអចិន្ត្រៃយ៍ ។ វិធីនានា ដែលអាចដាក់បញ្ចូលជាមួយគ្នានូវសកម្មភាពកសិកម្ម និងនេសាទខ្នាតតូច ដោយពុំបង្កការគំរាមកំហែងចំពោះប្រព័ន្ធអេកូឡូស៊ី ពុំបង្កទំនាស់ខាងសង្គម និងសេដ្ឋកិច្ច អាចជាផ្នែកមួយដែលគួរធ្វើការស្រាវជ្រាវឱ្យបានច្រើនជាបន្ថែមទៀត (Srun Lim Song et al, 2004) ។ បទពិសោធន៍នៅក្នុងតំបន់ទន្លេមេគង្គ អាចផ្តល់ជាគំរូល្អៗអំពីលទ្ធភាពខាងបច្ចេកវិទ្យា ប៉ុន្តែអាចត្រូវការឱ្យធ្វើការកែតម្រូវដើម្បីឱ្យសមស្របជាមួយភាពជាក់ស្តែងនៃស្ថាប័ននៅក្នុងប្រទេសកម្ពុជា។

គួរតែធ្វើការពិនិត្យមើលនូវទំហំនៃការយកចិត្តទុកដាក់ឱ្យបានច្រើនបន្ថែមទៀតអំពីតម្លៃនៃការមិនប្រើប្រាស់នៃធនធានជលផល ដូចជា ភាពទាក់ទាញប្រជាជន (អ្នកទេសចរ) ឱ្យទស្សនាត្រី និងទឹក ជាងធ្វើការនេសាទត្រីនៅក្នុងសហគមន៍នេសាទខ្លះៗនៅក្នុងបឹងទន្លេសាប។ ក្នុងករណីដែលលទ្ធភាពសម្រាប់ការនេសាទដើម្បីជាការកំសាន្ត អាចរកប្រាក់ចំណូលសម្រាប់សហគមន៍នេសាទគួរតែធ្វើការកំណត់ផងដែរអំពីគំរូនានាទាក់ទងនឹងកន្លែងនេសាទសហគមន៍ រដូវ និងពេលវេលា បរិមាណត្រីអនុញ្ញាតឱ្យនេសាទ និងការយកកម្រៃ។

នៅក្នុងបរិបទនៃជំនួយឥណទានអភិវឌ្ឍន៍អន្តរជាតិសម្រាប់រដ្ឋាភិបាលដើម្បីជម្រុញរបៀបវារៈអំពីកំណែទម្រង់វិស័យជលផល ការពិចារណាអំពីការប្រឈមនៅក្នុងការពង្រីកការចានុវត្តភាពសេដ្ឋកិច្ច និងការបង្កើនទ្រព្យសម្បត្តិសម្រាប់សង្គម នៅក្នុងសហគមន៍ គឺជាប្រការសំខាន់របស់ជាតិ[13] ។

ការបង្កើតឱ្យមានសកម្មភាពនេសាទដែលមានអត្ថិភាពបាន និងដែលអាចពង្រីកការចានុវត្តភាពសេដ្ឋកិច្ចនឹងធ្វើឱ្យសហគមន៍កាន់តែពង្រីកទំនាក់ទំនងជាមួយទីផ្សារបានច្រើនជាងពីមុន។ ភាគច្រើននៃផលដែលសហគមន៍នេសាទបានទទួលកាលពីអតីតកាលមានត្រឹមតែសេដ្ឋកិច្ចគ្រួសារដោយមានអន្តរកម្មតិចតួចជាមួយទីផ្សារ។ កំណើនលទ្ធភាពប្រើប្រាស់ធនធានជលផល

---

12 សក្តានុពលសម្រាប់សកម្មភាពនៅក្រៅកសិដ្ឋាន និងសកម្មភាពមិនទាក់ទងនឹងកសិដ្ឋាន នៅក្នុងប្រទេសកម្ពុជា ត្រូវបានចាត់ទុកថាមានសក្តានុពលយ៉ាងខ្លាំងសម្រាប់ការបង្កើតការងារជាច្រើនដែលផ្តល់កម្រៃ ( Acharya, 2003) ។

13 ប្រសិនបើប្រាក់កម្ចីបានទទួលពីធនាគារអភិវឌ្ឍន៍អាស៊ី និងពីស្ថាប័នផ្សេងទៀត មិនយកមកប្រើប្រាស់ក្នុងគោលដៅធ្វើឱ្យកូនចៅទៅអនាគតជាប់ជំពាក់ដោះស្រាយមិនរួចទេនោះ កំណែទម្រង់នេះត្រូវតែបង្កើតឱ្យមានកំណើនសេដ្ឋកិច្ចដែលជាបំណងប្រាថ្នារបស់សង្គមឱ្យបានច្រើនលើសពីតម្រូវការ តែមិនពុំគ្រាន់តែធ្វើឱ្យប្រជាពលរដ្ឋបានទទួលត្រឹមតែការប្រុងប្រុងក្នុងគ្រួសារតាមរយៈការនេសាទគ្រួសារនោះទេ។

ក្នុងចំណោមប្រជាពលរដ្ឋចំនួនច្រើននឹងនាំឱ្យមានកំណើនអន្តរកម្មជាមួយទីផ្សារសម្រាប់អ្នកទទួលផលថ្មីៗទាំងនេះ។ ធៀបនឹងមុខទំនិញដទៃទៀត ធនធានជលផលមានទំនោរយ៉ាងច្រើនទៅរកការជួញដូរនៅក្នុងទីផ្សារ ដោយសារការហូបចុកផលិតផលនេះនៅក្នុងគ្រួសារមានព្រំដែនកំណត់ហើយផលនេសាទងាយខូចខាតនៅក្នុងរយៈពេលខ្លី។ ទន្ទឹមនឹងវត្តមានទីផ្សារសម្រាប់ផលិតផលនេះ លទ្ធភាពប្រើប្រាស់ធនធានជលផល ក៏បង្កើនអន្តរកម្មជាមួយទីផ្សារផងដែរដើម្បីបង្កើតធាតុចូល (បរិក្ខារ និងឧបករណ៍នេសាទ។ល។) និងទីផ្សារឥណទាន (ប្រាក់កម្ចីសម្រាប់ទិញបរិក្ខារនានា)។ ជួនកាល ការផ្តោតតែលើទីផ្សារទាំងនេះដែលអាចបង្កគ្រោះថ្នាក់ចំពោះផលិតករ និងនាំឱ្យមានការកេងប្រវ័ញ្ច។ ឧទាហរណ៍: ប្រសិនបើទីផ្សារឥណទានមានទំនាក់ទំនងជាមួយទីផ្សារសម្រាប់ផលិតផលសម្រេចចំណងទាក់ទងបែបនេះអាចធ្វើឱ្យផលិតករត្រូវលក់ត្រីដែលខ្លួននេសាទបានដោយតម្លៃថោក។ នៅពេលមានការពង្រីកសកម្មភាពសេដ្ឋកិច្ចរបស់សហគមន៍នេសាទ ការជ្រៀតចូលនៃទីផ្សារទៅក្នុងជីវិតរស់នៅរបស់អ្នកទទួលផលនានាក៏នឹងកើនឡើងផងដែរ។ ការប្រឈមស្ថិតនៅត្រង់ថាតើធ្វើបែបណាឱ្យយន្តការទីផ្សារនេះមានលក្ខណៈត្រឹមត្រូវ និងងាយប្រើប្រាស់។ គោលដៅនេះអាចសម្រេចទៅបានតាមរយៈកិច្ចសហការរវាងសហគមន៍ជាមួយរដ្ឋ។ ចំណាត់ការរួមគ្នាដែលគាំទ្រដោយច្បាប់គឺជាគន្លឹះចំបង។

នៅពេលមានការពង្រីកសកម្មភាពសេដ្ឋកិច្ចរបស់សហគមន៍នេសាទ ការជ្រៀតចូលនៃទីផ្សារទៅក្នុងជីវិតរស់នៅរបស់អ្នកទទួលផលនានាក៏នឹងកើនឡើងផងដែរ។ ការប្រឈមស្ថិតនៅត្រង់ថា តើធ្វើបែបណាឱ្យយន្តការទីផ្សារនេះមានលក្ខណៈត្រឹមត្រូវ និងងាយប្រើប្រាស់។

### ៣.៧ ការកំណត់អត្តសញ្ញាណការកសាងសហគមន៍

តើគួរកំណត់និយមន័យសហគមន៍នៅជិតជាប់ដែនទឹក ដែលកើតឡើងថ្មីនេះតាមរបៀបណា? តើសមាជិករបស់សហគមន៍នេសាទដែលបានបង្កើតថ្មីមើលឃើញខ្លួនឯងថាជាអ្នកនេសាទដែលធ្វើកសិកម្ម ឬ ជាកសិករដែលធ្វើនេសាទ។ តើអត្តសញ្ញាណបឋមរបស់អ្នកទាំងនោះជាអត្តសញ្ញាណដែលឆ្លុះបញ្ចាំងអំពីទីកន្លែង ស្ថានភាពសេដ្ឋកិច្ច សកម្មភាពសេដ្ឋកិច្ច ឬជនជាតិ?

ប្រវត្តិនាពេលថ្មីៗនេះនៃប្រទេសកម្ពុជា បានកត់សំគាល់ដោយសេចក្តីទុក្ខវេទនា និងអំពើប្រល័យពូជសាសន៍ធ្ងន់ធ្ងរ។ នៅក្នុងរបបខ្មែរក្រហម ការលំបាកទាំងនេះបានកើតឡើងទន្ទឹមជាមួយការជំលៀសប្រជាពលរដ្ឋទៅជនបទពីលំនៅស្ថានរបស់ខ្លួន និងការបំបាត់ចោលស្ថាប័នប្រពៃណី ដូចជា វត្តអារាម ដែលផ្តល់ឱ្យប្រជាពលរដ្ឋនូវអារម្មណ៍អំពីទីកន្លែង អត្តសញ្ញាណ និងសហគមន៍។ ការរំដោះប្រទេសពីរបបខ្មែរក្រហមដោយវៀតណាម បានកើតឡើងដោយនៅជាប់ជាមួយអារម្មណ៍ចម្រុះ ជាពិសេសនៅពេលនិយាយដល់អារម្មណ៍អវិជ្ជមានដ៏ខ្លាំងក្លានៃប្រជាជនខ្មែរអំពីអ្នករំដោះខ្លួន។

តើអាចធ្វើការអធិប្បាយ ភូមិនានានៅក្នុងប្រទេសកម្ពុជា ថាជាអង្គភាពមួយដែលមានទំនាក់ទំនងផ្ទៃក្នុងស្អិតរមួតដាច់ពីមជ្ឈដ្ឋានក្រៅ ឬគ្រាន់តែជារចនាសម្ព័ន្ធរដ្ឋបាលឃុំដែលមានប្រជាពលរដ្ឋរស់នៅរួមគ្នា? (Guiseppe, 2000) ។ ទោះបីសង្គមខ្មែរអាចជាសង្គមដែលមានប្រពៃណីពឹងផ្អែកតែលើខ្លួនឯងក្តី (គ្រួសារនីមួយៗនៅតែឯង) យើងនៅតែអាចរកឃើញក្រុមមួយ

ចំនួនដែលរស់នៅដោយឯករាជ្យ នៅក្នុងភូមិមួយដោយផ្អែកលើភាពជាញាតិសណ្ដាន និងមិត្តភាពផងដែរ (Best, 2005) ។ វត្ត ក៏អាចត្រូវបាន និងនៅតែបន្តដើរតួនាទីជាកម្លាំងបង្រួបបង្រួមនៅក្នុងសហគមន៍ភាគច្រើនផងដែរ (Pellini, 2004) ។ មានការបកស្រាយជាច្រើនរួចមកហើយអំពី ទំនាក់ទំនងភ្ញៀវ-អតិថិជនដែលកំណត់អំពីនិយមន័យរបស់សហគមន៍ជនបទ (Blunt & Turner, 2005) ។ ទោះជាយ៉ាងណាក៏ដោយ ការសិក្សានានាដែលបានធ្វើឡើងនៅចុងទសវត្សរ៍ឆ្នាំ ១៩៩០ បានអធិប្បាយអំពីកង្វះការបង្កើតជាក្រុមធំៗ ឬការបង្កើតក្រុមថ្មី ដូចជាសមាគមន៍អ្នកនេសាទ ក្លឹប ឬសហករណ៍ដែលបង្កើតឡើងតាមគោល-ការណ៍អ្នកមិនជាប់ជាសាច់ញាតិជាមួយគ្នា (FACT/EJF, 2002:29) ។

គួរតែធ្វើការសិក្សាផងដែរអំពី វិសាលភាពនៃករណីដែលប្រជាពលរដ្ឋមានបំណងឱ្យមានការចាត់ទុកពួកគាត់ថាជា "អ្នកនេសាទ" ឬជា "កសិករ" ។ គួរពិចារណាផងដែរអំពីមូលដ្ឋានសម្រាប់បង្ហាញឱ្យដឹងអំពីអត្តសញ្ញាណតាមមុខរបរបែបនេះ។ អារម្មណ៍យ៉ាងជ្រាលជ្រៅរបស់ពុទ្ធសាសនិកជនប្រឆាំងនឹងសកម្មភាពដែលប្រហារជីវិត (ការនេសាទគឺជាសកម្មភាពមួយក្នុងចំណោមសកម្មភាពបែបនេះ) អាចមានឥទ្ធិពលទៅលើការយល់ឃើញ/ចំណាត់ការឆ្លើយតបរបស់ប្រជាពលរដ្ឋអំពីថាតើគាត់ចង់បង្ហាញអត្តសញ្ញាណមុខរបរតាមវិធីណា នៅពេលប្រឈមក្នុងការយកជម្រើសរវាងប្រការដែលត្រូវបានឱ្យឈ្មោះថា កសិករ ឬអ្នកនេសាទ។ សមាគមន៍នៃជនជាតិណាមួយដែលមានមុខរបរជាក់លាក់ក៏អាចមានឥទ្ធិពលទៅលើជម្រើសនានាផងដែរ។ ការលើកតម្កើងដោយខ្មែរក្រហម អំពីការធ្វើស្រែខ្ពស់ជាងអ្វីៗទាំងអស់ ក៏ជាកត្តាមួយផ្សេងទៀតដែលមានឥទ្ធិពលទៅលើអារម្មណ៍របស់ប្រជាពលរដ្ឋផងដែរ នៅពេលត្រូវបានសួរអំពីមុខរបររបស់ខ្លួន[14] ។

អនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍នេសាទមិនមានចែងអំពីចំនុចលំអិតទាំងនេះទេ។ អនុក្រឹត្យនេះ កំណត់សហគមន៍មួយ ថាប្រជាពលរដ្ឋខ្មែរមួយក្រុមតូចនៅក្នុងកន្លែងមួយ ដែលស្ម័គ្រចិត្តបង្កើត និងអនុវត្តកិច្ចផ្តួចផ្តើម ដើម្បីលើកកំពស់ការរស់នៅដោយប្រើប្រាស់ និងកែច្នៃធនធានជលផលឱ្យមាននិរន្តរភាព (មាត្រា ៦)។ នេះអាចមានន័យថា លើកលែងតែ បុគ្គលទាំងអស់នៅក្នុងភូមិនោះរួបរួមគ្នាបង្កើតជាសហគមន៍នេសាទ បើពុំនោះទេ នឹងមានមនុស្សពីរក្រុម : អ្នកដែលជាសមាជិក និងអ្នកដែលមិនមែនជាសមាជិក។ ទោះជាយ៉ាងណាក៏ដោយ ការបែងចែកបែបនេះមិនបានផ្តល់បុព្វសិទ្ធិឱ្យដល់សមាជិកច្រើនជាងអ្នកដែលមិនមែនជាសមាជិកនោះឡើយ។ ធៀបនឹងលទ្ធភាពក្នុងការប្រើប្រាស់ធនធានជលផល ពុំមានអ្នកណាម្នាក់នឹងត្រូវដាក់ឱ្យនៅក្រៅការយកចិត្តទុកដាក់ឡើយ (មាត្រា ១៤)។ យើងបានប្រឹងប្រែងបង្ហាញឱ្យឃើញពីចំនុចជាក់លាក់នៃអត្តសញ្ញាណរបស់បុគ្គលនីមួយៗ នៅក្នុងសហគមន៍នៅជាប់ដែនទឹក ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យចំនួនបីគឺ : (១) ជនជាតិ (២) ស្ថានភាពសេដ្ឋកិច្ច និង (៣) សកម្មភាពសេដ្ឋកិច្ច (រូបទី ២) ។

[14] បញ្ហានេះត្រូវបានលើកឡើងដោយ Acker, 2003 នៅពេលគាត់សួរថា "តើកម្ពុជា ជាប្រជាជាតិមួយដែលមាន អ្នកនេសាទដែលធ្វើស្រែផង ឬ មានអ្នកផលិតស្រូវដែលធ្វើនេសាទផង ឬយ៉ាងណា?" នៅពេលដែលលំបាកផ្តល់ចម្លើយឱ្យជ្រះស្រឡះចំពោះសំណួរនេះ ប្រជាពលរដ្ឋអាចប្រាប់អ្នកអំពីថាតើ ពួកគេអាចបែងចែកភាពខុសគ្នារវាងសកម្មភាពនេសាទ និងកសិកម្មបែបណា។




**រូបទី ២: លក្ខណៈវិនិច្ឆ័យសម្រាប់បកស្រាយអំពីចំនុចជាក់លាក់នៃអត្តសញ្ញាណរបស់សហគមន៍នៅជាប់ដែនទឹកក្នុងប្រទេសកម្ពុជា**

សំណួរសំខាន់មួយ គឺថាតើសមាជិកនានា ដែលបានឯកភាពគ្នាដោយស្ម័គ្រចិត្តពីមុនគេ ដើម្បីបង្កើតសហគមន៍នេសាទ គឺជាអ្នកដែលមានចំណាប់អារម្មណ៍ច្រើនជាងគេក្នុងចំណោមអ្នកភូមិទាំងអស់ ទាក់ទងនឹងសកម្មភាព ស្ថានភាពសេដ្ឋកិច្ច ឬ តាមទស្សនៈនៃក្រុមជនជាតិឬយ៉ាងណា។ លក្ខណៈចម្រុះ និងសមាសភាពនៃសមាជិកក្រុមដែលបានបង្កើតឡើងជាដំបូង អាចជាកត្តាចំបងក្នុងការកំណត់អត្តសញ្ញាណសមាជិក និងសម្ព័ន្ធភាពនៅក្នុងសហគមន៍នេសាទថ្មីមួយ។ ការសិក្សាដោយប្រុងប្រយ័ត្នអំពីសមាសភាព និងអត្តសញ្ញាណគ្រួសារនានានៅក្នុងតំបន់ដែលមានសក្តានុពលក្នុងការបង្កើតជាតំបន់សហគមន៍នេសាទគួរត្រូវបានចាត់ទុកជាអាទិភាព។ ផាតុនានានៃជោគជ័យ ឬបរាជ័យនៃសហគមន៍នេសាទមួយអាចជាប់ទាក់ទងនឹង "លក្ខខណ្ឌដើមដំបូង" នេះនៃអត្តសញ្ញាណ និងរចនាសម្ព័ន្ធនៃសមាជិកភាព។

សំណួរសំខាន់មួយ  គឺថាតើសមាជិកនានាដែលបានឯកភាពគ្នាដោយស្ម័គ្រចិត្តពីមុនគេដើម្បីបង្កើតសហគមន៍នេសាទគឺជាអ្នកដែលមានចំណាប់អារម្មណ៍ច្រើនជាងគេក្នុងចំណោមអ្នកភូមិទាំងអស់ ទាក់ទងនឹងសកម្មភាពស្ថានភាពសេដ្ឋកិច្ច ឬ តាមទស្សនៈនៃក្រុមជនជាតិឬយ៉ាងណា ។ លក្ខណៈចម្រុះនិងសមាសភាពនៃសមាជិកក្រុមដែលបានបង្កើតឡើងជាដំបូងអាចជាកត្តាចំបងក្នុងការកំណត់អត្តសញ្ញាណសមាជិក និងសម្ព័ន្ធភាពនៅក្នុងសហគមន៍នេសាទថ្មីមួយ ។

**ការបង្កើតសហគមន៍នេសាទនៅក្នុងបរិបទដែលគ្មានភាពច្បាស់លាស់បែបនេះ  អាចបង្កើតឱ្យមានការមិនចុះសម្រុងគ្នាជាថ្មី។ ប៉ុន្តែ សហគមន៍បែបនេះក៏មាន** សក្តានុពលក្នុងការផ្តល់នូវចំនុចជាក់លាក់ថ្មី សម្រាប់បង្កើតអត្តសញ្ញាណ និងអាចជាមូលដ្ឋានគ្រឹះសម្រាប់កសាងសហគមន៍ថ្មីៗនៅជាប់ដែនទឹកក្នុងជនបទនៃប្រទេសកម្ពុជាផងដែរ។ ការបង្កើតរចនាសម្ព័ន្ធសង្គមដែលមានបង្កប់នៅក្នុងដំណើរការនៃការបង្កើតសហគមន៍នេសាទថ្មីៗបែបនេះ  មានសារៈសំខាន់ខ្លាំងណាស់  និងក៏ជាការប្រឈមចំបងខាងផ្នែកសង្គមសាស្ត្រផងដែរ ។

**៣.៨ ពង្រឹងបណ្តាញការងារ**

ការចាត់ចែងស្ថាប័ននៅក្នុងកន្លែងនីមួយៗ និងការបង្កើតឱ្យមានជាបណ្តាញទាក់ទងគ្នា គឺជាការច្នៃប្រឌិតជាសារវន្តខាងស្ថាប័ន ដើម្បីគ្រប់គ្រងធនធានធម្មជាតិឱ្យបានជោគជ័យ ។ កម្រិតដែលអាចចេញចូល និងប្រើប្រាស់ធនធានធម្មជាតិទៅបាន គួរតែស្របគ្នាជាមួយកម្រិតនៃការចាត់ចែងរដ្ឋបាល និងសមត្ថភាពនៃប្រព័ន្ធអេកូឡូស៊ីផងដែរ ។ នៅក្នុងដំណាក់កាលមួយ ការបង្កើត និងដំណើរការរបស់សហគមន៍នេសាទនីមួយៗរីករាលដាល នៅពេលនោះក៏ត្រូវការឱ្យមានកាតព្វកិច្ចដើម្បីធ្វើឱ្យមានការសម្របសម្រួលកាន់តែច្រើនឡើងផងដែរ  រវាងសកម្មភាពនានាដែលទាក់ទងជាមួយសហគមន៍នេសាទ ។  ការធ្វើបែបនេះជាតម្រូវការដើម្បីកាត់បន្ថយឥទ្ធិពលអវិជ្ជមានទៅវិញទៅមកពីខាងក្រៅ  ទន្ទឹមនឹងការទាញយកផលប្រយោជន៍ពីសេដ្ឋកិច្ចខ្នាតធំនៅក្នុងពេលខាងមុខ ។ ទោះបីការបង្កើតឱ្យមានចំណាត់ការរួមគ្នាបែបនេះ  មិនត្រូវបានមើលឃើញនៅក្នុងអនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍នេសាទក៏ដោយ  ប្រការនេះត្រូវបានចែងនៅក្នុងព្រះរាជក្រឹត្យស្តីពីការបង្កើតសហគមន៍នេសាទ ( មាត្រា ៣) ដែលចែងថា "សហគមន៍នេសាទដែលមានដែននេសាទនៅជាប់គ្នា  អាចរួបរួមគ្នាដោយបង្កើតជាសហព័ន្ធសហគមន៍នេសាទ" ។  ការចែងបែបនេះក៏ជួយបង្កើន ភាពមានទៅមានមក រវាងសហគមន៍ និងកសាងទំនុកចិត្តនៅទូទាំងសហគមន៍នេសាទតូចៗនានា ។ ជាញឹកញាប់ គឺមូលធនសង្គមនេះហើយដែលនឹងក្លាយទៅជាកត្តាសម្រេចលើជោគជ័យ ឬបរាជ័យនៃចំណាត់ការរបស់សហគមន៍[15] ។

[15] នៅក្នុងទស្សនកិច្ចតាមមូលដ្ឋានជាក់ស្តែង យើងបានសង្កេតឃើញថា វិធានការបែបនេះកំពុងត្រូវបានអនុវត្ត ដោយសហគមន៍នៅកំពង់ត្រឡាច ក្នុងខេត្តកំពង់ឆ្នាំង ។ វិធានការបែបនេះ ដែលគាំទ្រដោយការិយាល័យជលផលខេត្ត មិនត្រឹមតែកាត់បន្ថយការនេសាទល្មើសច្បាប់តែប៉ុណ្ណោះទេ វាថែមទាំងបង្កើនភាពជឿជាក់កាន់តែខ្លាំងឡើងក្នុងចំណោមគណៈកម្មការសហគមន៍នេសាទ អំពីសមត្ថភាពរបស់ខ្លួន ក្នុងការចាត់ចែងនៅលើដែននេសាទដែលមានវិសាលភាពធំ ។

## ៣.៩ ការកំណត់ឡើងវិញនូវតួនាទីរបស់ស្ត្រី

ជាប្រពៃណី ស្ត្រីបានដើរតួនាទីយ៉ាងសំខាន់នៅក្នុងសហគមន៍នៅជាប់ដែនទឹក : ស្វែងរកអាហារសម្រាប់គ្រួសារ (រួមទាំងបេះផលពីរុក្ខជាតិ និងរកសាច់សត្វ នៅក្នុងរដូវប្រាំង នៅពេលដែលបុរសទៅរកការងារធ្វើនៅទីឆ្ងាយ) កែច្នៃផលនេសាទ លក់ត្រី និងជួយស្វាមីនៅក្នុងការនេសាទ និងសកម្មភាពពាក់ព័ន្ធ ដូចជា ជួសជុលមង ។ល។ ទន្ទឹមនឹងការកើនឡើងនៃសហគមន៍នេសាទ តួនាទីរបស់ស្ត្រីនៅក្នុងសកម្មភាពទាំងនេះនឹងត្រូវពង្រីកជាបន្ថែមទៀតផងដែរ។ ការពង្រីកសកម្មភាពនេះ ឱ្យមានគុណភាពខុសៗគ្នា និងមានប្រយោជន៍កាន់តែច្រើនជាងមុន គឺជាការប្រឈមមួយ។ គួរតែមានការពិនិត្យឱ្យបានល្អិតល្អន់អំពីលទ្ធភាពក្នុងការបង្កើតជាសហគ្រាសដែលស្ត្រីអាចធ្វើការរួមគ្នា ។ ការភ្ជាប់ទំនាក់ទំនងរវាងការសន្សំ និងឥណទានជាមួយការពង្រីកសកម្មភាពនៅពេលមុន និងនៅក្រោយសកម្មភាពនេសាទ អាចបង្កើតជាកម្លាំងជម្រុញចំបងសម្រាប់ធានាថា មានបម្លែងពីការពង្រីកការនេសាទជាលក្ខណៈគ្រួសារនៅក្នុងសហគមន៍នេសាទ ទៅជាសិទ្ធិអំណាច និងសមត្ថភាពក្នុងការពង្រឹងជីវភាពរស់នៅ។ នៅពេលដែលស្ត្រីមានអំណាចកាន់តែច្រើនក្នុងការគ្រប់គ្រងធនធានហិរញ្ញវត្ថុនៅក្នុងគ្រួសារ ធនធានទាំងនេះក៏មានសក្តានុពលកាន់តែខ្ពស់ដើម្បីធ្វើការវិនិយោគប្រកបដោយឈ្លាសវៃជាងមុន នៅក្នុងកិច្ចការដែលទាក់ទងជាមួយសន្តិសុខស្បៀង ការអប់រំ និង សុខភាពរបស់គ្រួសារផងដែរ។ ការផ្លាស់ប្តូរមួយក្នុងចំណោមការផ្លាស់ប្តូរនានាដែលអាចមើលឃើញ នៅក្រោយមានកំណែទម្រង់បច្ចុប្បន្ននៅក្នុងវិស័យជលផល គឺកំណើននៃការចាត់ចែងជារចនាសម្ព័ន្ធ និងកំណើនដោយធម្មជាតិនៃតួនាទីរបស់ស្ត្រីនៅក្នុងសកម្មភាពរបស់គណៈកម្មការសហគមន៍នេសាទ។ ស្ត្រីមួយចំនួនបានចូលរួមជាសមាជិកនៅក្នុងគណៈកម្មការសហគមន៍នេសាទជាច្រើន។ នៅដើមឆ្នាំ ២០០៥ សហគមន៍នេសាទនៅក្នុងខេត្តសៀមរាប មានសមាសភាពសមាជិកាគណៈកម្មការច្រើនជាងគេ (២៧ នាក់) ដែលមានស្ត្រីច្រើនជាងគេ (៩រូប) ។ គណៈកម្មការសហគមន៍នេសាទនៅក្នុងខេត្តដទៃទៀត មានសមាជិក ពី ៦ ទៅ ១០ នាក់ ក្នុងនោះមានស្ត្រីប្រហែលម្នាក់ ក្នុងគណៈកម្មការនីមួយៗ [16] ។ ស្ត្រីខ្លះបានដើរតួនាទីយ៉ាងសំខាន់ ជាលេខាធិការ និងជាគណនេយ្យករ ក៏ដូចជានៅក្នុងសកម្មភាពល្បាតផងដែរ។ តួនាទីរបស់មន្ត្រីនារី នៅក្នុងការិយាល័យជលផលខេត្ត ការចូលរួមរបស់ក្រុមប្រឹក្សាឃុំ និងអង្គការសង្គមស៊ីវិលគួរតែត្រូវបានពង្រឹង ដើម្បីបង្កើនសកម្មភាពរបស់ស្ត្រី និងពង្រឹងការចូលរួមរបស់អ្នកទាំងនេះនៅក្នុងអភិបាលកិច្ចសហគមន៍នេសាទ។

> តួនាទីរបស់មន្ត្រីនារី នៅក្នុងការិយាល័យជលផលខេត្ត ការចូលរួមរបស់ក្រុមប្រឹក្សាឃុំ និងអង្គការសង្គមស៊ីវិលគួរតែត្រូវបានពង្រឹង ដើម្បីបង្កើនសកម្មភាពរបស់ស្ត្រី និងពង្រឹងការចូលរួមរបស់អ្នកទាំងនេះ នៅក្នុងអភិបាលកិច្ចសហគមន៍នេសាទ។

## ៣.១០ ចំណងទាក់ទងជាមួយក្រុមប្រឹក្សាឃុំ

អភិបាលកិច្ចវិមជ្ឈការបានទទួលការជម្រុញដ៏ខ្លាំងក្លានៅក្នុងប្រទេសកម្ពុជា មួយចំណែក ដោយសារសម្ពាធពីម្ចាស់ជំនួយ និងមួយចំណែកទៀតដោយសារការដាក់ឱ្យប្រើប្រាស់យុទ្ធសាស្ត្រនយោបាយដែលឈ្លាសវៃជាងមុន (Blunt & Turner,

[16] ការអង្កេតស្ថានភាពគោល ដែលធ្វើឡើងដោយនាយកដ្ឋានជលផល នៅក្នុងផ្នែកអនុវត្តគម្រោងនីមួយៗ ដែលទទួលមូលនិធិពី TSEMP នៅចុងឆ្នាំ ២០០៤ និងដើមឆ្នាំ ២០០៥។

2005)។ ក្រុមប្រឹក្សាឃុំគឺជានីតិបុគ្គលនៃអភិបាលកិច្ចនៅកម្រិតសហគមន៍ដែលមានវិសាលភាពធំ។ ដើម្បីឱ្យមាននិរន្តរភាពខាងការចាត់ចែង និងសិទ្ធិអំណាច សហគមន៍នេសាទគួរតែប្រតិបត្តិការនៅក្នុងបរិបទនៃក្រុមប្រឹក្សាឃុំ។ មានភស្តុតាងល្អៗចូលមកហើយដែលបង្ហាញថា នៅពេលដែលសមាជិកគណៈកម្មការសហគមន៍នេសាទមានការពាក់ព័ន្ធផងដែរជាមួយក្រុមប្រឹក្សាឃុំសុទិដ្ឋិនិយម និងសកម្មភាពកាន់តែមានច្រើនឡើងផងដែរ (Marschke, 2003 and FACT, 2005) ។ នេះប្រហែលជាកើតឡើងដោយសារ សិទ្ធិអំណាចកាន់តែច្រើនដែលសហគមន៍នេសាទទទួលបាន នៅពេលពឹងផ្អែកទៅលើរចនាសម្ព័ន្ធរបស់សមត្ថកិច្ចរដ្ឋបាល និងនយោបាយដែលមានការចាត់ចែងបានរឹងមាំជាង។ អភិបាលកិច្ចវិមជ្ឈការនៅថ្នាក់ឃុំ គឺជាការសន្យាឱ្យមានការចូលរួមពីសំណាក់រចនាសម្ព័ន្ធដែលបានបង្កើតនៅមូលដ្ឋាន និងអាចផ្សព្វផ្សាយវប្បធម៌នៃកំណើន និងការទាក់ទាញនៃតម្រូវការឱ្យមានគណនេយ្យភាព។ លើសពីនេះ ការស្ថិតនៅក្រោមក្របខ័ណ្ឌនៃក្រុមប្រឹក្សាឃុំ គឺជាការផ្តល់ឱ្យមានការសម្របសម្រួលនូវសកម្មភាពនានា ប្រសិនបើនៅក្នុងតំបន់គ្រប់គ្រងរបស់ក្រុមប្រឹក្សាឃុំនោះ មានសហគមន៍នេសាទជាចំនួនច្រើនជាងមួយ។ ទោះជាយ៉ាងណាក៏ដោយ ប្រការជាច្រើននៅតែទាក់ទងទៅនឹងការកំណត់ព្រំដែននៃសមត្ថកិច្ចរបស់សហគមន៍នេសាទទៅអនាគត។

បច្ចុប្បន្ន អនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍នេសាទមានចែងអំពីកាតព្វកិច្ច (មាត្រា ៦) ដែលតម្រូវឱ្យក្រុមប្រឹក្សាឃុំធ្វើសហប្រតិបត្តិការនៅក្នុងការបង្កើតសហគមន៍នេសាទ។ ក្រៅពីនេះក៏មានចែង (នៅក្នុងមាត្រា ១៥) ថា ក្រុមប្រឹក្សាឃុំនឹងត្រូវអញ្ជើញឱ្យចូលរួមនៅក្នុងដំណើរការបោះឆ្នោតនៃគណៈកម្មការសហគមន៍។ ប្រការទាំងនេះមិនមានចែងច្បាស់អំពីការតម្រូវឱ្យសហគមន៍នេសាទ ដំណើរការនៅក្រោមការណែនាំទូទៅរបស់ក្រុមប្រឹក្សាឃុំនោះទេ។ ហេតុនេះចាំបាច់ត្រូវចាត់វិធានការទុកជាមុនដើម្បីពិនិត្យមើលចំណុចនេះ។

មានវិធានចំនួនពីរដែលអាចជួយឱ្យសម្រេចគោលដៅនេះ។ វិធានទីមួយ គឺត្រូវបង្កើតច្បាប់សមរម្យ ដើម្បីសម្រួលចំនុចនេះ ដូចជាសេចក្តីសម្រេចរួម (ប្រកាស) របស់ក្រសួងកសិកម្ម និងក្រសួងមហាផ្ទៃ (Oberndorf, 2004) ។ វិធានទីពីរ គឺទុកឱ្យកិច្ចការនេះវិវត្តន៍ដោយខ្លួនឯង នៅក្នុងកាលៈទេសៈនៃបរិបទជាក់លាក់នីមួយៗ រហូតបានទទួលបទពិសោធន៍ដល់កម្រិតមួយ ដែលកិច្ចសហប្រតិបត្តិការបែបនេះ នាំឱ្យមានការគាបសង្កត់ពីខាងក្រោមដើម្បីឱ្យបង្កើតចំណងទាក់ទងបែបនេះ។ រហូតមកទល់ពេលនេះ នៅក្នុងប្រទេសកម្ពុជា ដំណើរកំណែទម្រង់វិស័យជលផលទាំងមូល បានកើតឡើងក្រោមរូបភាពនៃការរួមបញ្ចូលគ្នានៃវិធានទាំងពីរនេះ។ គ្មានហេតុផលណាមួយដែលតម្រូវឱ្យធ្វើការផ្លាស់ប្តូរដំណើរការនេះទេ។

## ៣.១១ កិច្ចសហការជាមួយអង្គការសង្គមស៊ីវិល

តួនាទីរបស់អង្គការសង្គមស៊ីវិលនៅក្នុងការបង្កើតសហគមន៍នេសាទត្រូវបានទទួលស្គាល់ជាទូទៅ។ ប្រជាពលរដ្ឋនៅក្នុងសហគមន៍នេសាទក៏មានអារម្មណ៍ផងដែរអំពីអត្ថប្រយោជន៍ ទាំងអត្ថប្រយោជន៍ខាងសម្ភារៈ និងក្រៅពីសម្ភារៈ ដែលបានពីការចូលរួមរបស់សង្គមស៊ីវិល។ ទោះជាយ៉ាងណាក៏ដោយ ដូចជានៅក្នុងកិច្ចផ្តួចផ្តើមដែលនាំមុខដោយរដ្ឋដែរ ដែលជាទិដ្ឋភាពរួមកើតមាននៅក្នុងប្រទេសជាច្រើននៅអាស៊ី តួនាទីរបស់អង្គការសង្គមស៊ីវិល ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យប្រកបដោយការប្រុងប្រយ័ត្ន។ ស្ថានភាពពិតប្រាកដនៅក្នុងប្រទេសកម្ពុជា មានលក្ខណៈខុសប្លែកបន្តិច។ ដោយសារស្ថានភាពដែលប្រជាពលរដ្ឋ បានជួបប្រទះនៅដើមទសវត្សរ៍ឆ្នាំ ១៩៩០ ជំនួយមិនមែនរដ្ឋាភិបាលបានក្លាយជាប្រភពចំបងសម្រាប់ជួយសង្គ្រោះជីវិត និងការចិញ្ចឹមជីវិត

នៅក្នុងប្រទេសកម្ពុជា។ ភាពបត់បែន កត្តាជម្រុញពីផ្ទៃក្នុងចេតនាល្អ និងលទ្ធភាពកមូលនិធិ គឺជាចំណុចសំខាន់ចំបងរបស់អង្គការមិនមែនរដ្ឋាភិបាល។ ទោះជាយ៉ាងណាក៏ដោយ អង្គការទាំងនោះមិនសុទ្ធតែនាំមកជាមួយនូវសមត្ថភាព ឬចំណេះដឹងពិសេសអំពីវិស័យជាក់លាក់ ដែលអង្គការទាំងនោះធ្វើការជាមួយនោះឡើយ។ ដើម្បីជំនះបាននូវចំណុចខ្វះខាតនេះ អង្គការទាំងនោះបានស្វែងរកសេវាពីទីប្រឹក្សាអន្តរជាតិ និងនៅក្នុងស្រុក ដើម្បីផ្តល់យោបល់ដល់ខ្លួនអំពីវិធានការសមស្របដែលគួរអនុវត្ត។

ត្រូវធ្វើការអង្កេតអំពីតួនាទីរបស់អង្គការចាត់តាំងបែបប្រពៃណីដែលមានស្រាប់នៅកម្រិតភូមិផងដែរ។ គណៈកម្មការវត្ត និងទីកន្លែងនៅក្នុងវត្ត បានផ្តល់នូវរចនាសម្ព័ន្ធសហគមន៍តែមួយគត់ ដែលនៅបន្តដំណើរការបច្ចុប្បន្ននៅតាមជនបទ។ ភាគច្រើននៃការប្រមូលផ្តុំរបស់សហគមន៍នេសាទបានធ្វើឡើងនៅក្នុងបរិវេណនៃវត្តនៅក្នុងភូមិ។ ការពិនិត្យមើលជាលក្ខណៈប្រព័ន្ធអំពីចំណងទាក់ទងដ៏មានប្រយោជន៍រវាងសហគមន៍នេសាទ និងគណៈកម្មការវត្ត គឺជាផ្នែកមួយដែលត្រូវសិក្សាឱ្យបានស៊ីជំរៅ (Pellini, 2004) ។

ទាក់ទងនឹងការប្រឈមទៅអនាគតនៅក្នុងវិស័យនេសាទទឹកសាបក្នុងប្រទេសកម្ពុជា និងជាពិសេស ទាក់ទងជាមួយ ការកើតឡើងកាន់តែច្រើន និងការបង្កើតសហគមន៍នេសាទតាមផ្លូវច្បាប់ ការបញ្ជ្រាបខ្លះៗនូវសកម្មភាពនានារបស់អង្គការសង្គមស៊ីវិល អាចផ្តល់អត្ថប្រយោជន៍សម្រាប់នាយកដ្ឋានជលផល សហគមន៍ដែលមានបំណងបង្កើតជាសហគមន៍នេសាទ និងសម្រាប់អង្គការសង្គមស៊ីវិលខ្លួនឯងផងដែរ។ ការបង្កើតក្រុមការងារបច្ចេកទេសខាងជលផល (Department of Fisheries, 2005) ដែលធ្វើសកម្មភាពជាអន្តរការី និងជាដៃគូរវាងនាយកដ្ឋានជលផល សហគមន៍ម្ចាស់ជំនួយ និងអង្គការសង្គមស៊ីវិល គឺជាជំហានមួយតាមទិសដៅត្រឹមត្រូវ។ ទោះជាយ៉ាងណាក្តី នៅកម្រិតដែលមានលក្ខណៈជាក់ស្តែងជាងនេះ ប្រការសំខាន់ជាងនេះ គឺអង្គការសង្គមស៊ីវិលត្រូវសហការជាមួយការិយាល័យជលផលខេត្ត នៅលើការងារទាក់ទងនឹងសហគមន៍នេសាទ។ នៅកម្រិតនេះ ដំណើរ-ការដែលបង្កើនចំណេះដឹងតាមវិធីឆ្លើយឆ្លងទៅវិញទៅមក គឺជាតម្រូវការយ៉ាងខ្លាំង។ អង្គការទាំងនេះត្រូវការនូវចំណេះដឹងជាច្រើនបន្ថែមទៀតអំពីលក្ខណៈជាក់លាក់នៃការនេសាទទឹកសាប (ទិដ្ឋភាពអេកូឡូស៊ី សង្គម សេដ្ឋកិច្ច បច្ចេកវិទ្យា និងស្ថាប័ន ។ល។) ហើយបុគ្គលិកការិយាល័យជលផលខេត្ត ត្រូវការនូវចំណេះដឹងជាច្រើនបន្ថែមទៀតអំពីកត្តាមនុស្ស ដែលទាក់ទងនឹងការគ្រប់គ្រងធនធានធម្មជាតិ (ចំណេះដឹងជាមូលដ្ឋានអំពីការរៀបចំសហគមន៍ វិធីប្រមូលព័ត៌មាន ការរៀនសូត្រពីប្រជាពលរដ្ឋ ។ល។) ។ ការផ្លាស់ប្តូរចំណេះដឹងបែបនេះអាចត្រូវធ្វើឡើងនៅថ្នាក់ខេត្ត និងចាត់ចែងឡើងដោយការិយាល័យជលផលខេត្ត រួមជាមួយសម្ព័ន្ធភាពនៃអង្គការសង្គមស៊ីវិល ដែលធ្វើការនៅក្នុងខេត្តពាក់ព័ន្ធ។ ដោយហេតុថា បច្ចុប្បន្ន សហគមន៍នេសាទ គឺជាកិច្ចផ្តួច-ផ្តើមដែលដឹកនាំដោយរដ្ឋ ការធ្វើឱ្យប្រាកដថា ជំនួយរបស់អង្គការមិនមែនរដ្ឋាភិបាលត្រូវបានពង្រីកនៅទូទាំងសហគមន៍នេសាទក្នុងផ្ទៃប្រទេស គឺជាប្រការសំខាន់ណាស់។ គួរធ្វើការចងក្រងបទដ្ឋានដែលមានការឯកភាពគ្នា សម្រាប់សម្រួលការងារនេះ។

## ៣.១២ ការតម្រង់ទិសការងារស្រាវជ្រាវ និងការអភិវឌ្ឍ

ដើម្បីដោះស្រាយការប្រឈមដែលយើងបានធ្វើអត្តសញ្ញាណពីខាងដើម គេត្រូវការឱ្យមានការតម្រង់ទិសសកម្មភាព និងអាទិភាពនៃការស្រាវជ្រាវ និងអភិវឌ្ឍន៍ ។ បញ្ហាស្រាវជ្រាវ និងអភិវឌ្ឍន៍ជលផលត្រូវបានដាក់បញ្ចូលទៅក្នុងស្ថាប័ននេះ និងបានចាត់ចែងយ៉ាងល្អ នៅក្រោយឆ្នាំ ១៩៩៥។ វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍នេសាទទឹកសាប (IFReDI) ត្រូវបានបង្កើតឡើង

ដោយមានអាណត្តិ ដើម្បីគាំទ្រការងារអភិវឌ្ឍន៍វិស័យនេសាទទឹកសាបដោយចីរភាព។ វិទ្យាស្ថាន IFReDI បានបង្កើតឡើងនូវរបៀបវារៈសមស្របតាមបែបប្រពៃណី ទាក់ទងនឹងការស្រាវជ្រាវ និងអភិវឌ្ឍជីវៈ-អេកូឡូស៊ី សេដ្ឋកិច្ច-សង្គម និងបច្ចេក-វិទ្យា។ ក្រៅពីនេះ មានស្ថាប័នរដ្ឋ និងអង្គការសង្គមស៊ីវិលជាច្រើនផ្សេងទៀត ដែលផ្ដល់ការគាំទ្រកិច្ចផ្ដួចផ្ដើមស្រាវជ្រាវទាំងនេះ ដែលមានឥទ្ធិពលទៅលើប្រព័ន្ធជីជាតិ និងធនធានក្នុងទឹក និងក្នុងបរិបទនៃសេដ្ឋកិច្ច-សង្គមរបស់សហគមន៍ដែលពាក់ព័ន្ធ។

គោលដៅទាំងពីរ ពោលគឺ ការស្រាវជ្រាវ និងអភិវឌ្ឍន៍ ត្រូវតែផ្ដោតលើភាពពេញលេញនៃធនធានធម្មជាតិ និងសុខុ-មាលភាពរបស់សហគមន៍។ ចាំបាច់ត្រូវតែមានការប្ដេជ្ញាដើម្បីផលិតទិន្នន័យ និងប្រមូលព័ត៌មាន និងការតាមដានអំពីដំណើរការសង្គមប្រកបដោយលក្ខណៈដែលមានការចូលរួមជាងមុន ដោយផ្ដោតការយកចិត្តទុកដាក់ឱ្យបានគ្រប់គ្រាន់ចំពោះវិស័យនៃចំណេះដឹងនៅមូលដ្ឋាន អំពីសេដ្ឋកិច្ច-សង្គមនិងអេកូឡូស៊ី ដែលអាចទុកចិត្តបាន។ ត្រូវផ្ដោតការយកចិត្តទុកដាក់ចំពោះ "ភាពជាក់ស្ដែងនៅកម្រិតមូលដ្ឋាន" អំពីទិដ្ឋភាពអេកូឡូស៊ី និងសង្គមវិមជ្ឈការ ដោយពុំធ្វើឱ្យបាត់បង់ទស្សនទានអំពីក្របខ័ណ្ឌធំទូលាយ នៃ "ទិដ្ឋភាពនៅលើពិភពលោកឡើយ"។ ការផ្លាស់ប្ដូរគំរូនៃការស្រាវជ្រាវ និងអភិវឌ្ឍន៍ គឺជាការប្ដេជ្ញាចំពោះដំណើរការនៃការវិភាគអំពីស្ថានភាពទាំងនៅកម្រិតមូលដ្ឋាន និងនៅកម្រិតពិភពលោក នៅក្នុងពេលជាមួយគ្នា។ លក្ខខណ្ឌសំខាន់ៗ ដែលបានកំណត់ទុកជាមុន ដើម្បីសម្រេចគោលដៅនេះ គឺជាការតម្រូវឱ្យអ្នកស្រាវជ្រាវ និងអ្នកបច្ចេកទេសនេសាទ ចាត់វិធានការដែលគ្រោងទុកជាមុន ដើម្បីបង្កើនទំនាក់ទំនងឱ្យបានជិតស្និទ្ធជាងមុន និងតាមវិធីជាលក្ខណៈប្រព័ន្ធជាងមុន នៅក្នុងការងារទាក់ទងនឹងសហគមន៍នេសាទ ឬមួយដោយផ្ទាល់ ឬមួយតាមរយៈកិច្ចសហការជាមួយអ្នកគ្រប់គ្រងជលផល នៅក្នុងការិយាល័យជលផលតាមខេត្តនីមួយៗ[17]។

គោលដៅទាំងពីរ ពោលគឺ ការស្រាវជ្រាវ និងអភិវឌ្ឍន៍ ត្រូវតែផ្ដោតលើភាពពេញលេញនៃធនធានធម្មជាតិ និងសុខុមាលភាពរបស់សហគមន៍។

ការវាយតម្លៃអំពីតម្រូវការឱ្យមានការស្រាវជ្រាវ និងការអភិវឌ្ឍន៍ថ្មីៗ មិនមែនជាការងាយស្រួលនោះឡើយ។ ដោយសារការស្រាវជ្រាវ និងការអភិវឌ្ឍន៍ផ្ដោតទៅលើ "ភាពជាក់ស្ដែងនៅកម្រិតមូលដ្ឋាន" សមាជិកសហគមន៍នេសាទ ប្រហែលជាពុំអាចបញ្ចេញឱ្យដឹងអំពីតម្រូវការរបស់ខ្លួនតាមទម្រង់នៃសំណើជាក់លាក់បាននោះឡើយ។ ត្រូវស្វែងរកគោលគំនិតសម្រាប់ការស្រាវជ្រាវ និងអភិវឌ្ឍន៍ ឱ្យបានកាន់តែច្រើនឡើង ពីក្នុងចំណោមសំណួរនានារបស់សមាជិកសហគមន៍នេសាទ ទាក់ទងនឹងជីជាតិ និងធនធានទឹក ដែលសហគមន៍ទើបតែទទួលបាននៅពេលថ្មីៗនេះ។ យើងបានផ្ដល់ឧទាហរណ៍ខ្លះៗ ដើម្បីបង្ហាញអំពីការប្រឈមជាច្រើនបែប ទាក់ទងនឹងការស្រាវជ្រាវទៅអនាគត។

[17] យោងតាមអនុក្រឹត្យស្ដីពីការគ្រប់គ្រងសហគមន៍នេសាទ មាត្រា ២០ គណៈកម្មការសហគមន៍អាច "សុំការគាំទ្របច្ចេកទេស និងហិរញ្ញវត្ថុ ពីសមត្ថកិច្ចជលផល ស្ថាប័នពាក់ព័ន្ធ និងម្ចាស់ជំនួយ ដើម្បីអនុវត្តសកម្មភាពរបស់សហគមន៍នេសាទ"

*(i) ការប្រែប្រួលនៃទំហំ និងសមាសភាគនៃប្រភេទផលនេសាទ និងការគំរាមកំហែងថ្មីចំពោះបរិស្ថាន*

ការប្រែប្រួលរូបវន្តនៃការគ្រប់គ្រងតំបន់ទំនាបលិចទឹក ទំនងជាមានឥទ្ធិពលទៅលើទម្រង់នៃការធ្វើចរាចរ និងការរកចំណី របស់ពពួកត្រីស និងត្រីខ្មៅ នៅក្នុងប្រព័ន្ធនេះ។ អ្នកនេសាទ ដែលមានសកម្មភាពនៅក្នុងកន្លែងនេសាទសហគមន៍ណាមួយជាក់លាក់ អាចបានត្រឹមតែធ្វើការកត់សំគាល់អំពីការប្រែប្រួលនៅកម្រិតមូលដ្ឋានទាក់ទងនឹងត្រីខ្មៅ។ ឧទាហរណ៍ៈ អ្នកទាំងនោះចង្អុលបង្ហាញអំពីទឹកដែលហូរយ៉ាងលឿន និងគ្មានអ្វីរាំងស្ទះ ចេញពីផ្លូវទឹកនានានៅក្នុងតំបន់ទំនាបលិចទឹក ចូលទៅក្នុងស្ទឹង បន្ទាប់ពីការរំលាយឡូត៍នេសាទ បាននាំឱ្យមានកំណើនផលនេសាទជាពពួកត្រីខ្មៅនៅក្នុងទន្លេនានា។ ទោះជាយ៉ាងនេះក្តី អ្នកនេសាទអាចពុំទទួលអារម្មណ៍បានគ្រប់គ្រាន់អំពីអន្តរកម្មរវាងប្រភេទត្រីស និងការប្រែប្រួលនៃប្រព័ន្ធអេកូឡូស៊ីទាំងមូលឡើយ។ នេះជាចំនុចដែលអ្នកវិទ្យាសាស្ត្រ និងអ្នកគ្រប់គ្រងជលផលត្រូវតែសហការជាមួយបណ្តាញសហគមន៍មូលដ្ឋានដើម្បីសិក្សា និងគ្រប់គ្រងពពួកត្រីស នៅទូទាំងតំបន់ដែលមានរបាយប្រភេទត្រីស។

ការជីកយកខ្សាច់ពីក្នុងទន្លេនានា សម្រាប់ផ្គត់ផ្គង់ឧស្សាហកម្មសាងសង់ដែលកាន់តែរីកចម្រើនឡើង គឺជាការគំរាមកំហែងផ្សេងទៀត ចំពោះបរិស្ថាន និងដែលកើតឡើងយ៉ាងឆាប់រហ័ស។ "ការទន្ទ្រានបន្តិចម្តងៗចូលទៅក្នុងតំបន់ដីសើម" ដែលត្រូវបានគេហៅ "ដីឥតប្រយោជន៍" ក៏មាននិន្នាការកើនឡើងផងដែរ សម្រាប់ធ្វើការសាងសង់ នៅជិតមជ្ឈមណ្ឌលនៃទីក្រុងដែលនឹងកើតឡើង។ ប្រការទាំងនេះអាចនាំឱ្យមានការផ្លាស់ប្តូរជាចំបងចំពោះលំហូរទឹក និងសមត្ថភាពស្រូបទឹកជំនន់។ អ្នកនេសាទមានចំណេះដឹងតិចតួចណាស់អំពីប្រការទាំងនេះ។ ត្រូវធ្វើការសិក្សានិន្នាការទាំងពីរនេះដោយប្រុងប្រយ័ត្ន។ ទាក់ទងនឹងបញ្ហាចុងក្រោយនេះ ប្រការចំបងស្ថិតនៅត្រង់ការវាយតម្លៃទាបអំពីទិដ្ឋភាពសេដ្ឋកិច្ចនៃតំបន់ដីសើម (Ratner et al, 2005) ។

*(ii) បញ្ឈប់ការនេសាទដែលមានលក្ខណៈបំផ្លាញ*

កម្លាំងនេសាទសរុបបានកើនឡើង ក្រោយពេលមានការបង្កើតសហគមន៍នេសាទ។ ប៉ុន្តែ ការនេសាទទាំងនេះមានលក្ខណៈរាយប៉ាយ នៅទូទាំងតំបន់ទំនាបលិចទឹកទាំងមូល ។ អត្រានៃការនេសាទដែលមានលក្ខណៈបំផ្លាញក៏បានកើនឡើងផងដែរ ទន្ទឹមនឹងការបង្កើតសហគមន៍នេសាទ។ ការគូសបញ្ជាក់អំពីឥទ្ធិពលអវិជ្ជមាននៃការនេសាទដែលមានលក្ខណៈបំផ្លាញ ក៏ប្រហែលជាមានសារៈសំខាន់ជាងការដាក់ឱ្យប្រើប្រាស់ឧបករណ៍នេសាទបែបថ្មីទៅទៀត។ ផលប៉ះពាល់នីមួយៗដោយឡែកពីគ្នា និងផលប៉ះពាល់សរុបរួមគ្នានៃសកម្មភាពបែបនេះ នឹងលេចឡើងយ៉ាងច្បាស់នៅក្នុងកន្លែងនេសាទសហគមន៍ ជាងនៅក្នុងឡូត៍នេសាទដែលមានទំហំធំនោះទៅទៀត។ ហេតុនេះត្រូវបង្កើនការយល់ដឹងឱ្យបានកាន់តែច្រើនឡើងថែមទៀតក្នុងចំណោមអ្នកនេសាទនានា។ ត្រូវធ្វើឱ្យអ្នកនេសាទទាំងនោះបានយល់ដឹងអំពីផលប៉ះពាល់ចំពោះជីវសាស្ត្រ និងប្រព័ន្ធអេកូឡូស៊ី បណ្តាលពីសកម្មភាពរបស់អ្នកទាំងនោះ តាមរយៈការប្រើប្រាស់យុទ្ធសាស្ត្រប្រាស្រ័យទាក់ទងជាច្រើនបែប[18] ។ ការសិក្សាជាលក្ខណៈប្រព័ន្ធអំពីការបង់ខាត និងផលចំណេញខាងសង្គម និងសេដ្ឋកិច្ច នៃឧបករណ៍នេសាទនានា ដែលកំពុងប្រើប្រាស់ គឺជាជំនួយនៅក្នុងការធ្វើសេចក្តីសម្រេចដែលមានការដឹងឮជាមុន អំពីការគ្រប់គ្រងសកម្មភាពនេសាទ។

---

[18] ការប្រាស្រ័យទាក់ទងតាមមធ្យោបាយដែលមានលក្ខណៈស្របគ្នាជាមួយវប្បធម៌ចម្បុប្បន្ននៃប្រជាពលរដ្ឋ គឺជាវិធីដែលមានប្រសិទ្ធភាពជាងការប្រាស្រ័យទាក់ទងជាលាយល័ក្ខអក្សរទៅទៀត។ មធ្យោបាយនេះអាចរួមបញ្ចូល សិល្បៈ និងចម្រៀងប្រពៃណី ល្ខោនអាយ៉ៃ ឬវិទ្យុ។

*(iii) កសិកម្មក្នុងតំបន់ទំនាបលិចទឹក*

ការប្រើប្រាស់កាន់តែច្រើនឡើងនូវតំបន់ទំនាបលិចទឹកសម្រាប់ការធ្វើកសិកម្ម ជាពិសេសសម្រាប់ការធ្វើស្រែ នឹងកាន់តែកើនឡើងជាបន្ថែមទៀត នៅពេលមានការបង្កើតសហគមន៍នេសាទ។ ជំហានដំបូងគឺជាការរានឆ្ការព្រៃលិចទឹកកាន់តែច្រើនជាបន្ថែមទៀតដើម្បីយកដីធ្វើកសិកម្ម និងដើម្បីយកអុស។ គួរតែធ្វើការពិនិត្យអំពីផលប៉ះពាល់លើការបន្តពូជ និងការរកចំណីនៃពពួកត្រីខ្មៅ។ សកម្មភាពដែលនឹងកើតមានជាបន្ត គឺកំណើននៃការប្រើប្រាស់ជីគីមី និងថ្នាំគីមីកសិកម្ម ពីសំណាក់ប្រជាពលរដ្ឋជាចំនួនកាន់តែច្រើនឡើង។ ផលប៉ះពាល់ត្រួតគ្នានៃសកម្មភាពទាំងនេះទៅលើគុណភាពទឹកនៅក្នុងតំបន់ទំនាបលិចទឹក និងផលប៉ះពាល់អវិជ្ជមាននៃគុណភាពទឹកចំពោះធនធានជលផលគឺជាផ្នែកមួយផ្សេងទៀត ដែលត្រូវការឱ្យមានកំណើននៃការយល់ដឹង ការតាមដានកាន់តែហ្មត់ចត់ និងការស្រាវជ្រាវ[19]។ ត្រូវមានការស្រាវជ្រាវអំពីដំណាំផ្សេងពីស្រូវ ដំណាំដែលត្រូវចំណាយតិច និងកសិកម្មសរីរាង្គដែលអាចបង្កើនការប្រើប្រាស់តំបន់ទំនាបលិចទឹក ប៉ុន្តែទៅតាមទម្រង់ដែលមិនបង្កគ្រោះថ្នាក់ចំពោះប្រព័ន្ធអេកូឡូស៊ី។ គួរផ្តល់អាទិភាពចំពោះការសិក្សាដកស្រង់បទពិសោធន៍ពីប្រទេសនានាផ្សេងទៀតនៅក្នុងតំបន់ និងនៅក្រៅតំបន់ដែលប្រឈមនឹងទូគ្រោះប្រហាក់ប្រហែលគ្នានៃការប្រើប្រាស់តំបន់ទំនាបលិចទឹក[20] ។

| |
|---|
| ត្រូវមានការស្រាវជ្រាវអំពីដំណាំផ្សេងពីស្រូវ ដំណាំដែលត្រូវការចំណាយតិច និងកសិកម្មសរីរាង្គដែលអាចបង្កើនការប្រើប្រាស់តំបន់ទំនាបលិចទឹក ប៉ុន្តែទៅតាមទម្រង់ដែលមិនបង្កគ្រោះថ្នាក់ចំពោះប្រព័ន្ធអេកូឡូស៊ី។ |

*(iv) ផលប៉ះពាល់នៃរចនាសម្ព័ន្ធដែលបានកសាងឡើង*

ការស្រាវជ្រាវអំពីផលប៉ះពាល់នៃរចនាសម្ព័ន្ធទៅលើលំហូរទឹកច្រើនតែបានធ្វើឡើងសម្រាប់រចនាសម្ព័ន្ធខ្នាតធំ ដែលមានផលប៉ះពាល់ចំពោះផ្ទៃរងទឹកភ្លៀងនៃអាងទន្លេទាំងមូល។ ការយកចេញរបាំងព្រួលដែលបានដាក់នៅក្នុងអតីតឡូត៍នេសាទមានន័យថា នៅពេលទឹកស្រក នឹងពុំមានអ្វីជាឧបសគ្គរាំងលំហូរទឹកទៀតឡើយ។ ករណីនេះនឹងធ្វើឱ្យរដូវនេសាទមានរយៈពេលកាន់តែខ្លី និងអាចធ្វើឱ្យនៅមានសល់ទឹកតិចតួចតែប៉ុណ្ណោះសម្រាប់កសិករ។ ការបង្កើតរបាំងតូចៗជាថ្មីនៅក្នុងកន្លែងនេសាទនឹងកាន់តែកើនឡើង និងនាំឱ្យមានវិវាទកាន់តែច្រើនឡើងផងដែរ។ ការធ្វើបែបនេះក៏អាចនាំឱ្យមានកំណើននៃវិវាទថ្មីៗផងដែរ រវាងអ្នកដែលស្ថិតនៅក្នុងកន្លែងនេសាទសហគមន៍ ដែលជាអ្នកពឹងផ្អែកជាសំខាន់លើការដាំដំណាំ និងអ្នកដែលពឹងផ្អែកជាសំខាន់លើការធ្វើនេសាទ។ ការវាយតម្លៃអំពីការប្រែប្រួលនៅកម្រិតមូលដ្ឋានបែបនេះមានសារៈសំខាន់ណាស់ សម្រាប់បង្កើតទំនាក់ទំនងរវាងរចនាសម្ព័ន្ធរូបវន្ត ឌីណាមិកនិងភាពប្រែប្រួលនៃប្រព័ន្ធក្នុងមូលដ្ឋាន និង ជម្រើសលើជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ នៅក្នុងបរិបទនៃសហគមន៍នេសាទ។

[19] សូមអាន ADB, 2005 នូវសេចក្តីសង្ខេបច្បាស់លាស់អំពីលក្ខណៈឌីណាមិកនៃដី-ទឹក និងបញ្ហាអេកូឡូស៊ីដែលពាក់ព័ន្ធ ។

[20] វៀតណាម ឥណ្ឌូណេស៊ី និងបង់ក្លាដែស គឺជាជម្រើសច្បាស់លាស់ក្នុងចំណោមប្រទេសដទៃទៀត ។

*(v) ការស្វែងយល់ពីមុខរបរច្រើនមុខ និងការផ្លាស់ប្តូរមុខរបរ*

ទន្ទឹមនឹងការដាក់ឱ្យប្រើប្រាស់សហគមន៍នេសាទ ទំហំនៃមុខរបរច្រើនបែបនឹងកើនឡើងផងដែរ។ ការប្រែប្រួលនៃសកម្មភាពទៅតាមរដូវ រវាងបុរស និងស្ត្រី ក៏ដូចជារូបភាពនៃការពាក់ព័ន្ធរបស់កុមារ ក៏ត្រូវឱ្យមានការតាមដានដោយប្រុងប្រយ័ត្នផងដែរ។ សក្តានុពលនៃកំណើនការត្រួតត្រានៅមូលដ្ឋានទៅលើធនធាន ដែលកាត់បន្ថយការធ្វើចំណាកស្រុករវាងជនបទនិងទីក្រុង គឺជាបាតុភូត ដែលគួរតែធ្វើការសិក្សាផងដែរ។ ការធ្វើឱ្យតំបន់នៅជនបទស្រូបយកកម្លាំងពលកម្មកាន់តែច្រើន គឺជាគោលដៅសំខាន់សម្រាប់អភិវឌ្ឍន៍សេដ្ឋកិច្ចកម្ពុជា។ ការផ្លាស់ប្តូរស្ថាប័ន ដែលនឹងនាំឱ្យមានការកាត់បន្ថយសម្ពាធនៃចំនួនប្រជាជនទៅលើធនធានធម្មជាតិសម្រាប់រយៈពេលវែង គឺជាសម្មតិកម្មមួយដែលគួរតែធ្វើការសិក្សាផងដែរ។ លក្ខខណ្ឌដែលនាំឱ្យមានការបង្កើតសហគ្រាសលំដាប់ទីពីរ និងលំដាប់ទីបីនៅក្នុងជនបទដែលជាលទ្ធផលនៃមុខងារដែលមានភាពសស្រវើករបស់សហគមន៍នេសាទគឺជាប្រការសំខាន់ដើម្បីស្វែងយល់អំពីទំហំនៃការផ្លាស់ប្តូរមុខរបរនៅជនបទ។ ការពិនិត្យមើលភាពប្រែប្រួលទាំងនេះនៅក្នុងរយៈពេលវែងមានសារៈសំខាន់ណាស់ ប្រសិនបើត្រូវធ្វើការវាយតម្លៃអំពីផលប៉ះពាល់នៃកំណែទម្រង់វិស័យជលផលទៅលើសេដ្ឋកិច្ច។

> សក្តានុពលនៃកំណើនការត្រួតត្រានៅមូលដ្ឋានទៅលើធនធាន ដែលកាត់បន្ថយការធ្វើចំណាកស្រុករវាងជនបទនិងទីក្រុង គឺជាបាតុភូត ដែលគួរតែធ្វើការសិក្សាផងដែរ។ ការធ្វើឱ្យតំបន់នៅជនបទស្រូបយកកម្លាំងពលកម្មកាន់តែច្រើន គឺជាគោលដៅសំខាន់សម្រាប់អភិវឌ្ឍន៍សេដ្ឋកិច្ចកម្ពុជា។

*(vi) ការអភិវឌ្ឍន៍ គឺជាសេរីភាព*

អ្នកមានរបរគ្រប់គ្រងឡូត៍នេសាទបានលើកស្នើឱ្យមានការចាប់ផ្តើមឡើងវិញនូវប្រព័ន្ធឡូត៍នេសាទ។ បច្ចុប្បន្ន ពុំមានដំណើរការគ្រប់គ្រាន់តាមផ្លូវច្បាប់ សម្រាប់ធ្វើការវាយតម្លៃសំណើទាំងនោះឡើយ។ នេះក៏អាចជាចំណែកមួយដែលនាំឱ្យកើតមានទំនាស់សង្គមផងដែរ រវាងសហគមន៍អ្នកនេសាទ ដែលធ្លាប់មានសេរីភាពក្នុងការធ្វើនេសាទដោយគ្មានបារម្ភអំពីការកេងប្រវ័ញ្ចសង្កត់ និងផលប្រយោជន៍ផ្សេងទៀតនៅក្នុងរដ្ឋ ដែលមានបំណងបង្កើតឡើងវិញនូវអំណាចត្រួតត្រាធនធានជលផលនៅទូទាំងប្រទេស។ នៅពេលដែលសិទ្ធិលើការប្រើប្រាស់ និងរបបកម្មសិទ្ធិមានការប្រែប្រួលជាចំបង ដោយសារបទបញ្ញត្តិរដ្ឋបាល ទស្សនទាននៃការចាប់យកមកវិញរបស់ក្រុមអ្នកមានអំណាច សុទ្ធតែជាប្រការដែលអាចកើតមានឡើង។ ការប្រែប្រួលបែបនេះអាស្រ័យជាសំខាន់ទៅលើទម្រង់នៃការវិវត្តនៃផលប្រយោជន៍សង្គម និងនយោបាយ នៅក្នុងតំបន់ដែលមានកំណើនភាពតានតឹងបែបនេះ។ ក្នុងករណីដែលប្រជាពលរដ្ឋជាច្រើនបានទទួលឥទ្ធិពលពីផលវិបាកនៃការអភិវឌ្ឍនៃសេរីភាពរបស់ពួកគេ លក្ខណៈបំពេញថ្មី សម្ព័ន្ធភាពថ្មី និងយុទ្ធសាស្ត្រថ្មី អាចនឹងត្រូវបង្កើតឡើង (Sen, 1999) ។ ទោះបីការផ្លាស់ប្តូរខាងស្ថាប័នរួមចំណែក ឬមិនរួមចំណែកក្នុងការកាត់បន្ថយភាពខ្វះខាតនៅក្នុងប្រព័ន្ធប្រជាធិបតេយ្យនៅក្នុងប្រទេសមួយគឺជាបញ្ហាសង្គមក៏ដោយ គេត្រូវតែមានការសិក្សាអំពីប្រការទាំងនេះផងដែរ។

> នៅពេលដែលសិទ្ធិលើការប្រើប្រាស់ និងរបបកម្មសិទ្ធិមានការប្រែប្រួលជាចំបង ដោយសារបទបញ្ញត្តិរដ្ឋបាល ទស្សនទាននៃការចាប់យកមកវិញរបស់ក្រុមអ្នកមានអំណាចសុទ្ធតែជាប្រការដែលអាចកើតមានឡើង។

## អនុសាសន៍

ស្ថាប័ន និងនាយកដ្ឋាននានារបស់រដ្ឋាភិបាលកម្ពុជា ត្រូវមានចំណាត់ការប្រកបដោយការប្តេជ្ញា ដើម្បីជំនះការលំបាកជាច្រើនដែលសហគមន៍នៅជាប់ដែនទឹក និងអ្នកដើរតួជាច្រើនផ្សេងទៀត ដែលពាក់ព័ន្ធនៅក្នុងកំណែទម្រង់វិស័យជលផលនៅក្នុងប្រទេសកម្ពុជាត្រូវប្រឈមដើម្បីធ្វើឱ្យប្រាកដថា ផលប្រយោជន៍ពីកំណែទម្រង់វិស័យជលផល ត្រូវបានចែកចាយដល់អ្នកដែលជាគោលដៅក្នុងការទទួលផល។ ចំណាត់ការខ្លះៗក្នុងចំណោមចំណាត់ការទាំងអស់នេះ អាចនឹងសម្រេចទៅបានតាមរយៈការពង្រឹងកិច្ចសហប្រតិបត្តិការរវាងស្ថាប័នដែលមានស្រាប់។ ត្រូវធ្វើការការពិនិត្យឡើងវិញនៅក្នុងរបៀបវារៈនៃស្ថាប័នដែលមានស្រាប់ដើម្បីអនុវត្តសកម្មភាពផ្សេងទៀត។ ចំណាត់ការមួយចំនួនតូចអាចសម្រេចទៅបានតាមរយៈការបង្កើតកិច្ចផ្តួចផ្តើមថ្មីទាំងស្រុងពីសំណាក់អ្នកពាក់ព័ន្ធទាំងឡាយ។ យើងលើកស្នើអនុសាសន៍សំខាន់មួយចំនួនតូចដូចខាងក្រោមដែលគួរតែយកទៅអនុវត្ត ហើយមិនមែនមានន័យថាមានតែអនុសាសន៍ត្រឹមប៉ុណ្ណេះទេ។ ប៉ុន្តែអនុសាសន៍ទាំងនេះចង្អុលបង្ហាញអំពីទិសដៅទូទៅដែលការស្រាវជ្រាវ និងគោលនយោបាយគួរតែយកចិត្តទុកដាក់ ប្រសិនបើត្រូវអនុវត្តកម្មវិធីកំណែទម្រង់វិស័យជលផលប្រកបដោយប្រសិទ្ធភាព និងដំណើរការទៅបានល្អ។

### ៤.១ តួនាទីនាំមុខសម្រាប់វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍នេសាទទឹកសាប

កំណែទម្រង់វិស័យជលផល ដែលបានដាក់ឱ្យអនុវត្តនៅក្នុងវិស័យនេសាទទឹកសាបប្រទេសកម្ពុជានឹងជួយធ្វើឱ្យមានការផ្លាស់ប្តូរនៅក្នុងវិស័យប្រាក់ចំណូលពីការនេសាទ។ គួរតែធ្វើការសិក្សាតាមដានអំពីការផ្លាស់ប្តូរដែលនឹងកើតឡើងនៅក្នុងផ្នែកបច្ចេកវិទ្យានេសាទ ឌីណាមិកជលសាស្ត្រ និងផលប៉ះពាល់នៃកត្តាទាំងនេះទៅលើប្រព័ន្ធអេកូឡូស៊ី។ គោលបំណងសំខាន់មួយ គឺការផ្សព្វផ្សាយបច្ចេកទេសនេសាទដែលផ្តល់ប្រសិទ្ធភាពខ្ពស់ ប៉ុន្តែក៏មិនបង្កការគំរាមកំហែងចំពោះប្រព័ន្ធអេកូឡូស៊ីផងដែរ។ ការកែសម្រួលបច្ចេកវិទ្យាតាមបែបប្រពៃណីខ្លះៗ ដោយប្រើប្រាស់សម្ភារៈជាវត្ថុធាតុដើមថ្មីនៅក្នុងការកសាងឧបករណ៍នេសាទ អាចជាកិច្ចការមួយដែលត្រូវធ្វើការសិក្សាផងដែរ។ ដោយសារជំហាននៃការគ្រប់គ្រងដែនសាទដោយសហគមន៍ នឹងកើនឡើងទៅអនាគត ការយល់ដឹងអំពីឌីណាមិកជលសាស្ត្រនៅកម្រិតសហគមន៍នេសាទនីមួយៗ នឹងនាំឱ្យមានការប្រឈមកាន់តែច្រើន។ ត្រូវធ្វើការតាមដានឱ្យបានម៉ត់ចត់ និងសិក្សាជាបន្ត អំពីផលប៉ះពាល់នៃកត្តាខាងលើ ទៅលើត្រីប្រភេទនានា និងទៅលើប្រព័ន្ធអេកូឡូស៊ីនៃដែនទឹក។ ត្រូវធ្វើការពិចារណាអំពីការប្រើប្រាស់វិធាននៃការចូលរួមរបស់សហគមន៍នៅក្នុងការសិក្សាតាមដាន និងការស្រាវជ្រាវខាងលើ។ វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍នេសាទទឹកសាប គួរដើរតួនាទីនាំមុខដើម្បីធ្វើការស្រាវជ្រាវរកវិធីនានាដើម្បីសម្របសម្រួលឱ្យមានចំណាត់ការស្រាវជ្រាវ និងអភិវឌ្ឍន៍ដោយមានការចូលរួមសមស្របពីសំណាក់បុគ្គល និងសហគ្រាស ដែលមានសមត្ថភាពជំនាញ។ វិទ្យាស្ថាននេះ គួរបង្កើតប្រព័ន្ធផ្សព្វផ្សាយតាមបែបឆ្លើយឆ្លងដើម្បីផ្ទេរព័ត៌មានដែលបានពីការស្រាវជ្រាវ ឬបច្ចេកទេសទៅឱ្យកសិករ អ្នកនេសាទ និង សហគមន៍នេសាទ និងដើម្បីទទួលបានចម្លើយពីអ្នកទាំងនោះមកវិញ អំពីអ្វីដែលជាតម្រូវការចាំបាច់របស់ពួកគាត់។ វិទ្យាស្ថាននេះ ត្រូវធ្វើការផ្លាស់ប្តូរអភិបាលកិច្ចរបស់ខ្លួន និងត្រូវចាត់

ថែងឱ្យមានការអនុវត្តរចនាសម្ព័ន្ធលើកទឹកចិត្តដែលទាក់ទាញអ្នកស្រាវជ្រាវល្អៗប្រកបដោយវិជ្ជាជីវៈសមស្រប និងដែលមានការប្តេជ្ញាខ្ពស់។

### ៤.២ បេសកកម្មថ្មី និងកិច្ចសហប្រតិបត្តិការរវាងវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍នានា

ចលនាការឈានទៅការគ្រប់គ្រងធនធានធម្មជាតិដោយសហគមន៍ ទាមទារឱ្យមានការតម្រង់ទិសស្ថាប័នឡើងវិញ ដោយពង្រឹងឯកទេសលើការងារស្រាវជ្រាវនិងអភិវឌ្ឍន៍ធនធានធម្មជាតិប្លែកៗគ្នាដើម្បីឆ្លើយតបចំពោះតម្រូវការរបស់ក្រុមសហគមន៍ ។ វិទ្យាស្ថាននានាត្រូវកសាងបេសកកម្មរួមគ្នា អំពីការធានានិរន្តរភាព និងការលើកកំពស់ជីវភាពរស់នៅតាមជនបទ។ បន្ទាប់ពីនេះត្រូវមានការរួមបញ្ចូលវិស័យរួមនៃការស្រាវជ្រាវ ក្នុងចំណោមវិទ្យាស្ថានស្រាវជ្រាវកសិកម្មទាំងប្រាំចំបងៗរបស់រដ្ឋ ពោលគឺ វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍នេសាទទឹកសាប (IFReDI) វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា (CARDI) វិទ្យាស្ថានស្រាវជ្រាវដំណាំកៅស៊ូកម្ពុជា (CRRI) មជ្ឈមណ្ឌលជាតិស្រាវជ្រាវសុខភាពសត្វនិងផលិតកម្ម (NAHPIC) និងវិទ្យាស្ថានស្រាវជ្រាវវិទ្យាសាស្ត្រព្រៃឈើនិងសត្វព្រៃ (FWSRI) និងកិច្ចសហប្រតិបត្តិការជិតស្និទ្ធជាមួយទីភ្នាក់ងារស្រាវជ្រាវដទៃទៀត ដូចជា វិទ្យាស្ថានស្រាវជ្រាវសម្រាប់ការអភិវឌ្ឍន៍កម្ពុជា (CDRI) ក៏មានសារៈសំខាន់ផងដែរ។ កិច្ចការទាំងនេះអាចសម្រេចទៅបានតាមរយៈការបង្កើតឱ្យមានចំណងទាក់ទងដែលមានរចនាសម្ព័ន្ធច្បាស់លាស់ រវាងរចនាសម្ព័ន្ធអភិបាលកិច្ច នៃវិទ្យាស្ថានទាំងនេះ។ រាជរដ្ឋាភិបាលកម្ពុជាគួរផ្តល់អាទិភាពលើប្រការទាំងនេះ។

> ចលនាការឈានទៅការគ្រប់គ្រងធនធានធម្មជាតិដោយសហគមន៍ ទាមទារឱ្យមានការតម្រង់ទិសស្ថាប័នឡើងវិញដោយពង្រឹងឯកទេសកម្មលើការងារស្រាវជ្រាវ និងអភិវឌ្ឍន៍ធនធានធម្មជាតិប្លែកៗគ្នា ដើម្បីឆ្លើយតបចំពោះតម្រូវការរបស់ក្រុមសហគមន៍។

### ៤.៣ កិច្ចសហការដើម្បីបង្កើតទិន្នន័យ និងព័ត៌មានថ្មីដែលត្រូវការជាចាំបាច់

នាយកដ្ឋានជលផលគួរធ្វើការពិនិត្យឡើងវិញ និងធ្វើការកែតម្រូវរចនាសម្ព័ន្ធនៃការប្រមូលទិន្នន័យរបស់ខ្លួនដើម្បីសម្របសម្រួលជាមួយតម្រូវការនៅក្នុងស្ថានភាពថ្មី។ វត្តមាននៃព័ត៌មានប្រកបដោយគុណភាព និងសមស្របតាមពេលវេលាមានសារៈសំខាន់ណាស់សម្រាប់ស្វែងយល់អំពីការវិវត្តកាន់តែសាំញ៉ាំនៃការគ្រប់គ្រងធនធានធម្មជាតិ ដោយសហគមន៍នៅក្នុងប្រទេសកម្ពុជា។ ការធ្វើវិមជ្ឈការនៃការគ្រប់គ្រងធនធានជលផល ទាមទារឱ្យមានការផ្លាស់ប្តូរវិធីសាស្ត្រ រចនាសម្ព័ន្ធចាត់ចែង និងការបង្កើតរបៀបយកគំរូសំណាកដើម្បីប្រមូលទិន្នន័យ។ ត្រូវធ្វើការតម្រង់ទិសឡើងវិញ លើការប្រមូលទិន្នន័យអំពីផលនេសាទ និងព័ត៌មានជីវសាស្ត្រ។ ត្រូវបង្កើតឱ្យមានជាលក្ខណៈប្រព័ន្ធនូវការប្រមូលទិន្នន័យ និងព័ត៌មានអំពីដំណើរការស្តីពីការផ្លាស់ប្តូររបៀបរបបការងារ និងការងារដែលនាំឱ្យមានប្រាក់ចំណូលក្នុងចំណោមបុរស ស្ត្រី និងកុមារ ដែលជាលទ្ធផលបានពីការផ្លាស់ប្តូរទៅរកការគ្រប់គ្រងដោយសហគមន៍នេសាទ។ ត្រូវធ្វើការវាយតម្លៃដោយទៀងទាត់ អំពីឥទ្ធិពលនៃការផ្លាស់ប្តូរខាងសេដ្ឋកិច្ច ការចាត់ចែងការងារ សុខុមាលភាពសង្គម និងប្រជាសាស្ត្រ ដោយសហការជាមួយវិទ្យាស្ថានជាតិស្ថិតិ និងនាយកដ្ឋានផែនការ ដើម្បីធានាថាទិន្នន័យទាំងនោះស្របគ្នាជាមួយប្រព័ន្ធគណនារបស់ជាតិ និងយុទ្ធសាស្ត្រកសាងផែនការអភិវឌ្ឍន៍របស់ប្រទេស។

## ៤.៤ ការវិភាគប្រៀបធៀបនូវការចាត់ចែងរចនាសម្ព័ន្ធ

ការជជែកវែកញែកអំពីគុណសម្បត្តិ និងគុណវិបត្តិនៃការផ្លាស់ប្តូរលើការចាត់ចែងរចនាសម្ព័ន្ធ ពីឡូត៍នេសាទទៅជាសហគមន៍នេសាទ នឹងនៅបន្តកើតមានមួយរយៈទៀតនៅក្នុងសង្គមកម្ពុជា។ នាយកដ្ឋានជលផល គួរផ្តួចផ្តើមឱ្យមានការសិក្សាមួយដើម្បីធ្វើការវិភាគប្រៀបធៀប ដោយប្រើប្រាស់ពហុលក្ខណៈវិនិច្ឆ័យ និងការវិភាគអំពីការខាតបង់ធៀបនឹងផលចំណេញនៃការអនុវត្តប្រព័ន្ធឡូត៍នេសាទដែលមានស្រាប់ ជាមួយករណីនៃការគ្រប់គ្រងកន្លែងនេសាទសហគមន៍។ ការធ្វើបែបនេះនឹងជួយធ្វើឱ្យមានការយល់ដឹងអំពីគោលបំណងនៃឥទ្ធិពលខាងសេដ្ឋកិច្ច និងសុខុមាលភាពសង្គម ចំពោះសង្គមកម្ពុជាទូទៅដែលកើតឡើងពីការផ្លាស់ប្តូរពីឡូត៍នេសាទទៅសហគមន៍នេសាទ។ គួរធ្វើការសិក្សាផងដែរ អំពីតម្រូវការឱ្យមានការចាត់ចែងដើម្បីពង្រីកកាលានុវត្តភាពសេដ្ឋកិច្ចនៅក្នុងវិស័យជលផលសម្រាប់ការកែច្នៃ និងលក់ផលនេសាទតាមបែបវិមជ្ឈការ។ គួរផ្តួចផ្តើមឱ្យមានការពិសោធន៍ សាកល្បងអំពីការចាត់ចែងតាមទម្រង់ប្លែកៗ និងធ្វើការវាយតម្លៃអំពីស្ថានភាពសេដ្ឋកិច្ចនៃដំណើរការនោះ។

## ៤.៥ សហគមន៍នេសាទ និងយុទ្ធសាស្ត្រវិមជ្ឈការ និងវិសហមជ្ឈការ

យុទ្ធសាស្ត្រវិមជ្ឈការ និងវិសហមជ្ឈការនៃរាជរដ្ឋាភិបាលកម្ពុជា បានក្លាយជាសសរទ្រូងនៃរបៀបវារៈអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាល។ ក្រុមប្រឹក្សាឃុំ ដែលជារចនាសម្ព័ន្ធស្ថាប័នសម្រាប់អនុវត្តរបៀបវារៈវិមជ្ឈការ និងសហវិមជ្ឈការនឹងកាន់តែមានជំហររឹងមាំ និងប្រកបដោយនិរន្តរភាព ប្រសិនបើកិច្ចផ្តួចផ្តើមសហគមន៍សម្រាប់ការគ្រប់គ្រងធនធានធម្មជាតិ ដូចជាសហគមន៍នេសាទ ត្រូវបានដាក់ឱ្យអនុវត្តនៅក្នុងក្របខ័ណ្ឌនៃយុទ្ធសាស្ត្រនេះសម្រាប់រយៈពេលយូរអង្វែង។ ការធ្វើបែបនេះបានអាចទាមទារឱ្យមានការផ្លាស់ប្តូរខាងផ្នែកច្បាប់។ គួរតែមានការជជែកវែកញែកឱ្យបានទូលំទូលាយនៅក្នុងសង្គមស៊ីវិលអំពីលទ្ធភាព និងបំណងប្រាថ្នានៃចំណាត់ការបែបនេះ។ ក្រសួងមហាផ្ទៃ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងបរិស្ថាន គួរធ្វើការជាមួយគ្នាក្រោមរូបភាពជាដៃគូដើម្បីសម្រេចគោលដៅនេះ។

## ៤.៦ អង្គការសង្គមស៊ីវិល និងទីភ្នាក់ងារផ្តល់ជំនួយ

ការគ្រប់គ្រងធនធានសហគមន៍ក្នុងប្រទេសកម្ពុជា មិនអាចធ្វើទៅបានទេ បើពុំមានអន្តរាគមន៍តាមបែបច្នៃប្រឌិតរបស់អង្គការសង្គមស៊ីវិល និងទីភ្នាក់ងារផ្តល់ជំនួយទេនោះ។ ការពាក់ព័ន្ធរបស់ស្ថាប័នទាំងនេះត្រូវតែមានជាបន្តនៅក្នុងពេលអនាគតដ៏ខ្លីខាងមុខនេះ។ ទោះជាយ៉ាងណាក៏ដោយ ស្ថាប័នទាំងពីរនេះគួរតែគ្រោងយុទ្ធសាស្ត្រសម្រាប់ការដកខ្លួនថយផងដែរ។ ធ្វើបែបនេះបានជោគជ័យ តែនៅពេលស្ថាប័នទាំងនេះជម្រុញការអភិវឌ្ឍន៍ដោយចីរភាពនៅកម្រិតមូលដ្ឋាន ដែលជាកិច្ចផ្តួចផ្តើមប្រកបដោយការចូលរួមត្រឹមត្រូវ និងពឹងផ្អែកលើខ្លួនឯងតែប៉ុណ្ណោះ។ គួរផ្តោតអាទិភាពទៅលើកិច្ចប្រឹងប្រែងដើម្បីធ្វើឱ្យប្រជាជនរួមចំណែកទៅក្នុងការគ្រប់គ្រងធនធានសហគមន៍។ ការរួមចំណែកបែបនេះ អាចធ្វើទៅតាមក្រោមរូបភាពជា ការផ្តល់កម្លាំងពលកម្ម សម្ភារៈ និងធនធានហិរញ្ញវត្ថុតាមតែអាចធ្វើបាន និងសមស្រប។ វិធានការបែបនេះគួរតែដាក់ឱ្យអនុវត្តជាផ្នែករួមមួយនៃកម្មវិធី និងគម្រោងនានា ដែលអនុវត្តនៅក្នុងសហគមន៍ សម្រាប់ការគ្រប់គ្រងធនធានធម្មជាតិ ។ ការសម្របសម្រួលឱ្យកាន់តែ

ជិតស្និទ្ធជាមួយរចនាសម្ព័ន្ធអភិបាលកិច្ច នៅថ្នាក់មូលដ្ឋាន ក្នុងការកសាងផែនការ អនុវត្ត និងតាមដាន គឺជាកិច្ចការសំខាន់ ដើម្បីជៀសវាងបរាជ័យដែលអាចកើតឡើងពីចំណាត់ការរួមគ្នា នៅពេលដែលមានការផ្តាច់ជំនួយ ។

### ៤.៧ ការបង្កើតឱ្យមានការអនុវត្តសហគ្រប់គ្រង និងវិទ្យាស្ថានបណ្តុះបណ្តាល

ដើម្បីធានានិរន្តរភាព និងអភិវឌ្ឍន៍សហគមន៍នេសាទដែលមានតួនាទីឈានមុខ និងកិច្ចផ្តួចផ្តើមសហគមន៍ព្រៃឈើក្នុងប្រទេសកម្ពុជា ទាមទារឱ្យមានការបណ្តុះបណ្តាលអ្នកពាក់ព័ន្ធនានាជាបន្តនៅក្នុងប្រព័ន្ធនេះ ។ នៅពេលដែលសហគមន៍កាន់តែកើនចំនួន និងវិវត្តទីកចម្រើន នៅពេលនោះនឹងត្រូវការឱ្យមានអ្នកឯកទេសជំនាញ ដើម្បីជួយនៅក្នុងការងារប្រចាំថ្ងៃ ។ លើសពីនេះដោយសារចំណាប់អារម្មណ៍នៅទូទាំងពិភពលោកអំពីកិច្ចផ្តួចផ្តើមសហគ្រប់គ្រង ការចែករំលែកបទពិសោធន៍របស់ប្រទេសកម្ពុជានឹងរួមចំណែកធ្វើឱ្យមានការសហប្រតិបត្តិការរវាងមនុស្ស និងមនុស្សនៅទូទាំងពិភពលោក ។ ដើម្បីសម្របសម្រួលគោលបំណងដ៏សំខាន់ទាំងពីរនេះ រាជរដ្ឋាភិបាលកម្ពុជាគួរតែអនុវត្តកិច្ចផ្តួចផ្តើមដើម្បីចាប់ផ្តើមបង្កើតឱ្យមានវិទ្យាស្ថានស្វយ័ត សម្រាប់អនុវត្តសហគ្រប់គ្រង និងការបណ្តុះបណ្តាលដោយទទួលមូលនិធិពីរដ្ឋាភិបាល ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិ និងអង្គការសហគមន៍មូលដ្ឋាន ។ អភិបាលកិច្ចនៃវិទ្យាស្ថានថ្មីបែបនេះគួរត្រូវបានបង្កើតឱ្យទៅជាគំរូនៃសហគ្រប់គ្រងដោយមានការចូលរួមពីតំណាងរបស់រដ្ឋាភិបាល អង្គការសហគមន៍របស់ប្រជាពលរដ្ឋ សង្គមស៊ីវិល និងម្ចាស់ជំនួយ ។ គួរតែអនុញ្ញាតឱ្យមានការចូលរួមពីវិស័យនានាផ្សេងទៀតនៃសហគមន៍ជាតិ និងអន្តរជាតិ នៅពេលដែលវិទ្យាស្ថាននេះវិវត្តន៍ទាំងខាងទំហំ និងមុខងារទៅអនាគត ។

> ការសម្របសម្រួលឱ្យកាន់តែជិតស្និទ្ធជាមួយរចនាសម្ព័ន្ធអភិបាលកិច្ចនៅថ្នាក់មូលដ្ឋាន ក្នុងការកសាងផែនការ អនុវត្ត និងតាមដានគឺជាកិច្ចការសំខាន់ដើម្បីជៀសវាងបរាជ័យដែលអាចកើតឡើងពីចំណាត់ការរួមគ្នានៅពេលដែលមានការផ្តាច់ជំនួយ ។

## សេចក្តីសន្និដ្ឋាន

ប្រសិនបើមានការគ្រប់គ្រងបានល្អ និងពង្រឹងបានរឹងមាំ ការប្រើប្រាស់ធនធានដោយសហគមន៍អាចនាំឱ្យមានការប្រែប្រួលនៅក្នុងគ្រួសារ និងសង្គមដែលទ្រទ្រង់ធនធាននិងលើកកំពស់ជីវភាពរស់នៅដោយភាពកក់ក្តៅ ។ បន្ថែមលើកាត់បន្ថយភាពក្រីក្រ ការគ្រប់គ្រងដោយសហគមន៍អាចរួមវិភាគទានយ៉ាងច្រើនចំពោះការពង្រឹងសមត្ថភាព និងកម្មសិទ្ធិរបស់ប្រជាពលរដ្ឋនៅជនបទក្នុងប្រទេសកម្ពុជា ។ រួមផ្សំជាមួយការផ្តល់យោបល់ដោយចំហ និងការគាំទ្រពីស្ថាប័នស្រាវជ្រាវ និងការអភិវឌ្ឍន៍ សិទ្ធិលើការត្រួតត្រានៅក្នុងមូលដ្ឋាន អាចនាំឱ្យមានការយកចិត្តទុកដាក់ជាបន្ថែមទៀត និងការពង្រឹងប្រព័ន្ធអេកូឡូស៊ីដែនទឹក ដែលមានលក្ខណៈដោយឡែកនៅក្នុងប្រទេសកម្ពុជា ។

តាមរយៈទស្សនៈកិច្ចរបស់យើងនៅក្នុងសហគមន៍នេសាទ យើងបានទទួលព័ត៌មានអំពីកាលានុវត្តភាពកាន់តែច្រើនឡើងសម្រាប់បុរសក្នុងការទ្រទ្រង់ជីវភាពរស់នៅ និងកំណើនកាលានុវត្តភាពការងារធ្វើ និងប្រាក់ចំណូលសម្រាប់ស្ត្រី ។ ប្រជាពលរដ្ឋបាននិយាយកាន់តែច្រើនឡើង អំពីវិធីដែលគាំទ្រការប្រើប្រាស់ប្រាក់ចំណូល ដើម្បីធ្វើឱ្យកុមារមានសុខភាពមាំមួនជាងមុន និងបាន

ទទួលការអប់រំប្រសើរជាងមុន។ ពួកគេបាននិយាយអំពីការថយចុះនៃអំពើហិង្សាក្នុងគ្រួសារ។ កំណើនសិទ្ធិអំណាចគ្រប់គ្រងធនធាននៅក្នុងមូលដ្ឋាន ក៏នាំឱ្យមានការថយចុះនៃអត្រាផ្លាស់ទី"ទៅមក"[21] របស់បុរស ដើម្បីរកការងារធ្វើផងដែរ។ កត្តាទាំងនេះ រួមជាមួយគ្នា អាចធ្វើឱ្យមានការថយចុះនូវអត្រាមរណភាពកុមារជាច្រើនជំនាន់ ទំហំគ្រួសារ ពង្រឹងកម្រិតអប់រំ និងកំណើនយុត្តិធម៌ខាងយេនឌ័រ។

ការផ្លាស់ប្តូរជាវិជ្ជមានបែបនេះនៅក្នុងផ្នែកអេកូឡូស៊ី សេដ្ឋកិច្ច-សង្គម និងប្រជាសាស្ត្រ នឹងបង្កើតឱ្យមានការរំពឹងទុកខុសៗគ្នាអំពីមុខរបរនៅក្នុងសង្គមមនុស្សជំនាន់ក្រោយៗទៀត។ ការប្រែប្រួលបែបនេះអាចនាំឱ្យមានការកាត់បន្ថយសម្ពាធប្រជាពលរដ្ឋ ទៅលើធនធានជលផល នៅក្នុងពេលអនាគតខ្លីខាងមុខនេះ។ បន្ថែមពីលើការផ្លាស់ប្តូរខាងសិទ្ធិប្រើប្រាស់ធនធានជលផល ប្រសិនបើមានការកើតឡើងវិញនៃកំណើនសេដ្ឋកិច្ច និងកាលានុវត្តភាពការងារនៅក្នុងប្រទេស ការប្រែប្រួលនេះអាចនាំឱ្យមានមនុស្សជំនាន់ក្រោយ ជ្រើសរើសយកមុខរបរផ្សេងទៀតដែលផ្តល់ផលចំណូល។ កាលានុវត្តភាពទាំងនេះអាចបង្កើនឱ្យមានសហគ្រាសខ្នាតតូច និងមធ្យមនៅតាមភូមិ ដែលផ្អែកលើគោលការណ៍នៅមូលដ្ឋាន សម្រាប់ធ្វើការកែច្នៃធនធានជលផលដើម្បីបម្រើទីផ្សារនៅក្នុងទីក្រុង និងទីផ្សារសម្រាប់ការនាំចេញ និងនាំឱ្យមានប្រាក់ចំណូលកាន់តែខ្ពស់។ កំណើនប្រជាធិបតេយ្យខាងសេដ្ឋកិច្ចគឺជាលក្ខខណ្ឌចាំបាច់ សម្រាប់បង្កើនភាពថ្លៃថ្នូររបស់មនុស្ស និងបង្កើតឱ្យមានស្ថិរភាពនយោបាយខាងប្រជាធិបតេយ្យ និងសន្តិភាព។ ស្ថានភាពនេះ នឹងមានឥទ្ធិពលទូលំទូលាយទៅលើអនាគតរបស់ប្រទេសនេះ។

កំណែទម្រង់វិស័យជលផលនៅក្នុងប្រទេសកម្ពុជា មានប្រវត្តិដ៏យូរលង់មកហើយ។ ជំហានដើមដំបូងនានា គឺជាការចាត់វិធានការប្រកបដោយការពិចារណាដែលផ្តោតទៅលើប្រសិទ្ធភាព និងការបង្កើនការប្រមូលថ្លៃឈ្នួល និង ដែលស្របជាមួយការពិចារណាខ្លះៗ អំពីទិដ្ឋភាពសង្គម-នយោបាយ។ ដំណាក់កាលបច្ចុប្បន្ននៃកំណែទម្រង់បានផ្អែកទៅលើបរិបទនៃការវិវត្តថ្មីៗនេះរបស់ប្រទេសកម្ពុជា ឆ្ពោះទៅលទ្ធិប្រជាធិបតេយ្យ និងសមាហរណកម្មទៅក្នុងសេដ្ឋកិច្ចពិភពលោក។ នេះជាផ្នែកមួយនៃយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ដែលមានបំណងដើម្បី :

> "*កសាងសង្គមកម្ពុជាដោយរឹងមាំ និងជាជំហានៗតាមរយៈការពង្រឹងសន្តិភាព ស្ថិរភាព និងសណ្តាប់ធ្នាប់សង្គម ដែលពង្រឹងប្រជាធិបតេយ្យ និងលើកកំពស់ការគោរពសិទ្ធិមនុស្ស និងភាពថ្លៃថ្នូរ*"

នេះជាគោលបំណងដែលគួរឱ្យកោតសរសើរ។ គួរចាត់ទុកដំណាក់កាលបច្ចុប្បន្ននៃកំណែទម្រង់ឈានទៅសហគមន៍នេសាទ ថាជាការប្តេជ្ញាដ៏សំខាន់ដើម្បីឈានទៅសម្រេចគោលដៅនានាទាំងនេះ។ ក្នុងពេលដែលវាជាវិធានដែលមានលក្ខណៈពីលើចុះក្រោម និងពីក្រោមឡើងទៅលើវិញ ក្នុងពេលជាមួយគ្នាបែបនេះ វាជារឿងធម្មតាទេ ដែលគេអាចសង្កេតឃើញថាមានការសង្ស័យ និងការព្រួយបារម្ភអំពីចំណាប់អារម្មណ៍ និងភាពរស់រវើកនៃសហគ្រាសទាំងមូលទាំងនៅខាងរដ្ឋាភិបាល និងប្រជាពលរដ្ឋ។ គេពុំចាំបាច់ ផ្តោតការយកចិត្តទុកដាក់ច្រើនពេកទេ ទៅលើការចាត់ចែងអំពីកំណែទម្រង់ទាំងនេះ។ ប្រធានបទនៃ

---

[21] ទ្រឹស្តីអំពីចំណាកស្រុកដែលបានស្នើថា កាលៈទេសៈនៅក្នុងទីកន្លែងកំណើត (ដូចជាភាពក្រីក្រ និងភាពគ្មានការងារធ្វើ) បានរុញច្រាន ឬបង្ខំឱ្យប្រជាជនចាកចេញពីទីកន្លែងដើមនោះ ទៅរកកន្លែងផ្សេង ដែលមានការទាក់ទាញ (ដូចជាអត្រាខ្ពស់នៃកម្រិតជីវភាពរស់នៅ និងកាលានុវត្តភាពការងារ)។

ការជជែកវែកញែកបច្ចុប្បន្ន មិនមែនស្តីពី ថាតើការប្រមូលផលនេសាទក្នុងប្រទេសកម្ពុជាត្រូវបានកែលំអ បែបណា តាមរយៈប្រព័ន្ធឡូត៍នេសាទធំៗ ឬតាមរយៈអង្គការសហគមន៍នេសាទតូចៗនោះឡើយ។ កំណែទម្រង់វិស័យជលផល នឹងត្រូវចាត់ទុកថាធ្វើបានសម្រេចតែនៅពេលណាដែលបណ្តាអ្នកដែលទាក់ទងនឹងធនធានជលផល ត្រូវបានទទួលការធានាសេរីភាព និងបានទទួលរង្វាន់សមស្របដើម្បីឱ្យពួកគាត់ធ្វើបែបនោះ ដោយផ្អែកលើគោលការណ៍និន្តរភាព តាមរយៈកម្លាំងពលកម្មរបស់ពួកគេ ដើម្បីផ្តល់គុណតម្លៃ និងអត្ថន័យចំពោះកំណែទម្រង់នេះ។

នៅក្នុងផ្នែកនេះ ការចាប់ផ្តើមដ៏មានប្រយោជន៍មួយចំនួន ត្រូវបានអនុវត្តរួចមកហើយនៅក្នុងប្រទេសកម្ពុជា។ ប៉ុន្តែនៅមានការប្រឈមជាច្រើនបន្ថែមទៀត នៅក្នុងអនាគតដ៏ខ្លី និងនៅក្នុងរយៈពេលវែងឆ្ងាយទៅខាងមុខ។

> កំណែទម្រង់វិស័យជលផល នឹងត្រូវចាត់ទុកថា ធ្វើបានសម្រេចតែនៅពេលណាដែលបណ្តាអ្នកដែលទាក់ទងនឹងធនធានជលផល ត្រូវបានទទួលការធានាសេរីភាព និងបានទទួលរង្វាន់សមស្របដើម្បីឱ្យពួកគាត់ធ្វើបែបនោះដោយផ្អែកលើគោលការណ៍និន្តរភាព តាមរយៈកម្លាំងពលកម្មរបស់ពួកគេដើម្បីផ្តល់គុណតម្លៃ និងអត្ថន័យចំពោះកំណែទម្រង់នេះ។

# ឯកសារយោង

***Acharya S, 2003***: Off-Farm and Non-Farm Activities in Rural Cambodia, *Cambodia Development Review*, Vol 7, Issue 1

***Acker van F, 2003***: Cambodia's commons: Changing governance, shifting entitlements. CAS/CIMDA Discussion Paper 42, Antwerp

***Ahmed M Navy H, Vuthy L, Tiongco M, 1998***: Socio-Economic Assessment of Freshwater Capture Fisheries of Cambodia: Report of a Household Survey, MRC, Phnom Penh

***ADB, 2005***: The Tonle Sap and its Fisheries, ADB-TSI Brochure, Manila

***Ahmed M & Hirsch P (eds), 1999***: Common Property in the Mekong: Issues of Sustainability and Subsistence, ICLARM Stud.Rev 26, Manila

***Allan JD, et al, 2005***: Overfishing of Inland Waters, *BioScience* Vol 55, No 12

***Baran E, 2005***: Cambodian Fisheries: Facts, Figures and Context, WorldFish Center, Penang

***Best A, 2005***: The Monk, the Farmer, the Merchant, the Mother: Survival Stories of Rural Cambodia, Japan Printing House, Phnom Penh

***Blunt P & Turner M, 2005***: Decentralization, Democracy and Development in a Post-Conflict Society: Commune Councils in Cambodia, in Public Administration and Development, 25, 75-87

***Cacaud P & Sam Sok Phal, 2003***: Review of Regulatory Framework for Inland Fisheries, TSEMP, Phnom Penh

***Daly HE, 2005***: Sustaining Our Commonwealth of Nature and Knowledge, Lecture delivered at the Forum on Social Wealth, University of Massachusetts, Amherst

***Degen P et al, 2000***: Taken for Granted: Conflicts Over Cambodia's Freshwater Fish Resources, Paper Contributed to the 8th IASCP Conference, Bloomington, Indiana

***Degen P & Thouk N, 1999***: Historical, Cultural and Legal Perspectives on the Fishing Lot System in Cambodia, in Ahmed M & Hirsch P (eds) 1999

***Department of Fisheries, 2005***: The Importance of Cambodian Fisheries Globally, Phnom Penh

***Evans, P, 2002***: Fishing Disarmed, Samudra (March) , ICSF Publication, Chennai

***FACT/EJF, 2002***: Feast or Famine? Solutions to Cambodia's Fisheries Conflicts, London

***FACT, 2005***: Decentralisation and Natural Resource Management in Cambodia: Implications of the Decentralisation Process to Date. Phnom Penh

***FAO, 1996***: Management Guidelines for Asian Floodplain River Fisheries, FAO FTP 384/1&2, Rome

***FAO, 1997***: FAO Technical Guidlines for Responsible Fisheries -- Inland Fisheries (6), Rome

***FAO, 2005***: Fishery County Profile - The Kingdom of Cambodia (FID/CP/KHM), Rome

***Guiseppe S, 2000***: Khmer Rural Life in a Changing World: Village Solidarity, Social Networks and Development, Paper presented at the seminar on Khmer Culture and Globalisation, Department of Sociology Royal University of Phnom Penh, Phnom Penh

***Hortle, KG et al, 2004***: An Introduction to Cambodia's Inland Fisheries: Phnom Penh (Cambodia): Mekong River Commission. Mekong Development Series no. 4.

***Keskinen M, 2003***: Socio-Economic Survey of the Tonle Sap Lake, M.Sc Thesis, Helsinki University of Technology, Helsinki

***Kurien J, 1998***: Traditional Ecological Knowledge and Ecosystem Sustainability: New Meaning to Asian Coastal Proverbs, *Ecological Applications*, Vol 8(1) Supplement
***Levinson J, 2002***: An Examination of the Community Fisheries Sub-Decree: Changes and Developments during the Drafting Process, NACA-STREAM, Bangkok

***Ly Vuthy, 2005***: Fisheries Co-Management in Cambodia, Note presented at the APFIC Regional Workshop on Mainstreaming Fisheries Co-Management held in Siem Reap

***Marschke M, 2003***: From Planning to Action: What Can Resource Management Committees Do On the Ground? *Cambodia Development Review* Vol 7, Issue 3

***Munther Torsten, 2005***: The Potential of Community Fisheries for Fair and Sustainable Natural Resources Management in Cambodia, Food Security and Nutrition Policy Support Project, GTZ, Phnom Penh

***Oberndorf RB, 2004***: Law Harmonisation in Relation to the Decentralisation Process in Cambodia, CDRI Working Paoer 31, Phnom Penh

***Oxfam America, 2002***: Cambodia and Tonle Sap: Background Information, East Asia Regional Office, Phnom Penh

***Pellini A, 2004***: Traditional Pagoda Associations and the Emergence of Civil Society in Cambodia, *Cambodia Development Review*, Vol 8 Issue 3

***Ratner B, 2004***: Environmental Rights as a Matter of Survival, *Human Rights Dialogue* (Series 2 Number 11)

***Ratner B et al, 2005***: Undervalued and Overlooked: Sustaining Rural Livelihood Through Better Governance of Wetlands, WorldFish Center Studies and Reviews 28, Penang

***Royal Government of Cambodia, 1999***: The proclamation on the management and elimination of anarchy in fisheries, No. PROR KOR of 10 May 1999.
***Tarr Chou Meng, 2002***: Fishing Lots and People in Cambodia [http://www.rockmekong.org/pubs/Year2003/social/13_chou.PDF]

***Sen A, 1999***: Development as Freedom, OUP, New Delhi

***So Nam & Bouy Roitana, 2005***: A Review of Inland Fisheries Management in Cambodia. Paper presented at the International Seminar on Inland Fisheries Management, September 2005, New Delhi, India

***Somony T, 2002***: Concept of Fisheries Co-Management in Cambodian Context: A Case Study in Fishing Lots #3 and #6, Siem Reap Province, Cambodia, MBA (Thesis), Royal Agricultural College, England

***Srun Lim Song et al, 2004***: The Unsustainable Exploitation of Inland Fisheries Resources in Cambodia, paper presented at the FAO International Workshop on 'International Fisheries Instruments and Factors of Unsustainability and Overexploitation' held in Siem Reap

***Touch ST, 2005***: Implementation and Development of Fishery Community around the Great Lake Region Under the context of the Sub-Decree on the Management of Fishery Community, Paper Presented as FACT Workshop, Phnom Penh

***Touch ST, 2001***: System Approach to Inland Wetland Fisheries Reform: A Proposed Concept for Community-Based Fisheries Resource Management, Cabinet of the Council of Ministers, Phnom Penh

***UNDP, 2002***: Report on the Elections of the Commune Councils, Phnom Penh

***Vibolrith C, 2000***: Evaluation of Ex-fishing Lot No 5 after its abolishment in 1988, Siem Reap Province, Cambodia

## វិទ្យាស្ថានស្រាវជ្រាវ និង អភិវឌ្ឍន៍នេសាទទឹកសាប (IFReDI)

### ចក្ខុវិស័យ

ការអភិវឌ្ឍដោយចីរភាពនូវធនធានជលផលក្នុងដែននេសាទទឹកសាបនៃប្រទេសកម្ពុជា ដើម្បីបង្កើនសន្តិសុខស្បៀង និងវិបុលភាពសេដ្ឋកិច្ច ។

### បេសកកម្ម

ដើម្បីផ្តល់ព័ត៌មានវិទ្យាសាស្ត្រ និងការគាំទ្របច្ចេកទេស សំរាប់ការអភិវឌ្ឍ និងការគ្រប់គ្រងដោយនិរន្តរភាពនូវធនធានជលផល ក្នុងដែននេសាទទឹកសាបនៃប្រទេសកម្ពុជា ដោយផ្អែកលើការស្រាវជ្រាវ ជីវសាស្ត្រ និងសេដ្ឋកិច្ចសង្គម ។

### គោលដៅ

- ប្រមូល វិភាគ និងផ្សព្វផ្សាយតាមបែបវិទ្យាសាស្ត្រ នូវជីវសាស្ត្រ និងសេដ្ឋកិច្ចសង្គម ។
- អភិវឌ្ឍន៍ និងពង្រឹងសមត្ថភាពជាតិសម្រាប់ការគ្រប់គ្រងនេសាទទឹកសាបដោយសមស្រប ។
- បង្កើនជាអតិបរមានូវប្រាក់ចំណូលរបស់អ្នកនេសាទ និងកសិករ ។
- ការប្រើប្រាស់ធនធានជលផលដោយនិរន្តរភាព ។



អាគារលេខ ១៨៦, មហាវិថីព្រះនរោត្តម, រាជធានីភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា,
ប្រអប់សំបុត្រលេខ ៥៨២, ទូរស័ព្ទ/ទូរសារ: (៨៥៥) ២៣ ២២០ ៨១៧
អ៊ីម៉េល: info@ifredi.org គេហទំព័រ: www.ifredi.org

## កំណែទម្រង់វិស័យជលផលនៃប្រទេសកម្ពុជា : ការប្រឈមថ្មី ដែលនាំមក នូវគោលនយោបាយ និង ការស្រាវជ្រាវ

គោលបំណងចំបងនៃឯកសារនេះ គឺជាការបង្កើតឱ្យមានកិច្ចប្រឹងប្រែងតូចមួយ ដើម្បីគូសបញ្ជាក់អំពីការប្រឈមដែលកំពុងកើតឡើង នៅក្នុងដំណាក់កាលបច្ចុប្បន្ននៃកំណែទម្រង់វិស័យជលផលក្នុងប្រទេសកម្ពុជា ដែលជាសមាសភាគសំខាន់មួយ ជាពិសេសនៅក្នុងអន្តរកាលនៃការផ្លាស់ប្តូរពីឡូត៍នេសាទទៅសហគមន៍នេសាទ។ ការប្រឈមនានារួមមានវិសាលភាពនៃកំណែទម្រង់ស្ថាប័ន និង គោលនយោបាយចំណាត់ការនៅមូលដ្ឋាន ការច្នៃប្រឌិត និងការស្រាវជ្រាវ។ យើងបង្ហាញអំពីកិច្ចប្រឹងប្រែងរបស់យើង ដោយចាប់ផ្តើមពីការវាយតម្លៃអំពីសារៈសំខាន់នៃធនធានជលផល និងផ្តល់ព័តមានសង្ខេបអំពីប្រវត្តិដើមដែលនាំឱ្យ មានកំណែទម្រង់នេះ។ បន្ទាប់មកមានការពិនិត្យមើលអំពីការផ្លាស់ប្តូរលើសិទ្ធិនៃការប្រើប្រាស់ និងកម្មសិទ្ធិ ព្រមទាំងអំពីការផ្លាស់ប្តូរនៃប្រព័ន្ធដែលត្រូវបានបង្កើតឡើងដោយសារកំណែទម្រង់នេះ។ លើសពីនេះ ក៏មានការលើកឡើងផងដែរអំពីថាតើអាចធ្វើការវាយតម្លៃបែបណាអំពីការផ្លាស់ប្តូរនៅក្នុងអន្តរកាលនេះ និងអំពីថាតើអាចផ្តល់កិច្ចប្រឹងប្រែងបែបណាដើម្បីគាំទ្រសហគមន៍នេសាទក្នុងការលើកសម្រេចទាំងខាងគោលដៅសេដ្ឋកិច្ច និងសង្គម ។ យើងក៏លើកឡើងផងដែរ អំពីបញ្ហាសាំញ៉ាំ អំពីអត្តសញ្ញាណសង្គម និងការប៉ងប្រាថ្នាដើម្បីបង្កើតឱ្យមានគំនិតថ្មីអំពីការអនុវត្តការងារតាមបែបសហគមន៍។ តួនាទីថ្មីរបស់ស្ត្រី សារៈសំខាន់នៃការបង្កើតបណ្តាញការងារ និងកិច្ចសហការកាន់តែជិតស្និទ្ធជាមួយរចនាសម្ព័ន្ធអភិបាលកិច្ចមូលដ្ឋាននៃប្រទេសកម្ពុជា និងភាពរស់រវើកនៃការចាត់ចែងសង្គមស៊ីវិល ក៏មានគូសបញ្ជាក់នៅទីនេះផងដែរ។ កំណែទម្រង់បានបង្កើតបរិបទថ្មីខាងផ្នែកច្បាប់សម្រាប់ប្រព័ន្ធអេកូឡូស៊ីតូចៗ និងអភិបាលកិច្ចធនធាន។ ប៉ុន្តែការធ្វើបែបនេះនឹងមិនបង្វែរការយកចិត្តទុកដាក់ចេញពី តម្រូវការឱ្យមានការយល់ដឹងអំពីបរិបទធំទូលាយ "ជាសកល" នោះឡើយ ទោះបីការយល់ដឹងនេះទាក់ទងនឹងលក្ខណៈឌីណាមិកនៃប្រព័ន្ធ អេកូឡូស៊ី ឬអាទិភាពនានានៃអភិបាលកិច្ចក៏ដោយ។ យើងស្នើឱ្យមានការពិនិត្យឡើងវិញអំពីអាទិភាពនៃការស្រាវជ្រាវ និងអភិវឌ្ឍន៍វិធីនានា ដើម្បីធ្វើការពិចារណាដោយរីកញែកអំពី "ស្ថានភាពជាក់ស្តែងនៅ មូលដ្ឋាន" ដែលកើតឡើងថ្មី និងវិវត្តន៍ព្រមទាំងបង្ហាញពីទំនាក់ទំនងទម្រឹមគ្នានៃអាទិភាព ទាំងពីរនេះ ជាមួយស្ថានភាពដែលកើតមាន នៅក្នុងបរិបទធំទូលាយនៅ "កម្រិតពិភពលោក"។ ផ្នែកចុងក្រោយនៃការបកស្រាយរបស់យើងមាន ភ្ជាប់ជាមួយនូវអនុសាសន៍នានាសម្រាប់អ្នកដើរតួខុសៗគ្នាដែលពាក់ព័ន្ធនៅ ក្នុងដំណើរការធ្វើកំណែទម្រង់វិស័យជលផល។ នេះជាការអំពាវនាវឱ្យមាន បេសកម្មថ្មី និងកិច្ចសហការកាន់តែច្រើនឡើងពីសំណាក់គ្រឹះស្ថានស្រាវជ្រាវ វិធីសាស្ត្រថ្មីៗសម្រាប់ការប្រមូលទិន្នន័យ ការចូលរួមកាន់តែច្រើនឡើងជាមួយ រចនាសម្ព័ន្ធអភិបាលកិច្ចមូលដ្ឋាន យុទ្ធសាស្ត្រដកថយសម្រាប់ទីភ្នាក់ងារ ផ្តល់ជំនួយ និងអំពីតម្រូវការឱ្យបង្កើតវិទ្យាស្ថានជាតិសម្រាប់អនុវត្ត និងបណ្តុះបណ្តាលអំពីសហគ្រប់គ្រង។

ISBN 99950-65-00-2
9789995065003
ISBN 99950-65-01-0
9789995065010